សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងសំណល់(រឹង-រាវ)
# ក្នុងរាជធានីភ្នំពេញឆ្នាំ២០១៨-២០៣៥

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. ម៉ែត ចាន់កញ្ញា**

**កាំង ម៉េងហេង**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **បណ្ឌិត អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលរៀន ២០២០

ឆ្នាំសរសេរសារណា ២០២៤

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងសំណល់(រឹង-រាវ) ក្នុងរាជធានីភ្នំពេញឆ្នាំ២០១៨-២០៣៥

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

| ស្រាវជ្រាវដោយ | ណែនាំដោយ |
| --- | --- |
| និស្សិតឈ្មោះ **ក. ម៉ែត ចាន់កញ្ញា** | សាស្ត្រាចារ្យជំនួយ **បណ្ឌិត អ៊ុន សកក្កដា** |
| **កាំង ម៉េងហេង** | |

| | | |
| --- | --- | --- |
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលរៀន | ២០២០ |
| ជំនាន់ទី២៤ | ឆ្នាំសរសេរសារណា | ២០២៤ |

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **ម៉េត ចាន់កញ្ញា** និងខ្ញុំបាទ **ភាំង ម៉េងហេង** ជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២៤ ឆ្នាំសិក្សា២០២៣-២០២៤។

ជាបឋមនាងខ្ញុំ និងខ្ញុំបាទ សូមលំឱនកាយវាចាចិត្តដើម្បីសម្តែងការគោរព ការដឹងគុណ និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតជូនចំពោះអ្នកមានគុណទាំងទ្វេ គឺ **លោកឪពុក និងអ្នកម្តាយ** ដែលបានផ្តល់កំណើត ខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចក្រូចឆ្មារហូតដល់ធំធាត់ពេញវ័យ ព្រមទាំងផ្តល់នូវភាពកក់ក្តៅ សេចក្តីស្រឡាញ់ និងការអប់រំទូន្មានប្រៀនប្រដៅកូនៗប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងជម្រុញ និងលើកទឹកចិត្តក្នុងការបញ្ជូនកូនៗទៅទទួលការអប់រំ។ មិនតែប៉ុណ្ណោះ លោកទាំងពីរបានផ្តល់នូវការផ្គត់ផ្គង់ថវិកា និងសិក្ខាបករណ៍ចាប់តាំងពីកម្រិតបឋមសិក្សា មធ្យមសិក្សា រហូតដល់ថ្នាក់បរិញ្ញាបត្រធ្វើឱ្យកូនចងចាំជានិច្ច ដោយមិនអាចបំភ្លេចបាន។

សូមគោរពថ្លែងអំណរគុណចំពោះ **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រង ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យ** ទាំងអស់នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀន អប់រំទូន្មាន លះបង់ពេលវេលាព្រមទាំងកម្លាំងកាយកម្លាំងចិត្តដល់ខ្ញុំទាំងពីរក្នុងរយៈពេលបួនឆ្នាំកន្លងមកដើម្បីឱ្យ នាងខ្ញុំ និងខ្ញុំបាទទទួលបាន នូវចំណេះដឹង ផ្នែកនីតិសាស្ត្រ លើបញ្ហានានាដែលពាក់ព័ន្ធទៅនឹងច្បាប់ជាតិ ព្រមទាំងច្បាប់អន្តរជាតិថែមទៀតផង។ ជាពិសេស សូមថ្លែងអំណរគុណចំពោះ **លោកសាស្ត្រាចារ្យជំនួយបណ្ឌិត អ៊ុន សកក្កដា** ដែលជាសាស្ត្រាចារ្យណែនាំដើម្បីធ្វើឱ្យមាននូវដំណើរការ នៃការតាក់តែង កិច្ចការស្រាវជ្រាវនេះឡើង ប្រកបដោយភាពជោគជ័យ។ ជាពិសេសទៀតនោះ គាត់បានចំណាយកម្លាំងកាយកម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការ ប្រឹងប្រែងពន្យល់ណែនាំតម្រង់ទិសផ្តល់ឯកសារពាក់ព័ន្ធ និងអនុសាសន៍ល្អៗ និងជួយកែលម្អចំណុចខ្វះខាតទាំងឡាយ ដើម្បីធ្វើយ៉ាងណាឱ្យកិច្ចការស្រាវជ្រាវមួយនេះ បានទទួលនូវលទ្ធផលល្អ និងត្រឹមត្រូវ។

ជាចុងក្រោយក៏សូមថ្លែងអំណរគុណ និងសូមប្រសិទ្ធិពរជ័យដល់វត្ថុស័ក្តសិទ្ធិក្នុងលោកសូមជួយថែរក្សាដល់លោកទាំងអស់ដែលបានរៀបរាប់ខាងលើ ជួបតែពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ព្រមទាំងឧទ្ទិសដល់ទេវតា ឥន្ទព្រហ្មជួយឱ្យប្រទេសជាតិយើង រួមទាំងប្រជាជនកម្ពុជាទាំងអស់ជួបតែសុខសន្តិភាព សុវត្ថិភាព និងអភិវឌ្ឍន៍ឱ្យកាន់តែរីកចម្រើនឆ្ពោះទៅមុខជានិរន្តន៍។

# អារម្ភកថា

ក្រោយពីនាងខ្ញុំ និងខ្ញុំបាទបានទទួលនូវការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេល ០៤ឆ្នាំកន្លងមកនេះបានទទួលនូវចំណេះដឹងជាច្រើនទាំងផ្នែកទ្រឹស្តី និងការអនុវត្តនៅក្នុងផ្នែកនេះ។ ដោយផ្អែកទៅតាមលទ្ធភាព និងចំណេះដឹងទាំងអស់ដែលបានសិក្សាកន្លងមកវាជាកត្តាជម្រុញឱ្យមានឱកាសអាចសរសេរសារណាបញ្ចប់ការសិក្សាមួយនេះឡើង។ នៅក្នុងការរៀបចំចងក្រងសារណាមួយនេះឡើងក្នុងគោលបំណងអភិវឌ្ឍន៍ចំណេះដឹងផ្នែកស្រាវជ្រាវ និងបន្សល់ទុកឯកសារការពង្រីកចំណេះដឹងបន្ថែមសម្រាប់ឱ្យសាធារណជន និងអ្នកសិក្សាស្រាវជ្រាវឈ្វេងយល់ឱ្យកាន់តែស៊ីជម្រៅទាក់ទងទៅនឹងប្រធានបទ ការគ្រប់គ្រងសំណល់ (រឹង-រាវ )ក្នុងរាជធានីភ្នំពេញឆ្នាំ២០១៨-២០៣៥ វាក៏ជាសក្ខីភាព និងជាស្នាដៃមួយសម្រាប់ជំនួយដល់ការសិក្សាស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗទៀត។ សារណានេះអាចបញ្ចប់បានដោយរលូន គឺមានការណែនាំពីសំណាក់ **សាស្ត្រាចារ្យជំនួយបណ្ឌិត អ៊ុន សកក្កដា** ដែលបានខិតខំប្រឹងប្រែងជួយជម្រុញដូចជាជួយបង្ហាញពីវិធីសាស្ត្រនានាក្នុងការធ្វើយ៉ាងណាដើម្បីសម្រេចបានជាសារណានេះឡើង។

សារណាមួយនេះ គ្រាន់តែជាការស្រាវជ្រាវ បកស្រាយ និងចងក្រងនូវចំណេះដឹងបន្តិចបន្តួចទៅតាមអ្វីដែល យើងខ្ញុំធ្លាប់បានសិក្សារៀនសូត្រកន្លងមកនេះរួមជាមួយនឹងទិន្នន័យមួយចំនួនដែលបានស្រាវជ្រាវចេញមកពីបណ្ណាល័យនានា និងនៅក្នុងបណ្តាញសង្គមអ៊ីនធើណេតផ្សេងៗទៀតផងដែរ។ យើងខ្ញុំសង្ឃឹមថាសារណាមួយនេះ ជាមូលដ្ឋានមួយសម្រាប់ឈានទៅរកភាពច្បាស់លាស់នៅក្នុងការស្រាវជ្រាវបន្ថែម នាំឱ្យអ្នកអានអ្នកសិក្សាស្រាវជ្រាវយល់ដឹង ព្រមទាំងទទួលបានពុទ្ធិថ្មីៗពីខ្លឹមសារដែលមាននៅក្នុងសារណាមួយនេះ។

មុននឹងបញ្ចប់នាងខ្ញុំ និងខ្ញុំបាទ សូមគោរពទទួលយកនូវរាល់កំហុសខុសឆ្គងត្រង់ណាមួយដោយចេតនាក្តី ដោយអចេតនាក្តី ឬនៅមានចំណុចខ្វះខាតចន្លោះត្រង់កន្លែងណាមួយ សូមមេត្តាខន្តីអភ័យទោសប្រកបដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតហើយរង់ចាំទទួលរងចាំនូវរាល់មតិរិះគន់កែលម្អរាល់ចំណុចខ្វះខាតទាំងឡាយក្នុងន័យស្ថាបនាដើម្បីឱ្យការស្រាវជ្រាវមួយនេះមានន័យគ្រប់គ្រាន់បន្ថែមទៀត។

ជាទីបញ្ចប់ សូមគោរពជូនពរដល់មិត្តនិស្សិត មិត្តអ្នកអានទាំងអស់គ្នាឱ្យទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ច និងមានកម្លាំងមាំមួន ប្រាជ្ញាឈ្លាសវៃជៀសផុតពីជម្ងឺទាំងឡាយទាំងពួងរកស៊ីមានបានគ្រប់គ្នាព្រមទាំងទទួលបាននូវពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃការគ្រប់គ្រងសំណល់ (រឹង-រាវ) ក្នុងរាជធានីភ្នំពេញ**

**១.១. សញ្ញាណនៃសំណល់រឹង-រាវ** ........................................ ៤

**១.១.១. និយមន័យ** ........................................ ៥

**១.១.២. ប្រភេទនៃសំណល់រឹង-រាវ** ........................................ ៦

**១.២. មូលហេតុបង្កឱ្យមានសំណល់រឹង-រាវ** ........................................ ៧

**១.២.១. មូលហេតុនៃសំណល់រឹង** ........................................ ៨

**១.២.២. មូលហេតុនៃសំណល់រាវ** ........................................ ១០

**១.៣. គុណវិបត្តិនៃសំណល់រឹង-រាវ** ........................................ ១១

**១.៣.១. ផលប៉ះពាល់សំណល់រឹង-រាវ** ........................................ ១២

១.៣.១.១. ផលប៉ះពាល់សំណល់រឹង-រាវចំពោះសុខភាពសាធារណៈ ........................................ ១២

១.៣.១.២. ផលប៉ះពាល់សំណល់រឹង-រាវចំពោះបរិស្ថាន ........................................ ១៥

១.៣.១.៣. ផលប៉ះពាល់សំណល់រឹង-រាវចំពោះសោភ័ណភាព ........................................ ១៦

**ជំពូកទី២**

**វិធានការ និងការដោះស្រាយសំណល់ (រឹង-រាវ) ក្នុងរាជធានីភ្នំពេញ**

**២.១. ផែនការ យុទ្ធសាស្ត្ររបស់សាលាក្រុងរាជធានីភ្នំពេញស្តីពីសំណល់រឹង-រាវ** ........................................ ១៨

**២.១.១. គោលការណ៍ណែនាំ** ........................................ ១៨

**២.១.២. ចក្ខុវិស័យ** ........................................ ១៩

**២.១.៣. បេសកកម្ម** ........................................ ២០

**២.១.៤. គោលដៅ** ........................................ ២០

**២.២. ភាគីពាក់ព័ន្ធក្នុងការគ្រប់គ្រងសំណល់** ........................................ ២២

**២.២.១. បទប្បញ្ញត្តិ** ........ ២២

**២.២.២. អគ្គនាយកដ្ឋានគាំពារបរិស្ថាននៃក្រសួងបរិស្ថាន** ........ ២៤

**២.២.៣. តួនាទី និងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធ** ........ ២៤

**២.២.៤. រដ្ឋបាលរាជធានីភ្នំពេញ** ........ ២៦

**២.៣. ពង្រឹងប្រព័ន្ធសេវាកម្មប្រមូលសំរាម** ........ ២៨

**២.៣.១. ការបញ្ចេញសំណល់ និងកំណត់ទីតាំងស្តុកបណ្តោះអាសន្ន** ........ ៣១

២.៣.១.១. ការញែកសំណល់ឱ្យបានត្រឹមត្រូវ ........ ៣២

២.៣.១.២. ការរៀបចំទីតាំងទុកដាក់សំណល់បណ្តោះអាសន្ន ........ ៣៤

២.៣.១.៣. ពង្រឹងវិធានការប្រឆាំងការបោះចោលសំរាមគ្មានសណ្តាប់ធ្នាប់ ........ ៣៥

**២.៣.២. ការធ្វើឱ្យប្រសើរនូវសេវាប្រមូលសំណល់ សម្អាតផ្លូវ និងទីសាធារណៈ** ........ ៣៧

២.៣.២.១. ការកែលម្អផែនការប្រតិបត្តិការ និងការប្រមូលសំណល់ឱ្យល្អប្រសើរ ........ ៣៧

២.៣.២.២. ការពិនិត្យនូវថ្លៃសេវាកម្មដើម្បីឱ្យការប្រមូលមានប្រសិទ្ធភាពខ្ពស់ ........ ៤០

២.៣.២.៣. ការកំណត់លើភាពជាដៃគូរជាមួយក្រុមហ៊ុនប្រមូលសំរាម ........ ៤២

**២.៤. បញ្ហាប្រឈម និងដំណោះស្រាយ** ........ ៤២

**២.៤.១. បញ្ហាប្រឈម** ........ ៤២

**២.៤.២. ដំណោះស្រាយ** ........ ៤៣

២.៤.២.១. ការដោះស្រាយចំពោះសំណល់រឹង ........ ៤៤

២.៤.២.២.ដំណោះស្រាយចំពោះកាកសំណល់រាវ ........ ៥០

**សេចក្តីសន្និដ្ឋាន** ........ ១១

**អនុសាសន៍** ........ ៥១

**ឯកសារយោង**

**បញ្ជីឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជា ធ្លាប់បានឆ្លងកាត់ការផ្លាស់ប្តូររបបនយោបាយ ក៏ដូចជាសង្គ្រាមទាំងផ្ទៃក្នុង ជាមួយនឹងប្រទេសជិតខាងជាច្រើនលើកច្រើនសារ។ លើសពីនេះទៅទៀតក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាដែលស្ថិតនៅក្រោមការដឹកនាំរបស់ ប៉ុល ពត បានធ្វើឱ្យប្រទេសជាតិទទួលរងនូវវិនាសកម្មយ៉ាង ធំធេងបំផុត ពោល គឺរបបនោះត្រូវបានគេហៅថារបបប្រល័យពូជសាសន៍។ ក្រោយការផ្តួលរលំរបបនេះមក ប្រទេសកម្ពុជាយើងបានខិតខំប្រឹងប្រែង និងឥតឈប់ឈររបស់ថ្នាក់ដឹកនាំកម្ពុជា និងបានរៀបចំប្រទេសដោយ បាតដៃទទេ ក្លាយជាប្រទេសដែលមានអធិបតេយ្យ និងមានការទទួលស្គាល់ពីមជ្ឈដ្ឋានពិភពលោក។

ដើម្បីធ្វើឱ្យប្រទេសកាន់តែរីកចម្រើន ក៏ដូចជាការផ្តោតសំខាន់ទៅលើ សោភ័ណភាពទីក្រុង ឱ្យមានភាព ទាក់ទាញ ចាំបាច់ត្រូវមានការគ្រប់គ្រងទៅលើបរិស្ថាន ជាពិសេស គឺសំណល់រឹង-រាវ ដែលកើតចេញពីរបស់របរ ប្រើប្រាស់ប្រជាពលរដ្ឋប្រចាំថ្ងៃ ដូចជាថង់ អាហារ សម្លៀកបំពាក់ចាស់ៗ ដប កំប៉ុង ស្បែកជើងចាស់ៗ បន្លែ ជ័រ និងអ្វីផ្សេងៗទៀតដែលគេលែងប្រើប្រាស់ នោះគេចាត់ទុកថាជាកាកសំណល់ដែលអត់ប្រយោជន៍ និងត្រូវបោះវា ចោល។ សំណល់រឹង-រាវ គឺជារូបធាតុនានា ដែលគ្មានសារៈប្រយោជន៍ទៀត នៅក្នុងទម្រង់ ឬលក្ខខណ្ឌបច្ចុប្បន្ន របស់វា ។

ការគ្រប់គ្រងសំណល់រឹង-រាវ គឺជាការទុកដាក់រូបធាតុសំណល់ ដែលកើតមកពីប្រភពឧស្សាហកម្ម គេហដ្ឋាន ឬឧស្សាហកម្ម តាមរបៀបមួយដែលចំណាយតិច និងគ្មានការខូចខាតបរិស្ថាន។ កត្តាកំណើនចំនួន ប្រជាជន កំណើនកំរិតជីវភាពរស់នៅ កំណើននគរូបនីយកម្ម និងឧស្សាហកម្ម បាននាំមកនូវបរិមាណសំណល់ រឹង-រាវកាន់តែច្រើន នៅប្រទេសឧស្សាហកម្មដូចជា សហរដ្ឋអាមេរិច ជប៉ុន សឹង្ហបុរី ឬបារាំង ក៏ដូចជានៅប្រទេស កំពុងលូតលាស់ដូចជាកម្ពុជា និងឥណ្ឌាជាដើម។ សំណល់រឹង-រាវ ពិតជាមានឥទ្ធិពលយ៉ាងធ្ងន់ធ្ងរទៅលើផ្នែក សុខភាពសាធារណៈ និងបរិស្ថានប្រសិនបើគេស្តុកប្រមូល និងចាក់ចោលដោយមិនត្រឹមត្រូវ។ ផលប៉ះពាល់ ខ្លាំងជាងគេ ដែលបណ្តាលមកពីការគ្រប់គ្រងសំណល់រឹង-រាវមិនបានល្អរួមមាន ការបំពុលខ្យល់ ការបំពុលទឹក និងការចម្លងជម្ងឺរាតត្បាតដល់មនុស្ស។ វាបានធ្វើឱ្យទីក្រុងបាត់បង់សោភ័ណភាព និងកខ្វក់ប៉ះពាល់ដល់ខាង សុខភាព និងផ្លូវចិត្តរបស់មនុស្ស ហើយអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់សត្វ និងរុក្ខជាតិ។

ការគ្រប់គ្រងកាកសំណល់ គឺជាចំណោទដ៏ចម្បង ដែលរដ្ឋាភិបាលនានាលើពិភពលោកប្រឈមមុខ ពិសេសនៅកម្ពុជា សំណល់ គឺជាការបំពុលដែលឃើញជាក់ស្តែងបំផុត។ ការគ្រប់គ្រងកាកសំណល់ ការប្រមូល និងដឹកជញ្ជូនសំណល់នៅភ្នំពេញ គឺជាបញ្ហាដ៏គួរឱ្យព្រួយបារម្ភរបស់សាលាក្រុង ដែលជាអ្នកទទួលខុសត្រូវក្នុង ការចាក់ចោលសំណល់រឹង-រាវ ហើយក៏ជាកង្វល់របស់ក្រសួងបរិស្ថាន ដែលកំពុងខិតខំតាក់តែងច្បាប់ សម្រាប់ អង្កេតតាមដាន និងត្រួតពិនិត្យការបំពុលឱ្យមានប្រសិទ្ធភាព។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

មកទល់ត្រឹមនេះ យើងបានដឹងអំពីសារៈសំខាន់នៃការគ្រប់គ្រងសំណល់រឹង-រាវ និងភាពចាំបាច់ដែលត្រូវរួមធ្វើទាំងអស់គ្នា ប៉ុន្តែប្រជាពលរដ្ឋយើងមួយចំនួនមិនទាន់ដឹងនៅឡើយទេ អំពីការគ្រប់គ្រងសំណល់រឹង-រាវនៅរាជធានីភ្នំពេញ ជាពិសេស គឺ ការញែក ការវេចខ្ចប់ ការទុកដាក់ ការបញ្ចេញសំរាម និងមានវិធានការនៃការគ្រប់គ្រង។ សំណួរក្នុងការស្រាវជ្រាវលើប្រធានបទនេះ បានលើកឡើងថា តើការគ្រប់គ្រងសំណល់រឹង-រាវនៅក្នុងរាជធានីភ្នំពេញ មានការប្រព្រឹត្តទៅ យ៉ាងដូចម្តេចដែរ ? ថាតើមានបញ្ហាប្រឈម និងដំណោះស្រាយអ្វីខ្លះជាមួយអ្នកពាក់ព័ន្ធដូចជា សាលារាជធានីភ្នំពេញ ក្រុមហ៊ុនឯកជនដែលប្រមូលសំរាម និងជាពិសេស គឺបងប្អូនប្រជាពលរដ្ឋផ្ទាល់តែម្តង ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងក្នុងគោលបំណងដើម្បីរកឱ្យឃើញអំពីវិធានការគ្រប់គ្រងសំណល់រឹង-រាវនៅរាជធានីភ្នំពេញ ក៏ដូចជា ផែនការយុទ្ធសាស្ត្ររបស់សាលារាជធានីភ្នំពេញ ក្នុងការធ្វើឱ្យប្រជាពលរដ្ឋទទួលបានការអប់រំ និងចំណេះដឹងទាក់ទងនឹងការញែក ការវេចខ្ចប់ ការទុកដាក់ និងបញ្ចេញសំរាមរបស់ពួកគាត់ មិនត្រឹមតែប៉ុណ្ណោះ ឯកសារស្រាវជ្រាវនេះក៏ជាការប្រមូលគ្រប់អ្នកពាក់ព័ន្ធ វិស័យរដ្ឋ វិស័យឯកជន និងប្រជាពលរដ្ឋផ្ទាល់ឱ្យមានការចូលរួមយ៉ាងសកម្ម ក្នុងកិច្ចការពារនៅបរិស្ថានរបស់យើងគ្រប់ៗគ្នា ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទនៃការស្រាវជ្រាវនេះ គឺធ្វើឡើងនៅតែរាជធានីភ្នំពេញតែប៉ុណ្ណោះដែលត្រូវបានសិក្សាស្រាវជ្រាវនៅសាលារាជធានីភ្នំពេញ វិស័យឯកជន និងមានការដក់ស្រង់ចេញពីប្រភពឯកសារច្បាប់មួយចំនួន តាមរយៈគេហទំព័រ និងឯកសារដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំណល់។ ការសិក្សាស្រាវជ្រាវនេះ គឺស្ថិតនៅក្នុងអាណត្តិទី៧ នៃការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ក្នុងឆ្នាំ២០២៣-២០២៤។

## ៥. សារសំខាន់នៃការសិក្សាស្រាវជ្រាវ

ចំពោះសារៈប្រយោជន៍ក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះនឹងចូលរួមយ៉ាងសំខាន់ក្នុងដំណើរការនៃការគ្រប់គ្រងសំណល់រឹង-រាវនៅរាជធានីឱ្យកាន់តែមានប្រសិទ្ធភាព និងជាពិសេស គឺអ្នកជំនាន់ក្រោយនឹងអាចទទួលបានឯកសារ និងចំណេះដឹងកាន់តែទូលំទូលាយ ដើម្បីបំពេញសេចក្តីត្រូវការ ឬក៏អាចជាការជួយបាននូវអ្វីដែលខ្វះខាតនានានៅពេលបច្ចុប្បន្ននេះ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីស្រាវជ្រាវសរសេរចងក្រងសារណាមួយនេះ ចំពោះឯកសារ នាងខ្ញុំ និងខ្ញុំបាទបានធ្វើការស្រាវជ្រាវលើការគ្រប់គ្រងឯកសារពាក់ព័ន្ធ ដូចជា ច្បាប់ អនុក្រឹត្យ សារាចរណែនាំ សៀវភៅណែនាំនានាទាក់ទងទៅនឹងបរិស្ថាន និងតាមរយៈប្រព័ន្ធអ៊ីនធើណេតផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវសារណានេះ បានចែកចេញជាពីរជំពូកដែលដូចតទៅ៖

**ជំពូកទី១ សញ្ញាណទូទៅនៃការគ្រប់គ្រងសំណល់(រឹង-រាវ) ក្នុងរាជធានីភ្នំពេញ**

នៅក្នុងជំពូកនេះ ក្រុមខ្ញុំបានបែងចែកជាបីចំណុចបន្ថែមទៀតដោយ ចំណុចទី១ សញ្ញាណទូទៅនៃសំណល់រឹង-រាវ ចំណុចទី២ បុព្វហេតុដែលបង្កឱ្យមានសំណល់រឹង-រាវ និងចំណុចទី៣ បង្ហាញពីគុណវិបត្តិនៃសំណល់រឹង-រាវ

**ជំពូកទី២ វិធានការ និងការដោះស្រាយសំណល់(រឹង-រាវ) ក្នុងរាជធានីភ្នំពេញ**

នៅក្នុងជំពូកនេះផងដែរ ក្រុមខ្ញុំបានបែងចែកជាបួនចំណុចបន្ថែមទៀតដោយ ចំណុចទី១ ផែនការយុទ្ធសាស្ត្ររបស់សាលាក្រុងរាជធានីភ្នំពេញស្តីពីសំណល់រឹង-រាវ ចំណុចទី២ ភាគីពាក់ព័ន្ធក្នុងការគ្រប់គ្រងសំណល់ ចំណុចទី៣ ពង្រឹងប្រព័ន្ធសេវាកម្មប្រមូលសំរាម និងចំណុចទី៤ បញ្ហាប្រឈម និងដំណោះស្រាយ។

# ជំពូកទី១

# សញ្ញាណទូទៅនៃសំណល់រឹង-រាវ

# ជំពូកទី១

# សញ្ញាណទូទៅនៃការគ្រប់គ្រងសំណល់ (រឹង-រាវ) ក្នុងរាជធានីភ្នំពេញ

## ១.១. សញ្ញាណនៃសំណល់រឹង-រាវ

បរិស្ថាន គឺសំដៅលើរបស់គ្រប់យ៉ាងដែលស្ថិតនៅជុំវិញខ្លួនយើងដែលគិតទាំងរបស់មានជីវិត និងគ្មានជីវិត។ បរិស្ថានល្អ ឬស្អាតអាស្រ័យលើកត្តាមួយចំនួនដូចជា ខ្យល់អាកាសបរិសុទ្ធ ប្រព័ន្ធទឹកស្អាត ទេសភាពក្នុង និងក្រៅក្រុងស្រស់បំព្រង ទន្លេ ព្រៃ ភ្នំ មានលក្ខណៈស្រស់ស្អាតមានសត្វគ្រប់ប្រភេទរស់នៅ។ល។ ចំណែកឯបរិស្ថានមិនល្អ មិនស្អាតវិញ គឺមានសភាពខុសស្រលះពីបរិស្ថានស្អាតទាំងស្រុង។ បរិស្ថានមិនស្អាតដូចជាខ្យល់អាកាសអាប់អួរដោយសារតែគ្រឿងចក្រ យានយន្ត និងរោងចក្រ គ្មានប្រព័ន្ធទឹកស្អាត គ្មានប្រព័ន្ធលូ ការរំខានដោយសម្លេង គំនរសំរាមដែលបញ្ចេញក្លិនស្អុយពីកាកសំណល់ជាដើម។ កាកសំណល់ នៅក្នុងទីប្រជុំជនក្នុងរាជធានីភ្នំពេញនៅតែជាបញ្ហាដ៏សំខាន់មួយនាពេលបច្ចុប្បន្នជាពិសេសនោះ គឺទីក្រុងភ្នំពេញដែលយើងសង្កេតឃើញថាពេលខ្លះសំរាម សំណល់រឹង-រាវ ស្ថិតនៅរាយប៉ាយនៅតាមដងផ្លូវ និងទីសាធារណៈមួយចំនួន គឺនៅពេលដែលការប្រារព្ធពិធីបុណ្យជាតិធំៗមួយចំនួនដូចជាពិធីបុណ្យអុំទូក បុណ្យភ្ជុំបិណ្ឌ និងពិធីបុណ្យចូលឆ្នាំជាដើម។ កំណើនសំរាមនៅក្នុងរាជធានីភ្នំពេញ និងតាមទីប្រជុំជននានា គឺជាក្តីកង្វល់របស់យើងទាំងអស់គ្នាដែលចាំបាច់គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានត្រូវតែចូលរួមគ្រប់គ្រងសំណល់ដោយខ្លួនឯងបង្កើតឡើងឱ្យបានត្រឹមត្រូវដើម្បីជៀសវាងការបំផ្លាញបរិស្ថាន សោភ័ណភាពនៅក្នុងសហគមន៍។

កំណើនសំរាមនៅរាជធានីភ្នំពេញ និងនៅតាមទីប្រជុំជននានា ក្នុងប្រទេសកម្ពុជានាពេលនេះដោយសារតែកំណើនប្រជាពលរដ្ឋ ការផ្លាស់ប្តូរជីវភាពរស់នៅរបស់ប្រជាជន និងទំនៀមទម្លាប់នៃការប្រើប្រាស់និងការវេចខ្ចប់ទំនិញ ហើយការកែច្នៃពីសំរាមនៅមានកម្រិតទាបនៅឡើយ។ កត្តាទាំងនេះ បានធ្វើឱ្យសំរាមសំណល់រឹងមានបរិមាណដែលកើនឡើងឥតឈប់ឈរ។ បើយើងសង្កេតមើលឱ្យល្អិតល្អន់ទៅលើបរិស្ថានដែលនៅជុំវិញខ្លួនយើង គឺអាចនិយាយបានថា សុទ្ធសឹងតែពោរពេញទៅដោយសំរាម បញ្ហានេះកើតឡើងដោយសារតែមិនមានការចូលរួមយកចិត្តទុកដាក់ និងជួយពីសំណាក់ប្រជាជន បន្ទាប់ពីមានការជ្រោមជ្រែងពីរដ្ឋាភិបាលកន្លងមក។ បញ្ហានេះអាចមកពីពួកគេមិនមានការយល់ដឹងគ្រប់គ្រាន់ទៅលើបញ្ហានេះ ឬពួកគេបានយល់ដឹងពីផលវិបាកដែលបង្កដោយសំរាមនេះតែបែរជាមិនប្រព្រឹត្តតាមទៅវិញ។ ចំណែកឯហេតុផលមួយទៀតនោះអាចមកពីនៅតាមទីកន្លែងសាធារណៈ ក៏ដូចជាតំបន់ផ្សេងៗដែលប្រជាពលរដ្ឋរស់នៅ និងនៅតាមទីកន្លែងកម្សាន្ត មិនមានធុងសំរាមសំរាប់ផ្ទុកសំរាមគ្រប់គ្រាន់ គឺមានន័យថា កន្លែងនីមួយៗទោះជាមានធុងសំរាម តែវាមានគម្លាតឆ្ងាយពីគ្នាពេក។ **ឧទាហរណ៍** នៅតាមតំបន់កម្សាន្តនានា យើងឃើញថាមិនសូវមានធុងសំរាម

សម្រាប់ចោលកាកសំណល់ផ្សេងៗ ទើបបានជាភ្ញៀវទេសចរចោលសំរាមពាសវាលពាសកាលដោយមិនខ្វល់ពីសោភ័ណភាព និងសម្រស់របស់រមណីយដ្ឋាននានា។ បើនិយាយពីបញ្ហានេះនៅរាជធានីភ្នំពេញវិញ យើងឃើញថាទីក្រុងមានការគ្រប់គ្រងនឹងយកចិត្តទុកដាក់ក៏ពិតមែន តែបញ្ហាសំរាមនៅតែជាកង្វល់សម្រាប់សង្គមយើងដដែល។ រាជរដ្ឋាភិបាលបានផ្តល់ជូននូវធុងសំរាមនៅស្ទើរតែគ្រប់ទីកន្លែង តែបានបន្សល់កាកសំណល់ពេញទីក្រុងដដែល ពីព្រោះការប្រមូលកាកសំណល់ផ្សេងៗពីក្រុមហ៊ុនប្រមូលសំរាមមានការយឺតយ៉ាវពេកទើបបានជាបង្កសំរាមទាំងអស់ទៅជាគំនរសំរាមដ៏ធំមួយ ពីព្រោះកាកសំណល់ទុកចោលយូវាមិនត្រឹមតែមិនផ្តល់នូវសោភ័ណភាពនោះទេ វាអាចផ្តល់នូវក្លិនមិនល្អ និងអាចប៉ះពាល់ដល់សុខភាពផងដែរ។ នៅប្រទេសដែលមានសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍យ៉ាងឆាប់រហ័ស តែងតែធ្វើឱ្យមានការកើនឡើងនូវបរិមាណកាកសំណល់យ៉ាងច្រើនដោយសារការប្រើប្រាស់របស់ប្រជាពលរដ្ឋម្នាក់ៗ មានការកើនឡើងទៅតាមកម្រិតជីវភាពរបស់ពួកគេការទិញសម្ភារថ្មីៗ បានក្លាយជាជម្រើសមួយយ៉ាងទាក់ទាញជាជាងមានការជួសជុលរបស់ចាស់ៗដើម្បីប្រើប្រាស់ឡើងវិញ ដូច្នេះវាធ្វើឱ្យមានការកើនឡើងកាកសំណល់ទៅតាមសកម្មភាពនៃការប្រើប្រាស់របស់ពួកគេផងដែរ។ ការធ្វើនគរូបនីយកម្ម និងកំណើនឧស្សាហកម្មក៏បានបង្កើតកាកសំណល់ជាច្រើនផងដែរដែលតម្រូវឱ្យមានការគ្រប់គ្រងយ៉ាងយកចិត្តទុកដាក់ពីសំណាក់អាជ្ញាធរដែនដី និងថ្នាក់ដឹកនាំប្រទេសរួមទាំងភាគីដែលពាក់ព័ន្ធមួយចំនួនទៀត។ ដូច្នេះប្រសិនបើយើងធ្វើការគ្រប់គ្រងកាកសំណល់រឹង-រាវ មិនបានល្អ ឬគ្មានប្រសិទ្ធិភាពទេនោះ វានឹងបង្កឱ្យមានការចម្លងនូវជម្ងឺផ្សេងៗមកដល់មនុស្ស សត្វព្រមទាំងបានជះឥទ្ធិពលដល់បរិស្ថានទៀតផង។

### ១.១.១. និយមន័យ

- **សំណល់រឹង** គឺសំដៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់កម្ទេចកម្ទីដែលលែងត្រូវការប្រើប្រាស់ ហើយត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះចោល ឬតម្រូវឱ្យបោះបង់ចោល។ នៅក្នុងចំណុចសំណល់រឹង ជាចំណុចសំខាន់ក្នុងការសិក្សាស្រាវជ្រាវ ដើម្បីធ្វើឱ្យទីក្រុងមានសោភ័ណភាព។ សំណល់រឹងបែងចែកជា២ប្រភេទ គឺសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់
    - **សំរាម** គឺជាផ្នែកមួយនៃសំណល់រឹង ដែលពុំមានផ្ទុកសារជាតិពុល ឬសារជាតិដែលបានបង្កគ្រោះថ្នាក់ ហើយត្រូវបញ្ចេញពីលំនៅឋាន អាគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកម្សាន្ត។ល។[១]
    - **សំណល់ប្រកបដោយគ្រោះថ្នាក់** គឺសំដៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុក ឆេះ បង្កឱ្យមានជម្ងឺមហារីក ធ្វើឱ្យរលាក ធ្វើឱ្យច្រេះ ធ្វើអុកស៊ីតកម្ម ឬសារធាតុគីមីផ្សេងៗទៀត ដែលអាចនាំឱ្យមាននូវគ្រោះថ្នាក់

[១] ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ ១១៣ អនក្រ.បក, ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥

មនុស្ស សត្វ ឬមានការបំផ្លាញទៅដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន។ សំណល់ប្រកបដោយគ្រោះថ្នាក់មានប្រភពពីលំនៅឋាន រោងចក្រឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និងសេវាកម្ម អាជីវកម្មផ្សេងៗ។[២]

- **សំណល់រាវ** គឺជាវត្ថុរាវ ដែលជាផលិតផល និងជាសារធាតុរួមផ្សំជាមួយនឹងសារធាតុរឹងខ្លះដែលត្រូវបានគេបញ្ចេញចោលជាប្រចាំទៅតាមបណ្ដាញប្រព័ន្ធលូទឹកស្អុយជាដើម។ អត្ថន័យមួយទៀត គឺសំដៅទៅលើវត្ថុរាវ ដែលបានបញ្ចេញពីប្រភពបំពុលចូលទៅក្នុងទឹកសាធារណៈ ឬក៏មានចូលទៅតាមបណ្ដាញលូសាធារណៈទោះបានធ្វើប្រព្រឹត្តកម្ម ឬមិនបានធ្វើប្រព្រឹត្តកម្មក៏ដោយ។[៣]
  - **ប្រភពបំពុល** គឺសំដៅលើទីតាំងអគារទាំងឡាយណាដែលរួមទាំងលំនៅឋាន និងអគាររដ្ឋបាលសាធារណៈ ទីបរិវេណ មធ្យោបាយដឹកជញ្ជូន និងតំបន់អាជីវកម្ម ឬសេវាកម្មដែលបញ្ចេញសំណល់រាវ សារធាតុពុល ឬសារធាតុដែលបង្កឱ្យមានគ្រោះថ្នាក់ដោយផ្ទាល់ក្ដី ឬមិនផ្ទាល់ក្ដី បានចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្ដាញលូសាធារណៈ។[៤]

### ១.១.២. ប្រភេទនៃសំណល់រឹង-រាវ

កាកសំណល់ គឺជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃរបស់មនុស្សគ្រប់ៗរូប។ តាមគេហដ្ឋាននីមួយៗដែលនៅក្នុងរាជធានីភ្នំពេញបានបង្កើតសំណល់ជាច្រើនដែលគួរឱ្យកត់សម្គាល់។ វាមានសារៈសំខាន់ណាស់ក្នុងការយល់ដឹងពីសមាសធាតុកាកសំណល់ និងបរិមាណកាកសំណល់ដែលយើងគ្រប់គ្នាបានបង្កើត ប្រសិនបើយើងគ្រប់គ្នាចង់បានប្រព័ន្ធគ្រប់គ្រងកាកសំណល់មួយដែលប្រកបដោយប្រសិទ្ធភាព។ ក្នុងនោះផងដែរប្រភេទនៃសំណល់រឹងមានដូចជា សំណល់រឹងបំពុល និងសំណល់រឹងប្រកបដោយគ្រោះថ្នាក់។

- **សំណល់រឹងបំពុល** ជាសំណល់ដែលអាចផ្លាស់ប្ដូរសមាសភាព ឬលក្ខណៈជីវសាស្ត្រ គីមី ឬលក្ខណៈរូបរបស់បរិស្ថានដែលគេបោះបង់ចោលដោយចៃដន្យ ឬដោយចេតនា។[៥]
- **សំណល់ប្រកបដោយគ្រោះថ្នាក់** សំណល់រឹងប្រកបដោយគ្រោះថ្នាក់មានដូចជា សារធាតុរំលាយប្រើក្នុងឧស្សាហកម្មគីមី ទឹកអាស៊ីតចាក់អាគុយ ផូស្វរ សំណល់មន្ទីរពេទ្យ ម្ជុលចាក់ថ្នាំ និងស្បៃរុំរបួស។[៦]ចំណែកង

---

[២] អនុក្រឹត្យ ស្ដីពីការគ្រប់គ្រងសំណល់រឹង, លេខ ៣៦ អនក្រ.បក, ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៩៩, មាត្រា២

[៣] អនុក្រឹត្យ ស្ដីពីការបំពុលទឹក, លេខ ២៧ អនក្រ.បក, ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩, មាត្រា៣

[៤] អនុក្រឹត្យ លេខ២៧ អនក្រ.បក, មាត្រា៤

[៥] គេហទំព័រ https://www.khsearch.com/qna/១១៣១២ ដកស្រង់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤

[៦] គេហទំព័រ https://www.khsearch.com/qna/៥៧៨៦ ដកស្រង់នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤

សំណល់នៅតាមលំនៅឋានក៏អាចមានសារធាតុប្រកបដោយគ្រោះថ្នាក់ដែរតែវាមានកម្រិតតិចតួច។ ចំពោះវិស័យកសិកម្ម ដោយសារបច្ចេកទេសរបស់យើងនៅមានកម្រិតទាបកសិករភាគច្រើនបានប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតដែលមានជាតិពុលខ្លាំង និងប្រើប្រាស់ជាតិគីមីដើម្បីបង្កើននូវទិន្នផលដំណាំ។ ដូច្នេះ សារធាតុប្រកបដោយគ្រោះថ្នាក់មួយចំនួនក៏បានបង្កើតឡើងដោយវិស័យនេះផងដែរ។[៧]

- **សំណល់រាវ** គឺសំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថាន ដែលបញ្ចេញពីសកម្មភាព ឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម។[៨] ឬម្យ៉ាងទៀតសំណល់រាវ គឺជាវត្ថុរាវដែលជាផលិតផល និងសារធាតុរួមផ្សំជាមួយនឹងសារធាតុរឹងខ្លះទៀតដែលត្រូវបានគេបញ្ចេញចោលជាប្រចាំទៅតាមបណ្ដាញប្រព័ន្ធលូទឹកស្អុយផ្សេងៗ។[៩]
  - **ប្រព័ន្ធលូ** សំដៅដល់បណ្ដាញប្រមូល និងបង្ហូរទឹកកខ្វក់រួមមាន តំណភ្ជាប់ អណ្ដូងលូ និងបណ្ដាញលូ (បណ្ដាញល្បួម បណ្ដាញលូដាច់ដោយឡែក បណ្ដាញល្បួម បណ្ដាញលូមេរង បណ្ដាញលូខ្នែង និងបណ្ដាញលូខ្នែងរង)។[១០]
  - **សំណល់ភក់** សំដៅដល់កាកសំណល់ពីអាងសិបទិច ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។[១១]

## ១.២. មូលហេតុបង្កឱ្យមានសំណល់រឹង-រាវ

បច្ចុប្បន្ន នៅទីក្រុងភ្នំពេញសំណល់ប្លាស្ទិកមានចំនួនជាង ២០% នៃសំណល់សរុបនៅក្នុងទីក្រុង (៣.៦០០ តោន) ក្នុងមួយថ្ងៃៗដែលនេះជាការដាក់សម្ពាធដ៏សម្បើមមកលើសេវាគ្រប់គ្រងសំណល់។ នៅតាមទីប្រជុំជន សំណល់ប្លាស្ទិកដែលត្រូវបានគេចោលខុសច្បាប់ បង្កឱ្យមានការកកស្ទះផ្លូវទឹក ប្រព័ន្ធលូនឹងប្រព័ន្ធបង្ហូរទឹក និងបង្កើនហានិភ័យទឹកជំនន់។ នៅតំបន់ដែលពុំមានសេវាប្រមូលសំណល់ជារឿយៗសំណល់ប្លាស្ទិកត្រូវបានគេដុតនៅទីចំហ ឬចោលនៅកន្លែងចោលសំរាមមិនមានការគ្រប់គ្រងទុកចោលតាមផ្លូវ ឬចោលទៅក្នុងប្រព័ន្ធផ្លូវទឹក។ ការដុតសំណល់ប្លាស្ទិកមិនមានលក្ខណៈបច្ចេកទេសត្រឹមត្រូវនាំឱ្យមានការបំភាយសារធាតុគីមីគ្រោះថ្នាក់ ឬសារធាតុពុលដែលបង្កហានិភ័យធ្ងន់ធ្ងរដល់សុខភាពសាធារណៈព្រមទាំងធ្វើឱ្យមានកំណើនកម្ដៅផែនដីផងដែរ។ កំណើនបរិមាណសំណល់ប្លាស្ទិកដ៏ច្រើនបែបនេះព្រមទាំងបញ្ហាប្រឈមដែលបង្កឡើង

[៧] គេហទំព័រ https://seylanote.wordpress.com/?s= សំណល់រាវ ដកស្រង់នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤

[៨] អនុក្រឹត្យ ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់, លេខ ២៣៥ អនក្រ.បក, ចុះថ្ងៃទី២៥ ធ្នូ ២០១៧, មាត្រា៤

[៩] គេហទំព័រ https://seylanote.wordpress.com/?s= សំណល់រាវ ដកស្រង់នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៤

[១០] អនុក្រឹត្យលេខ ២៣៥ អនក្រ.បក, មាត្រា៤

[១១] អនុក្រឹត្យលេខ ២៣៥ អនក្រ.បក, មាត្រា៤

ដោយសារសំណល់ប្លាស្ទិកមិនមែនជាបញ្ហាដែលកើតមានតែចំពោះព្រះរាជាណាចក្រកម្ពុជានោះឡើយតាមពិត គេសង្កេតឃើញមានស្ថានភាពស្រដៀងគ្នានេះនៅតាមប្រទេសផ្សេងៗទៀតនឹងនៅអាស៊ីផងដែរ។ នៅតាមប្រទេសទាំងនោះ មានប្រជាពលរដ្ឋ និងអាជីវកម្មជាច្រើនចោលសំណល់ប្លាស្ទិកនៅជិត ឬទៅក្នុងប្រព័ន្ធផ្លូវទឹក ដោយអ្នកទាំងនោះប្រហែលជាមិនដឹងពីផលប៉ះពាល់ និងបញ្ហានៃសំណល់ទាំងនេះមកដល់បរិស្ថានរួមទាំងសោភ័ណភាព និងខ្សែចង្វាក់ចំណីអាហាររាប់បញ្ចូលទាំងខ្លួនយើងទាំងអស់គ្នាផងដែរ។[១២]

### ១.២.១. មូលហេតុនៃសំណល់រឹង

សព្វថ្ងៃកំណើនចំនួនប្រជាជនកើនឡើងយ៉ាងខ្លាំងនៅលើសកលលោកតម្រូវការជីវភាពរស់នៅមានការកើនឡើងនឹងសម្បូរបែបការរីកដុះដាលនៃនគរូបនីយកម្ម និងសំណង់ការរីកចម្រើនខាងវិស័យឧស្សាហកម្ម និងកសិកម្មដែលជាដើមហេតុនាំឱ្យមានកាកសំណល់ជាច្រើនសន្ធឹកសន្ធាប់ជាពិសេសប្រទេសដែលកំពុងតែអភិវឌ្ឍន៍។ កាកសំណល់រឹងមានប្រភពមកពីច្រើនកន្លែងតែយើងលើកឡើងតែប្រភពធំៗដូចខាងក្រោម៖

- **សំណល់លំនៅឋាន**

ភាគច្រើនជាប្រភេទសំណល់ចេញពីផ្ទះបាយ ដែលជាប្រភេទសរីរាង្គងាយពុករលួយដែលអាចយកទៅធ្វើជាជីកំប៉ុសបានដូចជាបន្លែ សំណល់ផ្លែឈើ សំណល់ម្ហូបអាហារ ប្លាស្ទិក ក្រដាស ដែក ក្រណាត់ និងសម្ភារដែលផេចខូប៉។ល។ សំណល់លំនៅឋានក៏មានប្រភេទប្រកបដោយគ្រោះថ្នាក់ផងដែរ មានសំណល់ថ្មពិលអាគុយ អំពូលភ្លើង ម៉ាស៊ីនត្រជាក់ដែលខូចលែងប្រើកើត។[១៣] សំណល់ផ្ទះបាយភាគច្រើនជាសំណល់សើមដូចជា បាយ ត្រី សាច់ បន្លែ ផ្លែឈើ និងសំណល់ផ្សេងៗដែលទទ្រង់គ្រឿងឧបភោគបរិភោគ។ សំណល់នេះមានប្រភពមកពីភោជនីយដ្ឋាន លំនៅឋាន អាហារដ្ឋាន តំបន់ទេសចរណ៍ បៀរហ្គាឌិនជាដើម។ កាកសំណល់ផ្ទះបាយដែលជាកាកសំណល់មានក្លិនស្អុយហើយអាចបំបែកភាគល្អិតសរីរាង្គលឿន។ កាកសំណល់តាមផ្ទះជាផ្នែកមួយនៃសំណល់រឹង ដែលភាគច្រើនកើតចេញពីផ្ទះឯកជន លំនៅឋាន អគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អគារពាណិជ្ជកម្ម ភោជនីយដ្ឋាន កន្លែងកម្សាន្ត។ល។[១៤]

- **សំណល់រោងចក្រ និងសិប្បកម្ម**

---

[១២] គេហទំព័រ ការគ្រប់គ្រងសំណល់រឹង https://United Nations Development Programme (undp.org) ដកស្រង់នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៤

[១៣] គេហទំព័រ https://seylanote.wordpress.com/២០១២/០៧/១២/ ការគ្រប់គ្រងសំណល់រឹង ដកស្រង់នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៤

[១៤] គោលការណ៍ណែនាំបរិស្ថាន ស្ដីពីការគ្រប់គ្រងសំណល់រឹងនៅព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១ កុម្ភៈ ២០០៦, ទំព័រទី៣

សំណល់ចេញពីរោងចក្រ និងសិប្បកម្ម ជាសំណល់ដែលសល់ពីផលិតកម្មហើយភាគច្រើនជាសំណល់ប្រកបដោយគ្រោះថ្នាក់ មានដូចជា សរសៃអំបោះ កម្ទេចក្រណាត់ សំណល់ដែលសល់ពីការឆេះមិនអស់នៅក្នុងឡឧស្សាហកម្ម។ ដោយសារតែឧស្សាហកម្ម ជាកន្លែងដែលបញ្ចេញថាមពលច្រើន និងមានផ្ទុកសារធាតុគីមី ការបំពុលដោយសំណល់អាចបង្កគ្រោះថ្នាក់ដល់សតិបញ្ញារបស់កុមារ និងធ្វើឱ្យមានការលូតលាស់យឺតយ៉ាវជាងធម្មតា។

❖ **មន្ទីរពេទ្យ**

សំណល់ដែលចេញពីមន្ទីរពេទ្យ ជាសំណល់ស្ងួត ដូចជាសម្ភាររុំរបួស ស៊ីរ៉ែន អាលុយមីញ៉ូម បរិក្ខាពេទ្យផ្សេងៗទៀតសំណល់ប្រភេទនេះមិនសូវមានគ្រោះថ្នាក់ប៉ុន្តែផ្ទុកទៅដោយមេរោគជាច្រើនប្រភេទ។ ប្រភពដែលនាំឱ្យមានសំណល់មន្ទីរពេទ្យមានដូចជាៈ

- **សំណល់ដែលបង្កឱ្យមានការឆ្លង** ជាប្រភពដែលមានភ្នាក់ងារចម្លងជម្ងឺ ដូចជាសំណល់សម្ភារចេញពីមន្ទីរពិសោធន៍ បណ្តុះមេរោគ សំណល់ជាលិកាតាមផ្នែកផ្សេងៗនៃសម្ភារ ឬជាឧបករណ៍ធ្លាប់បានប៉ះពាល់ផ្ទាល់ជាមួយនឹងសំណល់របស់អ្នកជម្ងឺមានមេរោគឆ្លង។
- **សំណល់រោគសាស្ត្រ** ជាលិកាមនុស្ស ឬវត្ថុ។ **ឧទាហរណ៍** បំបែកសារពាង្គកាយ ឈាម និងទឹករំអិលផ្សេងៗទៀត( ទឹកភ្លោះ )។
- **សំណល់ដែលបង្កឱ្យមានការមុត(របួសស្នាម)** ម្ជុល ប្រដាប់សម្រាប់ឆុងទឹក កាំបិតវះកាត់ ឡាមផ្លែកាំបិត អំបែង និងដប។
- **សំណល់ឱសថ** សំណល់ដែលមានឱសថ។ **ឧទាហរណ៍** ឱសថហួសកាលបរិច្ឆេទ ឬឈប់ប្រើប្រាស់វត្ថុសម្រាប់ដាក់ឱសថ ដូចជាដប ប្រអប់របស់វាជាដើម។
- **សំណល់ពុលសែន** សំណល់ដែលមានសារធាតុបំពុលសែន។ **ឧទាហរណ៍** សំណល់ជាតិថ្នាំពុលកោសិកា(ដែលប្រើប្រាស់ក្នុងការព្យាបាលជម្ងឺមហារីក) និងសារធាតុវិទ្យុសកម្ម។
- **សំណល់សារធាតុគីមី** សំណល់ដែលមានសារធាតុគីមី។ **ឧទាហរណ៍** ប្រតិករប្រើប្រាស់ក្នុងមន្ទីរពិសោធន៍ សារធាតុគីមី សារធាតុដែលប្រើសម្រាប់សម្លាប់មេរោគដែលហួសកាលបរិច្ឆេទ ឬឈប់ប្រើ និងសារធាតុរលាយ។
- **សំណល់លោហៈ** ថ្មពិល អាគុយ ឧបករណ៍វាស់កម្តៅដែលបានបែកបាក់ ឬប្រដាប់វាស់សម្ពាធឈាម។

➢ **សំណល់វិទ្យុសកម្ម** សំណល់ដែលមានសារធាតុវិទ្យុសកម្ម ដូចជាសារធាតុរាវចេញពីការព្យាបាលដោយប្រើកាំរស្មី ឬការស្រាវជ្រាវក្នុងមន្ទីរពិសោធន៍ ប្រដាប់ការពារកាំរស្មី ទឹកនោម ឬឈាមក្នុងជម្ងឺព្យាបាលកាំរស្មី។[១៥]

❖ **អគារពាណិជ្ជកម្ម**

ភាគច្រើនជាការិយាល័យតំណាងក្រុមហ៊ុនផ្សេងៗ សំណល់ទាំងនោះហើយជាសំណល់ស្ងួត និងមិនមានគ្រោះថ្នាក់ ឬផ្ទុកមេរោគឡើយដូចជា ក្រដាស សម្ភារការិយាល័យ ឧបករណ៍អេឡិចត្រូនិកជាដើម។ សំណល់ពាណិជ្ជកម្ម ជាប្រភេទសំណល់ចេញពីទីផ្សារទំនិញ សណ្ឋាគារ រង្គសាល ភោជនីយដ្ឋានជាដើម ហើយភាគច្រើនប្រភេទនៃសំណល់នេះជាប្រភេទពុំមានគ្រោះថ្នាក់ដូចទៅនឹងប្រភេទសំណល់លំនៅឋានដែរ។ ចំពោះប្រភេទដែលគ្រោះថ្នាក់មានដូចជា សម្ភារដែលសេសសល់ពីការវេចខ្ចប់ ថ្នាំសម្លាប់សត្វល្អិត សំណល់សម្ភារជជុះ(ថ្មពិល ទូរទស្សន៍ វិទ្យុ ម៉ាញ៉េ គ្រឿងបន្លាស់អេឡិចត្រូនិក) ម៉ាស៊ីនត្រជាក់ ទូរទឹកកក និងសំណល់កង់ឡានចាស់ៗ។ល។

❖ **សំណល់ពីសំណង់**

ប្រទេសកំពុងអភិវឌ្ឍ កំពុងតែប្រឈមជាខ្លាំងចំពោះសំណង់ប្រភេទនេះព្រោះវាមានការរីកដុះដាលនៃសំណង់ជាច្រើនពីមួយថ្ងៃទៅមួយថ្ងៃ។ **ឧទាហរណ៍** នៅក្នុងប្រទេសកម្ពុជាមានសំណង់ដែលកំពុងរីកដុះដាលគ្រប់ទីកន្លែងជាពិសេសរាជធានីភ្នំពេញ ទង្វើទាំងនេះវាអាចបង្កឱ្យមានការហុយដី សម្លេងរំខាន និងការកកស្ទះចរាចរណ៍ជាដើម។ សំណង់នេះមានដូចជា ដែក ស៊ីម៉ង់ ថង់ប្លាស្ទិក ថ្នាំលាបពណ៌ជាដើម។

### ១.២.២. មូលហេតុនៃសំណល់រាវ

សំណល់រាវ គឺជាវត្ថុដែលជាផលិតផលនឹងសារធាតុរួមផ្សំជាមួយនឹងសារធាតុរឹងខ្លះដែលត្រូវបានគេបញ្ចេញចោលជាប្រចាំទៅតាមបណ្ដាញលូទឹកស្អុយផ្សេងៗ។[១៦] ម្យ៉ាងវិញទៀត សំណល់រាវសំដៅដល់ទឹកសំណល់ដែលមានសារធាតុបំពុលបរិស្ថានដែលបញ្ចេញពីសកម្មភាព ឬដំណើរការផ្ទាល់នៃការផលិតកម្ម ឬសេវាកម្ម។[១៧] នៅក្នុងនោះផងដែរ ក្រសួងបរិស្ថានបានពិនិត្យឃើញថាមានរោងចក្រមួយចំនួន ជាពិសេស គឺរោងចក្រវាយនភ័ណ្ឌជ្រលក់ពណ៌ រោងចក្របោកគក់ ឬបោះពុម្ព និងរោងចក្រកែច្នៃផលិតផលកសិ-ឧស្សាហកម្ម បានបញ្ចេញសំណល់រាវរបស់ខ្លួនដោយមិនបានធ្វើប្រព្រឹត្តកម្មសម្អាត ឬអាងប្រព្រឹត្តកម្មខ្លះមិនបានដំណើរការឱ្យ

[១៥] គេហទំព័រ ការគ្រប់គ្រងសំណល់រឹង | កំណត់ត្រាសិលា (wordpress.com) ដកស្រង់នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៤

[១៦] គេហទំព័រ https://seylanote.wordpress.com/? ដកស្រង់នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៤

[១៧] អនុក្រឹត្យលេខ ២៣៥ អនក្រ.បក, មាត្រា៤

ជាប់លាប់ និងអាងប្រព្រឹត្តកម្មខ្លះទៀតមិនមានសមត្ថភាពឆ្លើយតបទៅនឹងបរិមាណសំណល់រាវដែលបានបង្កើត ដែលជាហេតុបង្កឱ្យមានការបំពុលដោយផ្ទាល់ ឬដោយប្រយោលទៅដល់គុណភាពទឹក ដី និងជាផលប៉ះពាល់ទៅដល់សុខភាពរបស់ប្រជាពលរដ្ឋដែលរស់នៅជុំវិញប្រភពបំពុល។[១៨] សំណល់រាវនេះត្រូវបានបែងចែកចេញជាពីរប្រភេទ គឺប្រភពបំពុលរាយប៉ាយ និងប្រភពបំពុលចំណុច។

- **ប្រភពបំពុលរាយប៉ាយ** គឺជាប្រភពដែលបង្កឱ្យមានការបំពុលដោយសារ សារធាតុបំពុលពីដីច្រើនកន្លែងដូចជា លំហូរកសិកម្ម សំណល់ចេញពីលំនៅឋាន សំណល់អាជីវកម្មរ៉ែ និងកំទេចកំទីពីការដ្ឋានសំណង់ជាដើម ហើយសំណល់ទាំងនេះហូរធ្លាក់ចូលទៅក្នុងទឹកលើផ្ទៃដីនៃតំបន់ដ៏ធំមួយ ហើយមិនងាយស្រួលក្នុងការត្រួតពិនិត្យវាអាស្រ័យទៅលើការយល់ដឹងរបស់បុគ្គល គ្រួសារ រួមទាំងសហគមន៍។
- **ប្រភពបំពុលចំណុច** គឺជាប្រភពដែលចេញពីកន្លែងច្បាស់លាស់តាមរយៈបំពង់បង្ហូរ ឬតាមប្រឡាយទីតាំងឧស្សាហកម្ម រោងចក្រនឹងបំពង់បង្ហូរទឹកលូសំអុយហើយងាយស្រួលក្នុងការត្រួតពិនិត្យ និងធ្វើប្រត្តិកម្មសំអាតទឹកឡើងវិញ។[១៩]

## ១.៣. គុណវិបត្តិនៃសំណល់រឹង-រាវ

បច្ចុប្បន្ន សំរាមសំណល់រឹងទីប្រជុំជនដែលត្រូវបានបញ្ចេញពីគេហដ្ឋាន មជ្ឈមណ្ឌលពាណិជ្ជកម្ម រោងចក្រ សហគ្រាស សិប្បកម្ម និងមន្ទីរពេទ្យ។ល។ ពុំទាន់ត្រូវបានញែក វេចខ្ចប់ និងទុកដាក់ឱ្យបានត្រឹមត្រូវតាមក្រឹត្យក្រមនឹងស្តង់ដារអនាម័យបរិស្ថានដែលជាហេតុបង្កផលប៉ះពាល់ដល់សុខភាពសាធារណៈ បរិស្ថាន និងសោភ័ណភាពរបស់ទីប្រជុំជនទាំងមូល។ ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលកំពុងមានសកម្មភាពនៅតាមរាជធានី ក្រុង និងស្រុកត្រូវបានរៀបចំយ៉ាងសាមញ្ញបំផុតដោយមិនទាន់មានការត្រួតពិនិត្យការបំពុល ឬប្រព័ន្ធការពារឡើយនឹងពុំទាន់អនុលោមតាមនិយាមស្តង់ដារនៃប្រទេសជឿនលឿននៅឡើយ។ ម៉្យាងវិញទៀត ធនធានដែលអាចយកមកប្រើប្រាស់បាន និងកែច្នៃដែលមិនទាន់ត្រូវបានទាញប្រមូលយកឱ្យអស់សក្តានុពល ហើយផ្ទុយទៅវិញបានដាក់សម្ពាធកាន់តែធ្ងន់ក្នុងការចំណាយយកទៅចាក់ក្នុងទីលាន។ ការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជននៅតែជាបញ្ហាប្រឈមធំនៅក្នុងតំបន់ទីក្រុងទូទាំងពិភពលោក ជាពិសេសនៅក្នុងរាជធានី ក្រុង និងស្រុកដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស។ កង្វះខាតនូវប្រព័ន្ធគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនប្រកបដោយប្រសិទ្ធភាព និងនិរន្តភាពបានបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំង

[១៨] គេហទំព័រ https://www.moe.gov.kh/wp-content/uploads/២០១៦/០៩/moe-pdf.pdf ដកស្រង់នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤

[១៩] គេហទំព័រ https://www.khsearch.com/qna/៨៨៧៤ ដកស្រង់នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤

ដល់គុណភាពបរិស្ថានហើយក៏ជាកត្តាកំណត់ដោយផ្ទាល់ទៅលើឥរិយាបថ ទម្លាប់ របៀបរបបរស់នៅ និងការធ្វើអាជីវកម្មផលិតកម្មរបស់អ្នកបង្កើត និងបញ្ចេញសំរាម សំណល់រឹងទីប្រជុំជន។ បញ្ហាប្រឈមចម្បងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន គឺកំណើនយ៉ាងឆាប់រហ័សទាំងបរិមាណនឹងសមាសភាគនៃសំរាមសំណល់រឹងទីប្រជុំជន កង្វះហេដ្ឋារចនាសម្ព័ន្ធ ការគ្រប់គ្រង យន្តការហិរញ្ញប្បទាន គោលនយោបាយ ព្រមទាំងការចូលរួមរបស់គ្រប់តួអង្គពាក់ព័ន្ធនៅមានកម្រិត។

### ១.៣.១. ផលប៉ះពាល់សំណល់រឹង-រាវ

ការគ្រប់គ្រងសំរាម ឬសំណល់នៅប្រទេសកម្ពុជាហាក់ដូចជាមានផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន និងសុខភាពមនុស្ស។ បើទោះបីជា នៅក្នុងប្រទេសកម្ពុជាហាក់ដូចជា មិនមានការសិក្សាស្រាវជ្រាវជាក់លាក់ណាមួយ ស្ដីពីផលប៉ះពាល់នៃការគ្រប់គ្រងសំរាម ឬសំណល់រឹង-រាវក៏ដោយ ជាទូទៅ គេសង្កេតឃើញថា ការចោលសំរាមនៅទីសាធារណៈ ការដុតសំរាម និងការចោលសំរាមនៅទីលានចាក់សំរាមនានា ដែលមិនមានការរចនាត្រឹមត្រូវនឹងមានផលប៉ះពាល់ជាអវិជ្ជមានទៅលើបរិស្ថាន និងសុខភាពមនុស្ស។ សំរាម មិនត្រឹមតែធ្វើឱ្យមានផលប៉ះពាល់ទៅដល់បរិស្ថាន សោភ័ណភាពនឹងបង្កឱ្យអាប់អួរដល់បរិយាកាសជុំវិញនោះទេ តែវាថែមទាំងបណ្ដាលឱ្យមានជម្ងឺផ្សេងៗទៀតបាន និងបង្កឱ្យមានគ្រោះថ្នាក់យ៉ាងខ្លាំងចំពោះសុខភាពមនុស្សតាមរយៈការប៉ះពាល់ដោយផ្ទាល់ ឬតាមរយៈការភាយក្លិនស្អុយនៃសំរាមដែលរលួយផងដែរ។ ការបញ្ចេញសំណល់ មានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងកំណើនប្រជាជន ដែលនាំឱ្យមានការព្រួយបារម្ភចំពោះផ្នែកបរិស្ថាន និងសុខភាពមនុស្ស សត្វ សោភ័ណភាព និងបរិស្ថានជុំវិញផងដែរ។ ដោយសារតែកង្វះខាតនៃការអនុវត្ត ការគ្រប់គ្រងសំណល់ឱ្យបានត្រឹមត្រូវ និងការយល់ដឹងជាសាធារណៈនៅមានកម្រិត បញ្ហាសំណល់នៅតែជាសម្ពាធមួយដ៏ធំសម្រាប់ប្រទេសជាតិដែលកំពុងអភិវឌ្ឍដូចជាប្រទេសកម្ពុជាជាដើម។

#### ១.៣.១.១. ផលប៉ះពាល់សំណល់រឹង-រាវចំពោះសុខភាពសាធារណៈ

សុខភាពសាធារណៈ ជាកត្តាទី១ ក្នុងការអភិវឌ្ឍធនធានមនុស្ស ក៏ដូចជាអភិវឌ្ឍន៍សង្គមជាតិ។ សំណល់រឹងមានផលប៉ះពាល់ដល់សុខភាពសាធារណៈដូចជា៖

- **មេរោគនៅក្នុងសំរាម** នៅក្នុងសំរាមមានផ្ទុកទៅដោយមេរោគច្រើនប្រភេទ។ នៅពេលវាឆ្លងមកដល់ក្នុងខ្លួនមនុស្ស វាបង្កឱ្យកើតមានជម្ងឺរាករូស ជម្ងឺរាកមូល អាសន្នរោគ គ្រុនពោះវៀន និងជម្ងឺជាច្រើនផ្សេងទៀត។ ប្រសិនបើមិនបានធ្វើអនាម័យជាប្រចាំទេ ជម្ងឺទាំងនោះនឹងអាចក្លាយទៅជាប្រភេទជម្ងឺរ៉ាំរ៉ៃបាន។ ម្យ៉ាងវិញទៀតសារធាតុមុតស្រួចដែលមាននៅក្នុងសំរាមក៏អាចបង្កជារបួសស្នាមរហូតក្លាយទៅជាដំបៅរ៉ាំរ៉ៃបានផងដែរ។

- **សារធាតុគីមីនៅក្នុងសំរាម** សំរាម មានផ្ទុកទៅដោយសារធាតុគីមីមួយចំនួនដែលអាចបង្កឱ្យកើតជម្ងឺមហារីកបាន។ ម្យ៉ាងវិញទៀតវាក៏អាចធ្វើឱ្យមានអុកស៊ីដកម្មលើសារធាតុគីមីដទៃទៀតដែលអាចនាំគ្រោះថ្នាក់ ដល់ មនុស្ស រុក្ខជាតិ និងសត្វដែលមាននៅក្នុងបរិស្ថានទៀតផង។[២០]
- **ប៉ះពាល់ដល់ផ្លូវដង្ហើម** ការទុកដាក់ និងការវិចខ្ចប់សំរាមមិនល្អធ្វើឱ្យមានក្លិនស្អុយសាយភាយ និងសំរាមហើរទៅជាធូលីហើយទៅជាខ្យល់បំពុលទៀតដែលអាចនាំឱ្យមានបញ្ហាផ្លូវដង្ហើម។
- **កើតជម្ងឺស្បែក** មេរោគដែលបង្កមកពីសំរាមដែលមាននៅគ្រប់ទីកន្លែង ឬបរិយាកាសហើយហើរទៅប៉ះនឹងស្បែក ជាទូទៅវានឹងបង្កឱ្យកើតជម្ងឺរមាស់ ពងបែក អាលែកហ្ស៊ីស្បែកជាដើម។
- **ជម្ងឺភ្នែកក្រហម** ធូលីដី និងមេរោគក្នុងបរិយាកាសដែលមាននៅគ្រប់ទីកន្លែងហើយហោះចូលកែវភ្នែករបស់យើង វាអាចធ្វើឱ្យភ្នែករបស់យើងឡើងក្រហម ឬផ្សាភ្នែកជាដើម។
- **ការប៉ះពាល់ចំពោះអ្នករើសអេតចាយ** ដោយការគ្រប់គ្រងទីលានមានភាពខ្វះខាតនឹងពុំមានវិធានការគ្រប់គ្រាន់ដើម្បីទប់ស្កាត់គ្រោះថ្នាក់ក៏ដូចជាប៉ះពាល់ដល់សុខភាពអ្នករើសអេតចាយ ឬអ្នកក្រីក្ររស់នៅជុំវិញទីលានចាក់សំណល់រឹង វាអាចបង្កគ្រោះថ្នាក់ផ្សេងៗដូចជា៖
  - ជម្ងឺឆ្លងនានា (បាក់តេរី ឬវីរុសដែលបង្កឱ្យមានជម្ងឺជីវសាស្ត្រ ដូចជាប៉ារ៉ាសិតនឹងបាក់តេរីទាក់ទងនឹងជម្ងឺពោះវៀន ក្រពះ)
  - ជម្ងឺផ្លូវដង្ហើមបង្កដោយធូលី
  - ការរងរបួសនៅទីលាន នៅពេលឡានចូលចាក់ម្តងៗដោយសារការដណ្តើមគ្នារើសសំរាម និងគ្រោះថ្នាក់តាមរយៈការមុត ឬប៉ះពាល់សំណល់ដោយផ្ទាល់ដោយសំណល់ទាំងនោះមានសំណល់ប្រភេទប្រកបដោយគ្រោះថ្នាក់ពុំបានញែកចេញត្រឹមត្រូវលាយឡំគ្នា។
  - ការយល់ដឹងជាសាធារណៈចំពោះអនាម័យ និងសុខភាពរបស់អ្នករើសអេតចាយនៅមានកម្រិតនឹងយល់ដឹងទាបដែលនាំឱ្យប៉ះពាល់ដល់សុខភាព ដោយអ្នកទាំងនោះមិនបានការពារខ្លួនទៅផលប៉ះពាល់ឡើយ។ ភាគច្រើននៃអ្នករើសសំរាមត្រូវបានគេដឹង និងបានបញ្ជាក់ថាមានអាការៈរោគបណ្តាលឱ្យឈឺ។ ជម្ងឺផ្តាសាយ និងជម្ងឺក្អកត្រូវបានគេដឹងថាជាទូទៅមានលក្ខណៈដូចជាជម្ងឺរបេងហើយក៏មានបញ្ហាកើតឡើងចំពោះអ្នករើសអេតចាយជាច្រើនផងដែរ។

[២០] គេហទំព័រ https://seylanote.wordpress.com/២០១២/០៦/២៩/ ផលប៉ះពាល់ និងការគ្រប់គ្រងសំរាម ដកស្រង់នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤

គ្រោះថ្នាក់ចំពោះអ្នករស់នៅ ឬសត្វស្រុកដែលរស់នៅជុំវិញទីលានចាក់សំណល់ ដោយមានបញ្ហាផ្នែកថវិការួមបញ្ចូលមធ្យោបាយក្នុងការវិភាគក្រសួងបរិស្ថានក៏ដូចជាស្ថាប័នពាក់ព័ន្ធពុំបានធ្វើការសិក្សាស្រាវជ្រាវពីភាពប៉ះពាល់លើសុខភាពមនុស្ស និងសត្វឡើយ។ តាមការប៉ាន់ស្មានប្រមាណមនុស្ស ឬសត្វដែលរស់នៅជុំវិញទីលានចាក់សំណល់ដែលមិនបានរៀបចំបច្ចេកទេសត្រឹមត្រូវ អាចបង្កគ្រោះថ្នាក់ដល់សុខភាពដូចជា៖

- ពពួកភ្នាក់ងារចម្លងមេរោគ ដូចជារុយ សត្វល្អិត ឬកណ្ដុរ
- សត្វពាហនៈមួយចំនួនដូចជាឆ្កែ មាន់ ទា ជ្រូក ឬឆ្មា ដែលសត្វទាំងអស់នេះអ្នករើសអេតចាយជាអ្នកចិញ្ចឹមនៅឯទីលានចាក់សំណល់
- ការប្រើប្រាស់ទឹកក្រោមដី ដោយរួមបញ្ចូលអណ្តូងចំហ អណ្តូងស្នប់ ដែលបានធ្វើឱ្យកខ្វក់ ឬមានសារធាតុបំពុលធ្លាក់ចូល
- ក្លិនស្អុយ និងគួរឱ្យខ្ពើមរអើម។

ការស្រូបខ្យល់ដកដង្ហើមដោយខ្យល់ពុលចេញពីការដុតសំណល់ដែលមាន $SO_2$(ស៊ុលផួឌីអុកស៊ីត), $CO_2$ (កាបូនឌីអុកស៊ីត), $NO_2$ (នីត្រាតឌីអុកស៊ីត), និងអាចមានការលេចចេញទៅដោយអុកស៊ីតឌីអុកស៊ីនផងដែរ។[២១] ចំណែកឯសំណល់រាវ វិញមានផលប៉ះពាល់មួយចំនួនចំពោះសុខភាពដូចជា៖

- ➢ ***សារធាតុពុលនៅក្នុងសំណល់រាវ*** សារធាតុពុលមួយចំនួនដែលនៅក្នុងសំណល់រាវអាចធ្វើឱ្យមានការប៉ះពាល់ដល់ស្បែកដែលបណ្តាលឱ្យមនុស្សកើតមានជម្ងឺដូចជា សើស្បែក រលាកស្បែក ជម្ងឺរលាកផ្លូវរំលាយអាហារ ជម្ងឺផ្លូវដង្ហើម និងរលាកសួតជាដើម។ ជួនកាលវាអាចបណ្តាលឱ្យមានផលប៉ះពាល់ដល់ប្រព័ន្ធប្រសាទថែមទៀតផងដោយសារតែការសាយភាយក្លិននឹងការចម្លងរោគពីសំណល់រាវ។
- ➢ **មេរោគនៅក្នុងសំណល់រាវ** នៅក្នុងសំណល់រាវមានផ្ទុកទៅដោយមេរោគជាច្រើនប្រភេទ។ នៅពេលវាឆ្លងទៅក្នុងខ្លួនមនុស្សវាអាចនឹងបង្កឱ្យកើតមានជម្ងឺរាករូស ជម្ងឺរាកមួល អាសន្នរោគ គ្រុនពោះវៀន និងជម្ងឺជាច្រើនទៀត។ ហើយប្រសិនជាយើងមិនបានធ្វើអនាម័យជាប្រចាំនោះទេ ជម្ងឺទាំងនោះនឹងអាចក្លាយទៅជាជម្ងឺរ៉ាំរ៉ៃបាន។
- ➢ ***សារធាតុគីមីក្នុងសំណល់រាវ*** នៅក្នុងសំណល់រាវ មានផ្ទុកទៅដោយសារធាតុមួយចំនួនដែលអាចបង្កឱ្យកើតមានជម្ងឺមហារីកបាន។ ម្យ៉ាងវិញទៀត វាក៏អាចធ្វើឱ្យមានអុកស៊ីតកម្មលើសារធាតុគីមីដទៃទៀត

[២១] គេហទំព័រ ការគ្រប់គ្រងសំណល់រឹង | កំណត់ត្រាសិលា (wordpress.com) ដកស្រង់នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៤

ដែលអាចនាំឱ្យកើតមានគ្រោះថ្នាក់ផ្សេងៗដល់មនុស្ស សត្វ រុក្ខជាតិ ដែលមាននៅក្នុងបរិស្ថានថែមទៀតផង។

**១.៣.១.២. ផលប៉ះពាល់សំណល់រឹង-រាវចំពោះបរិស្ថាន**

នៅពេលដែលកាកសំណល់សរីរាង្គកកកុញក្នុងបរិមាណច្រើននឹងតាមរបៀបដែលមិនសមរម្យវាបានចាប់ផ្តើមរលួយបង្កើតឧស្ម័នដែលបង្កគ្រោះថ្នាក់ដល់សុខភាព។ នៅក្នុងចំណោមទាំងនេះមានកាបូនឌីអុកស៊ីត និងមេតានដែលជាឧស្ម័នផ្ទះកញ្ចក់។ ម៉្យាងទៀតមេតាន គឺងាយឆេះខ្លាំងហើយអាចចាប់ផ្តើមឆេះដែលដុតកាកសំណល់ប្លាស្ទិក។ សំណល់ទាំងនេះនៅពេលដុតបង្កើតឧស្ម័នពុលដែលបង្កឱ្យមានជម្ងឺផ្លូវដង្ហើមផ្សេងៗដល់ប្រភេទមហារីកមួយចំនួន។ បញ្ហាធ្ងន់ធ្ងរមួយទៀតជាមួយនឹងការបំពុលសំរាម គឺវាបន្ថយគុណភាពប្រភពទឹក។ ការដាក់បញ្ចូលលោហធាតុធ្ងន់សាប៊ូបោកខោអាវឌីអុកស៊ីតប្រេង និងសារធាតុពុលផ្សេងទៀតប៉ះពាល់ដល់សក្តានុពល  និងអត្ថប្រយោជន៍របស់វាសម្រាប់ប្រព័ន្ធធារាសាស្ត្រ។ ក្នុងករណីខ្លះកំហាប់អុកស៊ីសែនរលាយអាចផ្លាស់ប្តូរដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រព័ន្ធអេកូឡូស៊ីក្នុងទឹក។ ដូចគ្នានេះផងដែរនៅពេលដែលសំរាមរលួយវាបញ្ចេញសារធាតុដែលត្រូវបានបង្ហូរដល់កំរិតទឹកក្រោមដីការបំពុលទឹកក្រោមដី។ បើយោងតាមលក្ខណៈរូប និងលក្ខណៈគីមីនៃសំណល់រឹងប្រសិនបើយើងមិនបានធ្វើការគ្រប់គ្រងឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសទេនោះវាអាចនឹងជះឥទ្ធិពលមកលើសុខភាពមនុស្ស សត្វ និងបរិស្ថាន។

បរិស្ថានជាជីវិតរបស់មនុស្សលោក សត្វ និងរុក្ខជាតិដែលមានជីវិតនៅលើពិភពលោកហើយបរិស្ថានមានទំនាក់ទំនងជាមួយនឹងការទុកដាក់នឹងការវិចខ្ចប់សំណល់រឹង ជាពិសេសសំរាម។ ការគ្រប់គ្រងសំរាមមិនល្អនឹងបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថានដូចជា បង្កឱ្យមានសំរាមនៅតាមដងផ្លូវសាធារណៈមានក្លិនមិនល្អហើយខូចគុណភាពដីនឹងទឹកដែលមនុស្សគ្រប់រូបប្រើប្រាស់ជាប្រចាំ និងស្មះលូជាដើម។

- សំណល់រឹងអាចធ្វើឱ្យបាត់បង់សោភ័ណភាពទីក្រុង និងលំនៅឋានរបស់ប្រជាពលរដ្ឋ
- ជាប្រភព និងទីជម្រកនៃពពួកមេរោគឆ្លងព្រមទាំងសត្វល្អិតចង្រៃជាច្រើន
- សំណល់រឹងមួយចំនួនដែលមិនបានទុកដាក់ត្រឹមត្រូវបានបំបែកធាតុ (រលួយ) បង្កឱ្យមានក្លិនស្អុយដែលប៉ះពាល់ដល់អ្នករស់នៅក្បែរនឹងបរិស្ថានជុំវិញ។
- សំណល់ប្រកបដោយគ្រោះថ្នាក់ដែលមានផ្ទុកទៅដោយសារធាតុពុល អាចជះឥទ្ធិពលអាក្រក់ទៅដល់សុខភាពប្រជាជនដូចជា ប៉ះពាល់ដល់ផ្លូវដង្ហើម កើតមានជម្ងឺសើស្បែក និងបណ្តាលឱ្យកើតមានជម្ងឺរ៉ាំរ៉ៃផ្សេងៗ។

ចំពោះទឹកស្អុយ ដែលចេញពីសំណល់ប្រកបដោយគ្រោះថ្នាក់នោះដែលមួយផ្នែកអាចផ្តល់ជាជម្រកដល់ភ្នាក់ងារចម្លងជម្ងឺមួយចំនួនធំ និងមួយផ្នែកទៀតដែលផ្ទុកទៅដោយសារ ធាតុគីមីពុលអាចជ្រាបចូលក្នុងដីបានធ្វើឱ្យប៉ះពាល់ដល់គុណភាពដី ទឹក និងទឹកក្រោមដី ធ្វើឱ្យមានការបំពុលទឹក និងដី។ ចំណែកឯសារធាតុមួយចំនួនដែលមិនអាចបំបែកធាតុបានដូចជាកៅស៊ូ ប្លាស្ទិក កែវ ជាដើមដែលត្រូវការទីតាំងធំដើម្បីទុកដាក់វា។ ការបោះចោលសំណល់រាយប៉ាយ អាចបង្កឱ្យស្ទះដល់ប្រព័ន្ធលូសាធារណៈតាមរយៈការហូរនាំដោយទឹកភ្លៀង ខូចដល់សោភ័ណភាព និងសណ្តាប់ធ្នាប់សាធារណៈ។

**សំណល់រាវ** គឺជាវត្ថុរាវ ដែលជាផលិតផលនឹងជាសារធាតុផ្សំជាមួយនឹងសារធាតុរឹងខ្លះដែលត្រូវបានបញ្ចេញចោលជាប្រចាំទៅតាមបណ្តាញប្រព័ន្ធលូទឹកស្អុយផ្សេងៗ។ ហើយនៅពេលដែលគ្រប់គ្រងសំណល់រាវមិនបានល្អនឹងបង្កឱ្យមានការបំពុលជាច្រើនកើតឡើងដូចជា ការបំពុលទឹក ការបំពុលដី និងការបំពុលទឹកនៅក្នុងដីហើយក៏ធ្វើឱ្យប៉ះពាល់ដល់មនុស្ស សត្វ និងរុក្ខជាតិទៀតផង។ នៅពេលសំណល់រាវបានបង្ហូរចូលក្នុងទឹក និងដី វានឹងធ្វើឱ្យទឹកពុលព្រមទាំងដីអស់ជីវជាតិ។ ម៉្យាងទៀតនៅពេលដែលសំណល់ជ្រាបចូលក្នុងដីវាអាចនឹងធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹកដែលនៅក្នុងដីទៀតផង។ បន្ថែមពីនេះការធ្វើឱ្យខូចគុណភាពទឹកដោយការបង្ហូរទឹកកង្វក់ និងចោលសំរាមនេះចូលក្នុងទឹកដែលជាបញ្ហាដែលធ្វើឱ្យទឹកមានលក្ខណៈកករ។ បន្ទាប់មកនៅពេលដែលមនុស្សបានយកទឹកនោះមកប្រើប្រាស់នឹងធ្វើឱ្យប៉ះពាល់ដល់សុខភាពដែលនឹងងាយកើតនូវជម្ងឺនានាដោយជាពម្មតាទឹកកង្វក់ទាំងនោះ គឺមានក្លិនដែលធ្វើឱ្យមនុស្សមិនឃ្លានចំណីអាហារធ្វើឱ្យទន់ខ្សោយក្នុងការដកដង្ហើម ក្អួតចង្អោរ និងការបង្កឱ្យមានវិបត្តិដល់ខួរក្បាលជាដើម។ ទន្ទឹមនឹងនេះសំណល់រាវអាចធ្វើឱ្យមានការបំផ្លាញដល់ជីវចំរុះដោយសារសារធាតុគីមី ឬសំណល់គ្រោះថ្នាក់ដែលមាននៅក្នុងទឹកនឹងធ្វើឱ្យជីវចំរុះមួយចំនួនក្នុងមជ្ឈដ្ឋាននោះត្រូវថយចុះ ឬក៏អាចបាត់បង់ទាំងស្រុង។ លើសពីនេះការខ្វះខាតក្នុងការគ្រប់គ្រងនេះក៏អាចនឹងប៉ះពាល់យ៉ាងខ្លាំងទៅដល់សោភ័ណភាពនៃការរៀបចំក្រុងដែលទឹកលូនោះបានបញ្ចេញក្លិនមិនសមរម្យហើយព្រមទាំងធ្វើឱ្យសេដ្ឋកិច្ចជាតិមានការធ្លាក់ចុះផងដែរ។

### ១.៣.១.៣. ផលប៉ះពាល់សំណល់រឹង-រាវចំពោះសោភ័ណភាព

ភាពស្រស់ស្អាតរបស់ទីក្រុង គឺត្រូវពឹងផ្អែកយ៉ាងជិតស្និតជាមួយនឹងបរិស្ថានស្អាតប៉ុន្តែបើទីក្រុងមួយពោរពេញទៅដោយសំរាម ក្លិនស្អុយ លូទឹកស្អុយ ធូលីហោះហើរពេញដីនោះនឹងធ្វើឱ្យទីក្រុងនោះបាត់បង់នូវភាពស្រស់ស្អាតនឹងសោភ័ណភាពជាដើម។ សោភ័ណភាពទីក្រុង គឺជាផ្នែកមួយនៃការទាក់ទាញភ្ញៀវទេសចរចូលមកទស្សនាប្រទេសដែលកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជាជាដើម។ សំរាមបានបំផ្លាញសោភ័ណភាពទីក្រុង និងរមនីយដ្ឋាននានាធ្វើឱ្យប្រជាជនមានអារម្មណ៍មិនល្អពេលឃើញសភាពបែបនេះនៅកន្លែងដែលខ្លួនរស់នៅ ហើយចំនួនភ្ញៀវទេសចរក៏ធ្លាក់ចុះដែលជាហេតុធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាធ្លាក់ចុះ និងខូចកិត្តិយស។ ចំពោះសំរាម

ដែលជាប្លាស្ទិកដែលត្រូវបានបោះចូលទៅក្នុងទឹកធ្វើឱ្យសត្វងាប់ដោយសារពួកសត្វទាំងនោះបានស៊ីប្លាស្ទិកជាចំណី( ប្លាស្ទិកមិនរលាយបន្ទាប់ពីសត្វស៊ី )។[២២] បើយើងសង្កេតមើលឱ្យមានភាពល្អិតល្អន់លើផ្នែកបរិស្ថានដែលនៅជុំវិញខ្លួនយើង គឺអាចនិយាយបានថាសុទ្ធសឹងតែពោរពេញទៅដោយសំរាមបញ្ហានេះកើតឡើងដោយសារតែមិនមានការចូលរួមយកចិត្តទុកដាក់ និងជួយពីសំណាក់ប្រជាជនបន្ទាប់ពីមានការជួយជ្រោមជ្រែងពីរដ្ឋាភិបាលកន្លងមក។ បញ្ហានេះអាចមកពីពួកគេមិនមានការយល់ដឹងគ្រប់គ្រាន់លើបញ្ហានេះ ឬពួកគេបានយល់ដឹងពីផលវិបាកដែលបង្កដោយសំរាមនេះហើយតែបែរជាមិនអនុវត្តន៍តាមទៅវិញ។ ចំណែកហេតុផលមួយទៀតនោះអាចមកពីនៅតាមទីកន្លែងសាធារណៈក៏ដូចជាតំបន់ផ្សេងៗដែលប្រជាពលរដ្ឋរស់នៅតាមទីកន្លែងកម្សាន្តមិនមានធុងសំរាមសម្រាប់ផ្ទុកសំរាមគ្រប់គ្រាន់ គឺមានន័យថាកន្លែងនីមួយៗទោះជាមានធុងសំរាម តែវាមានគម្លាតឆ្ងាយពីគ្នាពេក។[២៣]

[២២] គេហទំព័រ ការបំពុលសំរាម៖ មូលហេតុ, ផលវិបាកនិងឧទាហរណ៍ - (warbletoncouncil.org) ដកស្រង់នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៤

[២៣] គេហទំព័រ សោភ័ណភាពទីក្រុង – Site Title (wordpress.com) ដកស្រង់នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤

# ជំពូកទី២

# វិធានការ និងការដោះស្រាយសំណល់ (រឹង-រាវ) ក្នុងរាជធានីភ្នំពេញ

# ជំពូកទី២

# វិធានការ និងការដោះស្រាយសំណល់ (រឹង-រាវ) ក្នុងរាជធានីភ្នំពេញ

## ២.១. ផែនការ យុទ្ធសាស្ត្ររបស់សាលាក្រុងរាជធានីភ្នំពេញស្ដីពីសំណល់រឹង-រាវ

ក្នុងគោលបំណងនេះសាលារាជធានីភ្នំពេញបានរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងសំណល់រួមជាមួយនឹងផែនការសកម្មភាពដែលពាក់ព័ន្ធដើម្បីដឹកនាំសកម្មភាពរបស់ខ្លួនចែករំលែកចក្ខុវិស័យ និងបំណងនៃសកម្មភាពលើសេវាគ្រប់គ្រងសំណល់របស់ទីក្រុងជាមួយសង្គមទាំងមូលដើម្បីលើកកម្ពស់កិច្ចសហការជាមួយអ្នកដែលពាក់ព័ន្ធនានា និងឆ្ពោះទៅរកការរៀបចំធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងសំណល់ប្រកបដោយប្រសិទ្ធភាពសម្រាប់ផលប្រយោជន៍ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ។[២៤]

### ២.១.១. គោលការណ៍ណែនាំ

គោលការណ៍ណែនាំខាងក្រោមត្រូវបានគេប្រើជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍសកម្មភាពយុទ្ធសាស្ត្រដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការគ្រប់គ្រងសំណល់បច្ចុប្បន្នប្រកបទៅដោយអនាម័យ បរិស្ថានស្អាត និងនិរន្តរភាព។

- **ឋានានុក្រមនៃការគ្រប់គ្រងសំណល់** គឺជាឧបករណ៍យុទ្ធសាស្ត្រដែលជាសកម្មភាពអាទិភាពសម្រាប់ការស្ថាបនាប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹង-រាវដោយផ្អែកទៅលើគោលការណ៍ 3R (៣អ៊ែរ )រួមមាន៖
    - **ការកាត់បន្ថយ** កាត់បន្ថយការបង្កើតបរិមាណសំរាម សំណល់រឹងតាមរយៈការផ្លាស់ប្ដូរបែបបទនៃការប្រើប្រាស់ផលិតផល និង/ឬសេវាកម្ម។
    - **ការប្រើប្រាស់ឡើងវិញ** ជួសជុលនូវទំនិញដែលអាចជួសជុលបាន ឬស្វែងរកជម្រើសសម្រាប់ប្រើប្រាស់ឡើងវិញ។
    - **ការកែច្នៃឡើងវិញ** ធ្វើការកែច្នៃសំណល់ឱ្យវាមានតម្លៃជាធនធានវត្ថុធាតុដើម សម្រាប់ក្នុងការផលិតចេញឡើងវិញ។
- **ការទាញយកនូវថាមពល** ជាការបម្លែងសំណល់ឱ្យទៅជាប្រភពថាមពល (ឥន្ធនៈ កម្ដៅ និងថាមពល) ដោយបង្កើតឱ្យមានជាជីវឧស្ម័នតាមរយៈការបំបែកសំណល់ជីវក្នុងលក្ខខណ្ឌគ្មានខ្យល់ ការដុតសំណល់យកថាមពល និងថាមពលពីចំហេះជីវម៉ាសជាដើម។

[២៤] គេហទំព័រសាលារាជធានីភ្នំពេញ https://phnompenh.gov.kh/ ដកស្រង់ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤

- **ការចាក់ចោលសំណល់ទៅទីលានចាក់សំរាម** ដោយមានការត្រួតពិនិត្យ ឬដុតកម្ទេចចោលដោយមិនមានការទាញយកថាមពល។
- **ការចាក់ចោលសំណល់ទៅទីលានចាក់សំរាម** ដោយមិនមានការត្រួតពិនិត្យ។
- **ការអភិរក្សធនធាន** សំដៅជម្រុញការប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាព ទាំងការទាញយកធនធានពីសំណល់មកប្រើប្រាស់ឡើងវិញការបញ្ចៀសការទាញយកធនធានវត្ថុធាតុដើមផ្សេងៗ និងបញ្ចៀសការបង្កើតសំណល់។
- **គោលការណ៍បង់ប្រាក់សម្រាប់អ្នកបង្កើតការបំពុល** ជាគោលការណ៍ដែលអ្នកបង្កើតភាពបំពុលត្រូវទទួលខុសត្រូវ ឬការបង្កើតសំរាមត្រូវតែបង់ប្រាក់ចំពោះការបំពុល ឬការគ្រប់គ្រងសំរាម (ការប្រមូលដឹកជញ្ជូន និងចាក់ចោល) ដើម្បីរក្សាបាននូវសុខភាព បរិស្ថាន និងប្រព័ន្ធជីវសាស្ត្រចម្រុះ។
- **គោលការណ៍ប្រុងប្រយត្ន័ជាមុន** គោលការណ៍កំណត់ពីកង្វះទិន្នន័យឯកសារផ្នែកវិទ្យាសាស្ត្រដែលមិនគួរប្រើប្រាស់ធ្វើជាហេតុផលសម្រាប់ភាពអសកម្មដើម្បីការពារការបំផ្លាញ ឬការរិចរិលបរិស្ថាន។
- **គោលការណ៍ទីតាំងផលិត** ជាគោលការណ៍ដែលសំរាមត្រូវដោះស្រាយទៅតាមទីតាំងផលិតកាន់តែជិតកាន់តែប្រសើរ។មធ្យោបាយនេះជួយកាត់បន្ថយចំណាយថ្លៃដឹក និងថែមទាំងកាត់បន្ថយការបំពុលបរិស្ថានកំឡុងពេលដឹកជញ្ជូន។
- **គោលការណ៍នៃការផ្ដល់ប្រឹក្សា** គឺជាគោលការណ៍ដែលឱ្យសារៈសំខាន់ទៅលើថ្នាក់ដឹកនាំគ្រប់កម្រិតរបស់រដ្ឋបាលរាជធានីភ្នំពេញតាមរយៈការពិគ្រោះយោបល់ និងការធ្វើការជាមួយប្រជាពលរដ្ឋ និងអង្គការនានាតាមការអភិវឌ្ឍ និងអនុវត្តន៍ផែនការសកម្មភាព និងយុទ្ធសាស្ត្រគ្រប់គ្រងសំណល់។
- **ការចែករំលែកទំនួលខុសត្រូវ** នៅក្នុងបរិបទនេះសំណល់សូន្យ ( Zero waste ) គឺជាការទទួលខុសត្រូវរួម និងទាមទារភាពជាដៃគូ និងសហការលើគ្រប់វិស័យរបស់រដ្ឋាភិបាលខាងឧស្សាហកម្មគ្រប់បណ្ដាស្ថាប័នស្រាវជ្រាវ អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍ទូទៅ។[២៥]

### ២.១.២. ចក្ខុវិស័យ

ផែនការអភិវឌ្ឍន៍ទីក្រុងរបស់រាជធានីភ្នំពេញដែលផ្តល់នូវក្របខណ្ឌសម្រាប់ការអភិវឌ្ឍរយៈពេលមធ្យម និងរយៈពេលវែងរបស់រាជធានីបានចែងថា រាជធានីភ្នំពេញនឹងក្លាយជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ចពាណិជ្ជកម្មវប្បធម៌ប្រកបដោយសក្ដានុពលប្រកួតប្រជែងជាមួយការអភិវឌ្ឍដែលប្រកបទៅដោយវឌ្ឍនភាព

[២៥] គេហទំព័រសាលារាជធានីភ្នំពេញ https://phnompenh.gov.kh/ ដកស្រង់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤

សមធម៌ និងចីរភាព។ យុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់សម្រាប់រាជធានីភ្នំពេញក៏ដើរស្រប តាមចក្ខុវិស័យនេះដែលការគ្រប់គ្រងសំណល់ និងធនធានបានរួមចំណែកឆ្ពោះទៅរកការសម្រេចបាននូវសង្គម ចក្ខុវិស័យផងដែរ។ ដោយសារតែគោលនយោបាយសកល និងនិន្នាការគោលនយោបាយសេដ្ឋកិច្ច ការសម្រេច ឱ្យបាននូវសមិទ្ធផលសង្គមប្រកបដោយប្រសិទ្ធភាព គឺជាការចាំបាច់ក្នុងការទទួលបានផលប្រយោជន៍ដែលជា យុទ្ធសាស្ត្ររបស់រាជធានីភ្នំពេញ និងលើកកម្ពស់ស្តង់ដារជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។[២៦]

### ២.១.៣. បេសកកម្ម

រដ្ឋបាលរាជធានីភ្នំពេញ បានកំណត់ចេញនូវបេសកកម្មចំនួន ០៤ ជាមគ្គុទ្ទេសគោលនយោបាយក្នុង ការគ្រប់គ្រងសំណល់របស់ខ្លួនដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើមានដូចជា៖

- ការពារបរិស្ថាន និងលើកកម្ពស់សុខមាលភាពប្រជាពលរដ្ឋ
- ការបង្កើតសង្គមមួយដែលសំណល់ ត្រូវបានកាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ ដូច្នេះ សំណល់ត្រូវបានទប់ស្កាត់ដល់កម្រិតអប្បបរមា
- ការចូលរួមកែលំអរសង្គមឱ្យមានការបំភាយកាបូនតិចតាមរយៈការគ្រប់គ្រងសំណល់
- លើកកម្ពស់ការចូលរួម/កិច្ចសហការរវាងរដ្ឋាភិបាលប្រជាពលរដ្ឋ និងអាជីវកម្មសម្រាប់ការគ្រប់គ្រង សំណល់ឱ្យមានប្រសិទ្ធភាព។[២៧]

### ២.១.៤. គោលដៅ

គោលបំណងចុងក្រោយនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពនេះ គឺបង្កើតប្រព័ន្ធគ្រប់គ្រងសំណល់ ប្រកបដោយប្រសិទ្ធភាព កាត់បន្ថយសំណល់ និងការប្រើប្រាស់ធនធានតាមរយៈការសហការគ្នារវាងអ្នកដែល ពាក់ព័ន្ធនានាក្នុងសង្គមដើម្បីកាត់បន្ថយហេតុប៉ះពាល់លើបរិស្ថាន និងសុខភាពជាអវិជ្ជមាន។ ខាងក្រោមនេះ គឺ ជាគោលដៅចម្បងដែលត្រូវអនុវត្តន៍៖

- **ការកាត់បន្ថយកាកសំណល់** ការអនុវត្តវិធានការកាត់បន្ថយបរិមាណសំណល់ដែលបានបង្កើតតាំង ពីដំបូង។ នេះអាចរួមបញ្ចូលការលើកកម្ពស់ការកែច្នៃឡើងវិញការលើកទឹកចិត្តដល់ការប្រើប្រាស់ ផលិតផលដែលអាចប្រើឡើងវិញបាន និងការអនុវត្តយុទ្ធនាការកាត់បន្ថយកាកសំណល់។

[២៦] គេហទំព័រសាលារាជធានីភ្នំពេញ https://phnompenh.gov.kh/ ដកស្រង់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៤

[២៧] គេហទំព័រសាលារាជធានីភ្នំពេញ https://phnompenh.gov.kh/ ដកស្រង់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៤

- **ការបំបែកកាកសំណល់** ការលើកទឹកចិត្តអ្នកស្រុក និងអាជីវកម្មឱ្យបែងចែកកាកសំណល់របស់ពួកគេទៅជាប្រភេទផ្សេងៗគ្នាដូចជា កាកសំណល់ដែលអាចកែច្នៃឡើងវិញបាន កាកសំណល់សរីរាង្គ និងកាកសំណល់ទូទៅ។ នេះអាចជួយសម្រួលដល់ការកែច្នៃឡើងវិញ និងការចោលកាកសំណល់ប្រភេទផ្សេងៗបានត្រឹមត្រូវ។
- **កម្មវិធីកែច្នៃឡើងវិញ** ការបង្កើត ឬកែលម្អកម្មវិធីកែច្នៃឡើងវិញដើម្បីធានាថាសម្ភារដែលអាចកែច្នៃឡើងវិញបានត្រូវបានប្រមូល កែច្នៃ និងប្រើប្រាស់ឡើងវិញប្រកបដោយប្រសិទ្ធភាព។ នេះអាចរួមបញ្ចូលការបង្កើតមជ្ឈមណ្ឌលកែច្នៃ ការផ្តល់ធុងសំរាមឡើងវិញ និងមានការអប់រំជាសាធារណៈអំពីសារៈសំខាន់នៃការកែច្នៃឡើងវិញ។
- **ជីកំប៉ុស** លើកកម្ពស់ការធ្វើជីកំប៉ុសនៃកាកសំណល់សរីរាង្គដើម្បីកាត់បន្ថយបរិមាណកាកសំណល់ដែលបានបញ្ជូនទៅកន្លែងចាក់សំរាម និងផលិតជីកំប៉ុសដែលសម្បូរសារធាតុចិញ្ចឹមសម្រាប់ផលិតផលកសិកម្ម។
- **កាកសំណល់ទៅជាថាមពល** ការរុករកនូវបច្ចេកវិទ្យាពីកាកសំណល់ទៅជាថាមពល ដើម្បីបំប្លែងកាកសំណល់ទៅជាថាមពលដែលអាចជួយកាត់បន្ថយបរិមាណកាកសំណល់ដែលបញ្ជូនទៅកន្លែងចាក់សំរាម និងបង្កើតថាមពលកកើតឡើងវិញ។
- **ការគ្រប់គ្រងកន្លែងចាក់សំរាម** ការកែលម្អការអនុវត្តការគ្រប់គ្រងកន្លែងចាក់សំរាមដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថានដូចជាការអនុវត្តវិធានការកាត់បន្ថយការបំភាយឧស្ម័នមេតាន ការគ្រប់គ្រងទឹកសំណល់ និងការស្តារឡើងវិញនូវឧស្ម័ននៅកន្លែងចាក់សំរាម។
- ធ្វើយុទ្ធនាការផ្សព្វផ្សាយ និងកម្មវិធីអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីការអនុវត្តការគ្រប់គ្រងសំណល់ឱ្យបានត្រឹមត្រូវសារៈសំខាន់នៃការកែច្នៃឡើងវិញ និងផលប៉ះពាល់ចំពោះបរិស្ថានការចោលកាកសំណល់មិនត្រឹមត្រូវ។
- **គោលនយោបាយ និងបទប្បញ្ញត្តិ** ការអនុវត្តគោលនយោបាយ និងបទប្បញ្ញត្តិគ្រប់គ្រងកាកសំណល់ដើម្បីធានាបាននូវការអនុលោមតាមស្តង់ដារការចោលសំរាមលើកកម្ពស់ការអនុវត្តប្រកបទៅដោយនិរន្តរភាព និងរក្សាបុគ្គល និងអាជីវកម្មទទួលខុសត្រូវចំពោះការគ្រប់គ្រងសំណល់ឱ្យបានត្រឹមត្រូវ។[២៨]

[២៨] គេហទំព័រសាលារាជធានីភ្នំពេញ https://phnompenh.gov.kh/ ដកស្រង់ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤

## ២.២. តួនាទីពាក់ព័ន្ធក្នុងការគ្រប់គ្រងសំណល់

ក្រសួងបរិស្ថានត្រូវសហការជាមួយក្រសួងពាក់ព័ន្ធដើម្បីចងក្រងបញ្ជីសារពើភ័ណ្ឌដែលបញ្ជាក់ពី៖

- ប្រភព ប្រភេទ និងបរិមាណនៃសារធាតុបំពុល និងសំណល់ដែលត្រូវនាំចូលហើយបង្កើតឡើង ដឹកជញ្ជូន កែច្នៃឡើងវិញ បានប្រព្រឹត្តកម្ម រក្សាទុក បោះបង់ចោល ឬបញ្ចេញចោលទៅក្នុងអាកាស ទឹក ក្នុងដី ឬលើដី។
- ប្រភព ប្រភេទ និងបរិមាណនៃសារធាតុពុល និងសារធាតុប្រកបដោយគ្រោះថ្នាក់ដែលបាននាំចូល ផលិត ដឹកជញ្ជូន រក្សាទុក ប្រើប្រាស់ បង្កើតឡើងបានប្រព្រឹត្តកម្ម កែច្នៃឡើងវិញ បោះបង់ចោល ឬ ដែលចាក់បញ្ចេញចោលទៅក្នុងអាកាស ទឹក ឬទៅក្នុងដី ឬលើដី។[២៩]

### ២.២.១. បទប្បញ្ញត្តិ

បទដ្ឋានច្បាប់ ប្រកាស អនុក្រឹត្យ និងសេចក្តីណែនាំផ្សេងៗ ត្រូវបានដាក់ចេញជាបន្តបន្ទាប់ទាំងថ្នាក់ជាតិ និងថ្នាក់រាជធានីអស់រយៈពេលជាច្រើនឆ្នាំទាក់ទងទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹង-រាវទីប្រជុំជន។

- អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង លេខ ៣៦ អនក្រ.បក (ឆ្នាំ១៩៩៩)
- សេចក្តីប្រកាស អន្តរក្រសួងនៃក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង នៅតាមខេត្ត/ ក្រុងនៃប្រទេសកម្ពុជា លេខ ៨០ (ឆ្នាំ២០០៣)
- អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន លេខ ១១៣ អនក្រ.បក (ឆ្នាំ២០១៥)
- យុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់នៃប្រទេសកម្ពុជា
- ពង្រាងសេចក្តីណែនាំស្តីពីការកែលម្អការងារគ្រប់គ្រង ការសម្អាតសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ
- សេចក្តីជូនដំណឹងស្តីពីការទុកដាក់ ការសម្អាត ការបញ្ចេញសំរាម និងការពិន័យចំពោះការបោះចោលសំរាមគ្មានសណ្តាប់ធ្នាប់នៅក្នុងរាជធានីភ្នំពេញ លេខ ១៣ (ឆ្នាំ២០១៣)
- ផែនការណែនាំស្តីពីការអនុវត្តការផាកពិន័យដើម្បីលើកកម្ពស់អនាម័យបរិស្ថាននៅរាជធានីភ្នំពេញ លេខ២០៩ (ឆ្នាំ២០១០)
- សេចក្តីណែនាំស្តីពីការពិន័យលើការចោលសំរាមតាមទីសាធារណៈ លេខ ១៦ (ឆ្នាំ២០១០)

[២៩] ច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ, ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦, មាត្រា១២

- ផែនការណែនាំស្តីពីការអនុវត្តការញែកសំរាម នៅរាជធានីភ្នំពេញ លេខ០៨ (ឆ្នាំ២០១០)
- អនុក្រឹត្យ ស្តីពីការរៀបចំ និងមុខងាររបស់នាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់ លេខ ៤៤៦ (ឆ្នាំ២០១៥)
- ប្រកាស ស្តីពីការដាក់ឱ្យប្រើប្រាស់នូវកម្រិតកំណត់ស្តង់ដារបរិមាណជាតិពុល ឬសារធាតុគ្រោះថ្នាក់ ដែលអនុញ្ញាតឱ្យបោះបង់ចោល លេខ ៣៨៧ (ឆ្នាំ២០១៥)
- គោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងសំណល់រឹងនៅតាមរោងចក្រ សហគ្រាស និងក្រុមហ៊ុន លេខ ១១ (២០០៣)
- គោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងសំណល់ភក់នៅតាមរោងចក្រ សហគ្រាស (២០០០)
- គោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងសំណល់គ្រោះថ្នាក់ពីរោងចក្រ លេខ ៨៧ (២០០០)
- សេចក្តីប្រកាស ស្តីពីការប្រមូលសំណល់ឧស្សាហកម្ម និងដឹកជញ្ជូនក្នុងរាជធានីភ្នំពេញ និងខេត្តកណ្តាល លេខ ១៤៨ (២០០២)
- សេចក្តីប្រកាសពីការអនុញ្ញាតឱ្យក្រុមហ៊ុន សារ៉ុ ត្រេដឌីង ប្រមូល និងដឹកជញ្ជូនសំណល់ឧស្សាហកម្ម ពីរាជធានី និងខេត្តកណ្តាល លេខ ១៥៦ (២០០១)
- អនុក្រឹត្យថ្មីមួយត្រូវបានចេញដោយក្រសួងបរិស្ថាននៅឆ្នាំ២០១៦ ដើម្បីគ្រប់គ្រងក្រុមហ៊ុនដែលបាន ទិញ រុះរើបំណែក និងបោះបង់ចោលសំណល់អេឡិចត្រូនិកក៏ដូចជាតម្រូវការស្នើសុំជាមុនសម្រាប់ការ ផ្តួចផ្តើមប្រតិបត្តិការអាជីវកម្ម ហើយគេក៏បានបង្ហាញពីមាត្រានៃការផាកពិន័យចំពោះភាពល្មើសតាម ច្បាប់នេះចំនួន ៤០.០០០ រៀល សម្រាប់បុគ្គល និង២.០០០.០០០ រៀលសម្រាប់អាជីវកម្មផងដែរ។
- អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក លេខ ១៦ អនក្រ.បក (ឆ្នាំ២០១៦)
- អនុក្រឹត្យ ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព្រឹត្តកម្មទឹកកខ្វក់ លេខ ២៣៥ អនក្រ.បក (ឆ្នាំ២០១៧)
- អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក លេខ ២៧ អនក្រ.បក (ឆ្នាំ១៩៩៩)។[៣០]

[៣០] គេហទំព័រសាលារាជធានីភ្នំពេញ https://phnompenh.gov.kh/ ដកស្រង់ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤

### ២.២.២. អគ្គនាយកដ្ឋានគាំពារបរិស្ថាននៃក្រសួងបរិស្ថាន

នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថានមានភារកិច្ចសហការជាមួយនាយកដ្ឋានជំនាញដើម្បី៖

- បំពេញកិច្ចការជំនាញពាក់ព័ន្ធនឹងកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារអន្តរជាតិនានាស្តីពីកិច្ចការពារគុណភាពបរិស្ថាន។
- ចងក្រងបញ្ជីសារពើភ័ណ្ឌ ដែលបញ្ជាក់ពីប្រភព ប្រភេទ និងបរិមាណនៃសំណល់រឹង រាវ សារធាតុបំពុល សារធាតុពុល សារធាតុប្រកបដោយគ្រោះថ្នាក់ ផ្សែង សំលេង និងរំញ័រ។
- រៀបចំ និងអនុវត្តអនុក្រឹត្យ ព្រមទាំងបរិធានច្បាប់នានាសម្រាប់កិច្ចការពារគុណភាពបរិស្ថាន និងត្រួតពិនិត្យការបំពុលនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។
- អង្កេតតាមដានធ្វើរបាយការណ៍ និងផ្សព្វផ្សាយពីស្ថានភាពគុណភាពបរិស្ថានរួមមានស្ថានភាពបំពុលខ្យល់ ទឹក ដី និងសំលេង ជូនសាធារណជន។
- រៀបចំ សំណើស្តីពីនីតិវិធីនៃការធ្វើអធិការកិច្ចលើប្រភពបំពុល និងការធ្វើរបាយការណ៍ស្តីពីបទល្មើសជូនស្ថាប័នមានសមត្ថកិច្ច ។
- អនុវត្តន៍ការធ្វើអធិការកិច្ចលើប្រភពបំពុល និងធ្វើរបាយការណ៍ស្តីពីបទល្មើសជូនស្ថាប័នដែលមានសមត្ថកិច្ចដោយសហការជាមួយក្រសួងពាក់ព័ន្ធ។[៣១]

### ២.២.៣. តួនាទី និងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធ

តួនាទី និងការទទួលខុសត្រូវរបស់មន្ទីរពាក់ព័ន្ធលើការគ្រប់គ្រងសំណល់នៅរាជធានីភ្នំពេញមានដូចជា៖

- **ការិយាល័យដឹកជញ្ជូនសាធារណៈ**
  - តួនាទី និងការទទួលខុសត្រូវ គឺសម្អាតតាមសួន និងទីតាំងសាធារណៈដទៃទៀតហើយវេចខ្ចប់សំណល់ដើម្បីឱ្យក្រុមហ៊ុនប្រមូលសំរាមអាចប្រមូលទាន់ពេល។
  - ធ្វើការយ៉ាងជិតស្និទ្ធជាមួយនគរបាល ឬអាជ្ញាធរមូលដ្ឋានត្រួតពិនិត្យតាមសួន និងអនុវត្តន៍ទៅលើការផាកពិន័យអ្នកចោលសំរាមលើសួន។
  - រាយការណ៍ទៅកាន់សាលារាជធានីភ្នំពេញឱ្យបានទៀងទាត់។

[៣១] អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន, លេខ ១៣៥ អនក្រ.បក, ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦, មាត្រា៨

❖ **មន្ទីរវិចិត្រសិល្បៈ**

គ្រប់គ្រង និងសម្អាតឧទ្យាន ឬសួនក្នុងវត្តភ្នំ និងបញ្ចេញសំណល់ឱ្យបានត្រឹមត្រូវទៅតាមកាលវិភាគប្រមូលសំរាមរបស់ក្រុមហ៊ុនប្រមូលសំរាម។

❖ **មន្ទីរបរិស្ថាន**

- ដើរតួជាសេនាធិការរបស់សាលារាជធានីភ្នំពេញក្នុងការរៀបចំផែនការសកម្មភាពស្ដីពីការប្រមូលសំរាម ការស្តុកទុកបណ្តោះអាសន្ន ការដឹកជញ្ជូន និងការចាក់ចោល។
- ធ្វើការជាមួយសាលារាជធានី ជាពិសេសទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថានរបស់សាលារាជធានី និងអាជ្ញាធរមូលដ្ឋានដូចជាខណ្ឌ និងសង្កាត់ដើម្បីត្រួតពិនិត្យអំពីបញ្ហាសំណល់នៅតាមមូលដ្ឋាន និងវាយតម្លៃផែនការមេនៃការប្រមូលសំរាមរបស់ស៊ីនទ្រី និងក្រុមហ៊ុនប្រមូលសំរាមដទៃទៀត។
- ធ្វើការជាមួយអាជ្ញាធរខណ្ឌ និងសង្កាត់ដើម្បីលើកកម្ពស់ការយល់ដឹងលើកស្លាកសញ្ញា និងផាកពិន័យ។
- រាយការណ៍បញ្ហាគ្រប់គ្រងសំណល់ទៅកាន់សាលារាជធានីភ្នំពេញ។

❖ **មន្ទីរទេសចរណ៍**

ត្រូវផ្ដល់ការណែនាំ ឬការលើកកម្ពស់ការយល់ដឹងនៅទីរមណីយដ្ឋាន ទីកន្លែងទេសចរណ៍ ផ្ទះសំណាក់ សណ្ឋាគារ ភោជនីយដ្ឋានបរទេស អំពីការញែកសំណល់ ការបញ្ចេញចោល/ ការវេចខ្ចប់ឱ្យបានត្រឹមត្រូវស្របទៅនឹងកម្មវិធីប្រមូលសំរាម។

❖ **មន្ទីរអប់រំ យុវជន និងកីឡា**

តួនាទី និងការទទួលខុសត្រូវ ត្រូវផ្ដល់ការណែនាំ ឬការលើកកម្ពស់ការយល់ដឹងដល់សាលារៀនរដ្ឋ និងឯកជនអំពីការញែកសំណល់ ការបញ្ចេញ/ការវេចខ្ចប់ឱ្យបានត្រឹមត្រូវស្របទៅនឹងកម្មវិធីប្រមូលសំរាម។

❖ **មន្ទីរពាណិជ្ជកម្ម**

ផ្ដល់ការណែនាំ និងការលើកកម្ពស់ការយល់ដឹងដល់អ្នកជំនួញ អ្នកលក់ដូរ អ្នកផ្ដល់សេវាកម្មដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មដើម្បីចូលរួមក្នុងការគ្រប់គ្រងសំណល់ក្នុងរាជធានីភ្នំពេញ។ ពួកគេត្រូវតែរៀបចំនូវធុងសំរាម និងវេចខ្ចប់ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលាសម្រាប់អ្នកប្រមូលសំរាម។

❖ **មន្ទីរឧស្សាហកម្ម និងសិប្បកម្ម**

ផ្ដល់ការណែនាំ និងការលើកកម្ពស់ការយល់ដឹងដល់សិប្បកម្ម និងអាជីវកម្មផ្សេងៗដែលស្ថិតនៅក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងដោយមន្ទីរឧស្សាហកម្ម និងសិប្បកម្មឱ្យចូលរួមក្នុងការគ្រប់គ្រងសំណល់ដែលមាននៅ

ក្នុងរាជធានីភ្នំពេញ។ ពួកគេត្រូវរៀបចំធុងសំរាម វេចខ្ចប់ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលាសម្រាប់អ្នកប្រមូលសំរាម។

❖ **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

ផ្តល់ការយល់ដឹងដល់រោងចក្រ សហគ្រាស និងកម្មករដើម្បីចូលរួមការអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងសំណល់ (ការវេចខ្ចប់ ឬការបញ្ចេញសំណល់បានប្រសើរជាងមុន និងការញែកសំរាម)។

❖ **មន្ទីរវប្បធម៌ និងសាសនា**

ផ្តល់ការយល់ដឹង ឬចែកចាយនូវព័ត៌មានទៅកាន់ទីវត្តអារាមទាំងអស់ឱ្យបានចូលរួមអនុវត្តន៍ផែនការ និងយុទ្ធសាស្ត្រដើម្បីឱ្យការអនុវត្តការងារគ្រប់គ្រងសំណល់កម្មវិធីប្រមូលសំណល់មានភាពប្រសើរឡើងជាពិសេសនៅកំឡុងពេលបុណ្យទានធំៗ។ ក្នុងពេលដំណាលគ្នាវត្តអារាមនីមួយៗត្រូវរៀបចំធុងសំរាម និងហាមចាក់សំរាមចោលមុខក្លោងទ្វារ និងជិតជញ្ជាំងព្រោះវាប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងសុខមាលភាព។

❖ **មន្ទីរសុខាភិបាល**

ត្រូវចែករំលែកព័ត៌មានដល់មន្ទីរពេទ្យគ្លីនិកតូចធំក្នុងរាជធានីឱ្យចូលរួមអនុវត្តន៍ផែនការ និងយុទ្ធសាស្ត្រដើម្បីឱ្យការអនុវត្តការងារគ្រប់គ្រងសំណល់មានភាពប្រសើរឡើង។ ចំពោះមន្ទីរត្រូវជំរុញឱ្យមន្ទីរពេទ្យ និងគ្លីនិកធ្វើការវេចខ្ចប់សំណល់ និងញែកសំណល់ឱ្យបានត្រឹមត្រូវ និងបញ្ចេញទាន់ពេលវេលាតាមកាលកំណត់។

❖ **មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី**

មន្ទីរចែកចាយព័ត៌មានពីវិធានការផាកពិន័យដល់ការដ្ឋានសំណង់ទាំងអស់ដែលបោះចោលសំណល់មិនបានត្រឹមត្រូវ។ មន្ទីរត្រូវចែករំលែកកម្មវិធីពេលវេលាប្រមូលសំរាម ទៅម្ចាស់សំណង់ទាំងអស់។ ជាការចាំបាច់ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ទីរជំនាញដើម្បីធ្វើការផាកពិន័យចំពោះការដ្ឋានសំណង់ទាំងនោះ។[៣២]

### ២.២.៤. រដ្ឋបាលរាជធានីភ្នំពេញ

នៅរាជធានីភ្នំពេញ រដ្ឋបាលរាជធានីភ្នំពេញទទួលខុសត្រូវក្នុងការធានានូវការផ្តល់សេវាគ្រប់គ្រងសំរាមសំណល់រឹង-រាវ និងមានការសម្របសម្រួលជំនួយបច្ចេកទេសពីមន្ទីរនានាជាសេនាធិការនៃក្រសួងស្ថាប័នដូចបានពិពណ៌នាពីខាងដើម។ ទោះបីជាយ៉ាងណាក៏ដោយអនុក្រឹត្យលេខ ១១៣ (ឆ្នាំ២០១៥) បានជំរុញការ

[៣២] គេហទំព័រសាលារាជធានីភ្នំពេញ https://phnompenh.gov.kh/ ដកស្រង់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៤

យកចិត្តទុកដាក់បន្ថែមទៀតផងដែរលើការផ្តល់សេវាដែលអនុញ្ញាតឱ្យរដ្ឋាភិបាលថ្នាក់ក្រោមជាតិអាចទទួលខុសត្រូវផ្នែកខ្លះៗនៃអភិបាលកិច្ចគ្រប់គ្រងសំណល់។ នេះជាលទ្ធផលនៃកំណែទម្រង់អភិបាលកិច្ចនៅក្នុងវិស័យសំណល់ដោយមានការផ្ទេរការទទួលខុសត្រូវជាច្រើនទៅរដ្ឋបាលខណ្ឌ និងសង្កាត់ហើយត្រូវបានដកស្រង់ដូចខាងក្រោម។

រដ្ឋបាលខណ្ឌត្រូវទទួលខុសត្រូវចំពោះការអនុវត្តភារកិច្ចដែលពួកគេទទួល និងជួយគាំទ្រសម្របសម្រួលដំណើរការនៃការបោសសម្អាត ការប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន និងសេវាផ្សេងទៀតនៅក្នុងវិស័យគ្រប់គ្រងសំណល់រឹងដូចតទៅៈ

- គ្រប់គ្រង និងអនុវត្តន៍ភារកិច្ចដែលពួកគេទទួលបានក្នុងការគ្រប់គ្រងសំណល់នៅទីប្រជុំជន
- ចូលរួម និងសហការក្នុងការអនុវត្តកម្មវិធីគ្រប់គ្រងសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ
- ចូលរួមតាមដានការអនុវត្តនៃការសម្អាត ការប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងតាមទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។[៣៣]

រដ្ឋបាលឃុំ-សង្កាត់ត្រូវទទួលខុសត្រូវចំពោះការអនុវត្តភារកិច្ចដែលបានធ្វើប្រតិភូកម្ម និងបំពេញតួនាទីគាំទ្រ និងសម្របសម្រួលនៃការសម្អាត ការប្រមូល និងសេវាដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដូចតទៅៈ

- គ្រប់គ្រងការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងតាមទីប្រជុំជនតាមការធ្វើប្រតិភូកម្ម។
- ចូលរួមក្នុងការអប់រំ និងផ្សព្វផ្សាយការងារសម្អាត ការដឹកជញ្ជូនសំរាម សំណល់រឹងនៅតាមទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ចូលរួមក្នុងការផ្តល់មតិយោបល់ទាក់ទងនឹងការរៀបចំ ការសម្អាត ការប្រមូលសំរាម និងការដឹកជញ្ជូនសំរាមទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ចូលរួមក្នុងការតាមដានការអនុវត្តនៃការសម្អាត ការប្រមូល ការដឹកជញ្ជូន និងសេវាគ្រប់គ្រងសំរាមសំណល់រឹងផ្សេងៗនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

[៣៣] អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ ១១៣ អនក្រ.បក, ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥, មាត្រា៩

- ចូលរួមដោះស្រាយបញ្ហាទាក់ទងនឹងការសម្អាត ការប្រមូល ការដឹកជញ្ជូន និងសេវាគ្រប់គ្រងសំរាម សំណល់រឹងផ្សេងៗនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងចូលរួមក្នុងពង្រឹងការអនុវត្តវិធានការច្បាប់ និងបទបញ្ញត្តិផ្សេងៗទាក់ទងនឹងការគ្រប់គ្រងសំរាម សំណល់រឹង។

រដ្ឋបាលខណ្ឌនីមួយៗ ត្រូវបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់ជាមួយនឹងក្រុមហ៊ុនប្រមូលសំរាម សំណល់រឹងនៅក្រោមកិច្ចសន្យាសម្បទាន ដែលមានស្រាប់រវាងក្រុមហ៊ុន និងរដ្ឋបាលរាជធានីភ្នំពេញ ដោយធ្វើការសម្របសម្រួលប្រចាំថ្ងៃលើការអនុវត្តសេវាកម្មប្រមូល និងដឹកជញ្ជូនសំរាមដែលបានប្រព្រឹត្តទៅតាមបែបរិមជ្ឈការ។[៣៤]

## ២.៣. ពង្រឹងប្រព័ន្ធសេវាកម្មប្រមូលសំរាម

ការធ្វើកំណែទម្រង់នៃការគ្រប់គ្រងសំរាម និងសំណល់រឹង នៅរាជធានីភ្នំពេញ ចាប់ពីដើមខ្សែរហូតដល់ចុងខ្សែទទួលបានលទ្ធផលគួរជាទីមោទនៈ ក្នុងនោះការដេញថ្លៃជ្រើសរើសក្រុមហ៊ុនថ្មី ដើម្បីផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ ក៏បានធ្វើរួចរាល់ផងដែរ ដែលកន្លងមក ក្រុមហ៊ុនចំនួន ០៣ត្រូវបានជ្រើសរើសហើយបានចាប់ផ្តើមប្រតិបត្តិការការងាររបស់ខ្លួនកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១។ ក្រុមហ៊ុនទាំង០៣នោះ គឺទី១ ក្រុមហ៊ុន 800 Super/Global Action for Environment Awareness Public Limited បានផ្តល់សេវាក្នុងតំបន់ទី១ ដែលមានចំនួន ០៥ខណ្ឌ រួមមាន ខណ្ឌទួលគោក ខណ្ឌសែនសុខ ខណ្ឌឫស្សីកែវ ខណ្ឌជ្រោយចង្វារ និងខណ្ឌព្រែកព្នៅ។ ទី២ មានក្រុមហ៊ុន Mizuda Group Co., Ltd បានផ្តល់សេវាក្នុងតំបន់ទី២ មានចំនួន ០៥ខណ្ឌរួមមាន ខណ្ឌដូនពេញ ខណ្ឌ៧មករា ខណ្ឌដង្កោ ខណ្ឌកំបូល និងខណ្ឌពោធិ៍សែនជ័យ។ ទី៣ ក្រុមហ៊ុនCINTRI បានផ្តល់សេវាក្នុងតំបន់ទី៣ ដែលមាន ០៤ខណ្ឌរួមមាន ខណ្ឌចំការមន ខណ្ឌបឹងកេងកង ខណ្ឌមានជ័យ និងខណ្ឌច្បារអំពៅ។

ដើម្បីឱ្យការអនុវត្តប្រព័ន្ធថ្មីនៃការគ្រប់គ្រងសំរាម សំណល់រឹង នៅក្នុងរាជធានីភ្នំពេញឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់រដ្ឋបាលរាជធានីភ្នំពេញ សូមធ្វើការណែនាំអំពីការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងដូចខាងក្រោម៖

- សំរាម និងសំណល់រឹង មុននឹងបញ្ចេញត្រូវសម្រិតទឹកចេញដាក់ចូលទៅក្នុងប្រព័ន្ធលូឱ្យបានត្រឹមត្រូវ។
- ត្រូវញែកសំរាម សំណល់រឹងជា០២ប្រភេទ គឺសំរាមសើម និងសំរាមស្ងួត ដោយដាក់នៅក្នុងថង់ដាច់ដោយឡែកពីគ្នា៖

[៣៤] អនុក្រឹត្យលេខ ១១៣ អនក្រ.បក, មាត្រា១៣

- សំរាមសើម សំណល់ម្ហូបអាហារ សំណល់សរីរាង្គ ផ្លែឈើ ផ្កា ត្រូវដាក់ នៅក្នុងថង់ពណ៌ខ្មៅ
- សំរាមស្ងួត ក្រដាស ក្រដាសកាតុង ឡាំង គ្រឿងប្លាស្ទិក ហ្វូម ជ័រ ដែក កំប៉ុង ដបត្រូវដាក់ក្នុងថង់ពណ៌ស។

**បញ្ជាក់** ក្រុមហ៊ុននឹងធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងដែលបានដាក់ក្នុងថង់ដែលបានកំណត់ទាំង ០២ប្រភេទនេះតែប៉ុណ្ណោះ ទៅតាមកម្មវិធីដាច់ដោយឡែកពីគ្នា។ ការដាក់សំរាម សំណល់រឹងក្នុងថង់ពណ៌ផ្សេងក្រៅពីពណ៌ខ្មៅ និងពណ៌ស ក្រុមហ៊ុននឹងមិនប្រមូលឡើយ។ បងប្អូនប្រជាពលរដ្ឋអាចរកទិញថង់ទាំង ០២ពណ៌ខាងលើនេះ នៅតាមបណ្តាទីផ្សារនានា។

- ➢ ហាមវេចខ្ចប់សំណល់ដែលបង្កគ្រោះថ្នាក់ ដូចជា អំបែងកញ្ចក់ និងសំណល់មុតស្រួចនានា លាយឡំជាមួយនឹងសំរាមសើម និងសំរាមស្ងួត។

ត្រូវទុកដាក់សំណល់ដែលបង្កគ្រោះថ្នាក់ទាំងនេះចូលក្នុងធុងសំរាម ឬប្រអប់ដោយឡែកឱ្យបានត្រឹមត្រូវ ក្រុមហ៊ុននឹងប្រមូលនៅរៀងរាល់ ថ្ងៃអាទិត្យ។ ក្នុងកាទុកដាក់ខុសពីការណែនាំនេះក្រុមការងារផាកពិន័យនឹងធ្វើកំណត់ហេតុអំពីកំហុសឆ្គងលើកទី១។ បើនៅតែទុកដាក់ខុសទៀតនឹងទទួលការផាកពិន័យទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងប្តឹងទៅតុលាការតាមកំហុសជាក់ស្តែង។

- ➢ ថង់សំរាម សំណល់រឹង ត្រូវចងមាត់ឱ្យបានជិតត្រឹមត្រូវ និងមិនត្រូវហែកឡើយ។
- ➢ ក្រុមតម្រូវ មានដូចជា ផ្សារទំនើប ផ្សាររដ្ឋ ផ្សារឯកជន អគារពាណិជ្ជកម្ម សណ្ឋាគារ ផ្ទះសំណាក់ អាគារស្នាក់នៅ ភោជនីយដ្ឋាន កន្លែងកំសាន្ត សាលារៀន មន្ទីរពេទ្យ លំនៅឋានក្នុងបុរី សហគ្រាស រោងចក្រ សិប្បកម្ម អគារក្រសួង ស្ថាប័នរដ្ឋ ត្រូវមានកាតព្វកិច្ចដាក់ធុងសំរាមដោយខ្លួនឯងជាចាំបាច់។
- ➢ ក្រុមលើកទឹកចិត្តមានដូចជា វត្តអារាម ព្រះវិហារ អាជីវកម្មលក់ដូរចល័ត ផ្ទះស្នាក់នៅទូទៅ និងផ្សារក្រមួន...អាចមាន ០២ប្រភេទ ទី១ មានធុងសំរាមខ្លួនឯងស្រាប់ និងទី២ មានធុងសំរាមដែលផ្តល់ឱ្យដោយប្រតិបត្តិករថ្មី ដែលអាចត្រូវបានរៀបចំដាក់ពង្រាយជាពិសេសនៅតាមតំបន់ផ្ទះល្វែងខ្ពស់ៗ។
- ➢ ត្រូវទុកដាក់សំរាម សំណល់រឹងរបស់ខ្លួនឱ្យបានត្រឹមត្រូវទៅតាមទីកន្លែងដែលបានកំណត់ (ទីតាំងទុកដាក់សំរាមនឹងត្រូវកំណត់ដោយអាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករប្រមូលសំរាមតាមជាក់ស្តែង)។
- ➢ ហាមចោលសំរាម សំណល់រឹងនៅមាត់អណ្តូងលូ ប្រឡាយ តាមទីសាធារណៈ និងតាមអាងស្តុកទឹក និងហាមដុតសំរាម សំណល់រឹង នៅរាជធានីភ្នំពេញជាកំហិត។
- ➢ កម្មវិធីបញ្ចេញសំរាម សំណល់រឹង

**សំរាមសើម**

ខណ្ឌកណ្តាលរាជធានី ចំនួន ០៥រួមមាន ខណ្ឌដូនពេញ ខណ្ឌចំការមន ខណ្ឌ៧មករា ខណ្ឌទួលគោក និងខណ្ឌបឹងកេងកង ក្រុមហ៊ុននឹងប្រមូល និងដឹកជញ្ជូនរៀងរាល់ថ្ងៃ នៅពេលយប់ ចាប់ពីម៉ោង៩ ដល់ម៉ោង៥ ទៀបភ្លឺដូច្នេះ ម៉ោងបញ្ចេញសំរាមមាន ៣ម៉ោង គឺម៉ោង៦-៩យប់។ បញ្ចេញសំរាមខុសពីម៉ោងនេះនឹងបានទទួលនូវការផាកពិន័យ។

ខណ្ឌជាយរាជធានីភ្នំពេញចំនួន ០៩រួមមាន ខណ្ឌឫស្សីកែវ ខណ្ឌសែនសុខ ខណ្ឌជ្រោយចង្វារ ខណ្ឌដង្កោ ខណ្ឌព្រែកព្នៅ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌកំបូល ខណ្ឌមានជ័យ និងខណ្ឌច្បារអំពៅ ក្រុមហ៊ុននឹងប្រមូល និងដឹកជញ្ជូនដូចខាងក្រោម៖

- **ផ្លូវជាតិ** ត្រូវប្រមូល និងដឹកជញ្ជូនរៀងរាល់ថ្ងៃ នៅពេលយប់ វេលាម៉ោង៩យប់ ដូច្នេះ ការបញ្ចេញសំរាមត្រូវចាប់ផ្តើមចន្លោះពីម៉ោង ៦យប់រហូតដល់ម៉ោង៩យប់
- **ផ្លូវធំ** ត្រូវប្រមូល និងដឹកជញ្ជូនរៀងរាល់ថ្ងៃ (ពេលថ្ងៃ វេលាម៉ោង៨ព្រឹក ឬ ពេលយប់ វេលាម៉ោង៩)
- **ផ្លូវរណប** ត្រូវប្រមូល និងដឹកជញ្ជូនរៀងរាល់ ០២ថ្ងៃ/១ម្តង (ពេលថ្ងៃ វេលាម៉ោង៨ព្រឹក ឬពេលយប់ វេលាម៉ោង៩)។

**សំរាម សំណល់រឹងស្ងួត** ក្រុមហ៊ុននឹងប្រមូល និងដឹកជញ្ជូន ២ដង/១សប្តាហ៍ គឺនៅរៀងរាល់ថ្ងៃចន្ទ និងថ្ងៃសុក្រ។

- ➢ ក្នុងករណីខកខានមិនបានបញ្ចេញសំរាម សំណល់រឹងតាមម៉ោងពេលកំណត់ (ពេលថ្ងៃត្រឹមម៉ោង៨ព្រឹក និងពេលយប់ ត្រឹមម៉ោង៩យប់) ត្រូវរង់ចាំបញ្ចេញនៅវេនក្រោយ ហើយមិនត្រូវយកសំរាមនេះមកទុកគ្មានសណ្តាប់ធ្នាប់ឡើយ។
- ➢ ចំពោះសំណល់ដើមឈើ និងមែកឈើ ត្រូវទុកដាក់ដោយឡែកឱ្យបានត្រឹមត្រូវ រួចធ្វើការទំនាក់ទំនងមកកាន់ខាងផ្នែករដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ តាមរយៈទូរស័ព្ទលេខ ០៨១ ៦៤៦ ២២២ ឬ០១១ ៦៤៦ ២២២ ឬកម្មវិធីទូរស័ព្ទដៃរបស់រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងក្នុង រាជធានីភ្នំពេញ(PPSWMA) ដើម្បីធ្វើការស្នើសុំប្រមូល និងដឹកជញ្ជូនចេញ។
- ➢ ចំពោះសំណល់សំណង់ អាចម៍ដី កំទេចថ្ម ខ្សាច់... ត្រូវទុកដាក់ដោយឡែកឱ្យបានត្រឹមត្រូវ រួចធ្វើការទំនាក់ទំនងមករដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ តាមរយៈទូរស័ព្ទលេខ

០៨១ ៦៤៦ ២២២ ឬ០១១ ៦៤៦ ២២២ ឬកម្មវិធីទូរស័ព្ទដៃរបស់រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ (PPSWMA) ដើម្បីធ្វើការស្នើសុំប្រមូល និងដឹកជញ្ជូនចេញ។

- ចំពោះសំណល់ជាគ្រឿងសង្ហារឹម គ្រឿងអេឡិចត្រូនិក គ្រឿងអគ្គិសនី សំបកកង់ និងវត្ថុកែច្នៃឡើងវិញ បានត្រូវទុកដាក់ដោយឡែកឱ្យបានត្រឹមត្រូវ រួចធ្វើការទំនាក់ទំនងមករដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ តាមរយៈទូរស័ព្ទលេខ ០៨១ ៦៤៦ ២២២ ឬ ០១១ ៦៤៦ ២២២ ឬកម្មវិធីទូរស័ព្ទដៃរបស់រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម សំណល់រឹង រាជធានីភ្នំពេញ (PPSWMA) ដើម្បីធ្វើការស្នើសុំប្រមូល និងដឹកជញ្ជូនចេញ។

ក្នុងករណីមិនអនុវត្តន៍តាមសេចក្តីណែនាំនេះ រដ្ឋបាលរាជធានីភ្នំពេញនឹងធ្វើការផាកពិន័យទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងអនុវត្តន៍វិធានការរដ្ឋបាល និងវិធានការណ៍នានាតាមការចាំបាច់ដទៃទៀតដូចជា ការបិទការធ្វើអាជីវកម្មជាបណ្តោះអាសន្ន។ល។[៣៥]

### ២.៣.១. ការបញ្ចេញសំណល់ និងកំណត់ទីតាំងស្តុកបណ្តោះអាសន្ន

ការបញ្ចេញសំរាម គឺជាកិច្ចការដែលប្រជាពលរដ្ឋគួរតែយកចិត្តទុកដាក់ដើម្បីឱ្យការប្រមូលសំរាមប្រព្រឹត្តទៅដោយរលូនជៀសវាងកើតមាននូវបញ្ហាណាមួយកើតឡើងដូចជា បង្កឱ្យមានការកកស្ទះចរាចរណ៍អំឡុងពេលក្រុមហ៊ុនប្រមូលសំរាមចេញប្រមូល ឬការទុកដាក់សំរាមគ្មានសណ្តាប់ធ្នាប់ដែលធ្វើឱ្យរាយប៉ាយនៅតាមទីសាធារណៈដែលធ្វើឱ្យខូចខាតដល់សោភ័ណភាពទីក្រុងម្ចាស់សំរាមត្រូវតែអនុវត្តន៍ដូចជាៈ

- ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវអនុវត្តន៍ការញែក និងការវេចខ្ចប់សំរាម សំណល់រឹងដែលអាចប្រើប្រាស់ឡើងវិញ ឬកែច្នៃបានដាច់ដោយឡែកពីសំរាមសំណល់រឹងដែលត្រូវបោះចោលទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។[៣៦]
- ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការវេចខ្ចប់ដោយថង់ ឬការដាក់នៅក្នុងធុងសំរាមផ្ទាល់ខ្លួននូវសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងលក្ខណៈហ្មត់ចត់មិនឱ្យលេចធ្លាយ មិនឱ្យលេចជ្រាបទឹកស្អុយ ឬមិនឱ្យមានភាយក្លិនស្អុយក្នុងរយៈពេលនៃការទុកដាក់រង់ចាំការបញ្ចេញទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។[៣៧]

---

[៣៥] សេចក្តីណែនាំ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ, លេខ ០២៥/២១ សណន.ស, ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១

[៣៦] អនុក្រឹត្យលេខ ១១៣ អនក្រ.បក, មាត្រា១៥

[៣៧] អនុក្រឹត្យលេខ ១១៣ អនក្រ.បក, មាត្រា១៦

- ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការរក្សាទុកនូវកញ្ចប់ ឬធុងផ្ទុកសំរាមសំណល់រឹងរបស់ខ្លួននៅក្នុងរបង ឬបរិវេណនៃលំនៅឋាន អគារ ឬទីតាំងរបស់ខ្លួន និងត្រូវបញ្ចេញទៅតាមម៉ោងពេលដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។
- រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការត្រួតពិនិត្យឱ្យបានម៉ឺងម៉ាត់លើការអនុវត្តការបញ្ចេញកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជនទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈរង់ចាំការប្រមូល និងដឹកជញ្ជូនទៅតាមពេលម៉ោងដែលបានកំណត់។[៣៨]
- ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនដែលប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។[៣៩]
- រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំដីកា ឬលិខិតបទដ្ឋាននានាដើម្បីណែនាំអនុវត្តន៍ការសម្អាត ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងនៅទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានលក្ខណៈឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃទីប្រជុំជននីមួយៗ និងត្រូវធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងលើកកម្ពស់ទៅដល់សោភ័ណភាពអនាម័យ និងបរិស្ថាននៅតាមទីប្រជុំជន។

ដីកា ឬលិខិតបទដ្ឋានខាងលើនេះត្រូវរៀបចំឡើងដោយអនុលោមទៅតាមគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសជាធរមាន។ ខាងរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវផ្សព្វផ្សាយដីកា ឬលិខិតបទដ្ឋាននានាដូចមានចែងក្នុងកថាខ័ណ្ឌខាងលើឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាឱ្យមានការចូលរួមអនុវត្តន៍ប្រកបទៅដោយការទទួលខុសត្រូវ។[៤០]

### ២.៣.១.១. ការញែកសំណល់ឱ្យបានត្រឹមត្រូវ

ដើម្បីធ្វើឱ្យប្រសើរឡើងនូវការវេចខ្ចប់សំរាម និងការបញ្ចេញសំរាមរបស់ប្រជាពលរដ្ឋ (អ្នកបង្កើតសំណល់) និងដើម្បីឱ្យការបញ្ចេញសំរាមមកទាន់ពេលវេលា និងមានប្រសិទ្ធភាពក្នុងការប្រមូលសំរាមដោយមានក្រុមហ៊ុនប្រមូលសំរាម។

[៣៨] អនុក្រឹត្យលេខ១១៣ អនក្រ.បក, មាត្រា១៧

[៣៩] អនុក្រឹត្យលេខ១១៣ អនក្រ.បក, មាត្រា១៨

[៤០] អនុក្រឹត្យលេខ១១៣ អនក្រ.បក, មាត្រា១៩

នៅរាជធានីភ្នំពេញ ការវេចខ្ចប់សំណល់ និងការបញ្ចេញសំរាមចោលត្រូវបានគេអនុវត្តន៍ដោយមិនទាន់ត្រឹមត្រូវទាំងនៅតាមផ្ទះ និងតាមទីសាធារណៈផងដែរ។

- អ្នករស់នៅក្នុងរាជធានីភ្នំពេញជាទូទៅពួកគេតែងតែដាក់បញ្ចូលសំណល់ផ្សេងគ្នាទៅក្នុងថង់ប្លាស្ទិក/ធុងតែមួយ។ គេដាក់លាយឡំគ្នានូវសំណល់សើម សំណល់ស្ងួត សំណល់អេឡិចត្រូនិក និងសំណល់គ្រោះថ្នាក់តាមលំនៅឋាន។ ករណីខ្លះ សំណល់ធំៗ ត្រូវបានបញ្ចេញចោលជាមួយសំណល់ទូទៅដោយមិនបានចងឱ្យបានត្រឹមត្រូវ។
- ប្រជាពលរដ្ឋត្រូវបានអនុញ្ញាតណែនាំឱ្យដាក់សំរាមនៅមុខផ្ទះ។ សម្រាប់អ្នករស់នៅជាន់ទី២ ឬខ្ពស់ជាងនេះអាចដាក់ក្បែរជណ្តើរប្រើរួមគ្នា។ ទោះជាយ៉ាងណាក៏ដោយសំណល់ទាំងនេះត្រូវបានគេនាំយកមកដាក់តាមដងផ្លូវ តាមមាត់លូ ឬកន្លែងទំនេរដើម្បីជៀសវាងកខ្វក់ផ្ទះរបស់ខ្លួន និងពិបាកក្នុងការឡើងជណ្តើរ។
- សំណល់ត្រូវដាក់ក្នុងស្បោងប្លាស្ទិក (ជាធម្មតាស្បោងចាស់ៗ) ឬក្នុងធុងដោយមិនបានចងថង់។ សំណល់រប៉ាត់រប៉ាយតាមធុងសំរាមដោយសារដាក់ច្រើនពេកបណ្តាលឱ្យខូះអនាម័យថែមទាំងខូចសោភ័ណភាព និងពិបាកក្នុងការប្រមូលដែលករណីនេះកើតឡើងភាគច្រើននៅពេលល្ងាច។
- ប្រជាពលរដ្ឋភាគច្រើននៅមិនទាន់យល់ដឹងពីទីតាំង និងពេលវេលាត្រូវបញ្ចេញសំរាមនៅឡើយ។
- ការអនុវត្តតាមគោលការណ៍បញ្ចេញចោលសំរាម សំណល់រឹង គឺមានតិចតួចណាស់នៅរាជធានីភ្នំពេញហើយមានប្រជាជនតែប្រមាណ ៣៦% ដែលត្រូវបានបណ្តុះបណ្តាល និងផ្តល់ព័ត៌មានអំពីការគ្រប់គ្រងសំណល់។ ជាលទ្ធផលសំណល់ត្រូវបានបញ្ចេញយឺតពេលដាក់រាយប៉ាយតាមផ្លូវ និងសំណល់ខ្លះត្រូវបានរាយប៉ាយដោយសារសត្វ និងអ្នករើសអេតចាយ។
- នៅតំបន់ទីផ្សាសាធារណៈខ្លះដែលក្រុមហ៊ុនប្រមូលសំរាមមិនអាចទៅប្រមូលដល់ទេសំរាមត្រូវបានបញ្ចេញចោលនៅតាមសង្កាត់ដោយដាក់ជាគំនរសំរាមតាមដងផ្លូវជាដើមដែលរំខានដល់ការធ្វើចរាចរណ៍នៅក្នុងតំបន់នោះផងដែរ។[៤១]

**ឧទាហរណ៍** សំរាមដែលមិនបានប្រមូលបង្កឱ្យមានផលប៉ះពាល់យ៉ាងសម្បើមទៅដល់អនាម័យ និងផ្នែកខាងបរិស្ថាននៅក្នុងតំបន់នោះ។ បន្ថែមពីនេះទៀតទម្លាប់ចាក់សំរាមដោយគ្មានសណ្តាប់ធ្នាប់ និងការទុកដាក់សំរាមមិនត្រឹមត្រូវ ឬរាយប៉ាយ គឺត្រូវបានចាក់ឫសគល់យ៉ាងជ្រៅក្នុងផ្នត់គំនិតប្រជាជនដែលពួកគាត់

[៤១] គេហទំព័រសាលារាជធានីភ្នំពេញ https://phnompenh.gov.kh/ ដកស្រង់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤

អាចបោះសំរាមចោលនៅលើផ្លូវ ឬមិនថានៅទីតាំងសាធារណៈក្តី ហើយក្នុងករណីខ្លះ ក៏មានការដាក់សំរាមនៅខាងក្រៅធុងសំរាមជាដើម។

- ការចោលសំរាមគ្មានសណ្តាប់ធ្នាប់នៅរាជធានីភ្នំពេញកើតឡើងរហូតក្លាយជាទម្លាប់មិនល្អមួយ និងជាសកម្មភាពតៗគ្នាទៅហើយកាលណាសកម្មភាពទាំងនេះកើតមានជាញឹកញាប់វាអាចនឹងជះឥទ្ធិពលដោយប្រយោលហើយទម្លាប់អាក្រក់នេះក៏រាលដាលទៅកាន់អ្នកដទៃផ្សេងៗទៀតផងដែរក្នុងការទទួលយកទម្លាប់បោះចោលសំរាមដូចគ្នាដែរ។
- យុទ្ធនាការការអប់រំ ឬការផ្សព្វផ្សាយនៅមានតិចតួចណាស់ដើម្បីអប់រំដល់សាធារណជនឱ្យទទួលខុសត្រូវលើផ្នែកបរិស្ថាន និងរបៀបរបបក្នុងការបញ្ចេញសំរាមចោលឱ្យបានត្រឹមត្រូវនោះ។
- ធុងដាក់សំរាមប្រភេទធំៗមួយចំនួនត្រូវបានដាក់នៅតាមទីតាំងសមស្របជាធុងធំដាក់សំរាមបណ្តោះអាសន្នបានយ៉ាងច្រើន។ ប៉ុន្តែជាទូទៅវាមានសភាពកខ្វក់ដោយសារសំរាមជ្រុះរាយប៉ាយដែលនៅជុំវិញធុងហើយជាលទ្ធផលមានការតវ៉ាច្រើនពាក់ព័ន្ធទៅនឹងអនាម័យហើយធុងធំៗទាំងនោះត្រូវបានចល័តយកទៅដាក់តាមទីតាំងផ្សេងៗទៀតដោយគ្មានការត្រួតពិនិត្យត្រឹមត្រូវ។

### ២.៣.១.២. ការរៀបចំទីតាំងទុកដាក់សំណល់បណ្តោះអាសន្ន

ការបង្កើតទីតាំងស្តុកសំណល់បណ្តោះអាសន្នក្នុងរាជធានីភ្នំពេញត្រូវរកទីកន្លែងណាដែលងាយស្រួលសម្រាប់រថយន្តប្រមូលសំរាម និងត្រូវបានអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន។

- រដ្ឋបាលខណ្ឌ/សង្កាត់នឹងបង្កើតផែនការប្រមូលសំរាម រួមទាំងរបៀបនៃការប្រមូលសំរាមផងដែរ ពីផ្ទះមួយទៅផ្ទះមួយ ឬការប្រមូលតាមទីតាំងប្រមូលផ្តុំ (ដោយប្រើប្រាស់ទីតាំងណាជាកន្លែងស្តុក និងប្រមូល)។
- ក្នុងតំបន់ទីប្រជុំជនក្រុង ការប្រមូលសំរាមពីផ្ទះមួយទៅមួយអាចរក្សាទុកឱ្យនៅដដែល ដោយគ្រាន់តែធ្វើការវេចខ្ចប់ឱ្យបានត្រឹមត្រូវ និងធ្វើការកំណត់ទីតាំងបណ្តោះអាសន្នណាមួយតូចល្មមសម្រាប់ការបញ្ចេញសំណល់។
- ខណៈពេលគេប្រមូលសំរាមពីផ្ទះមួយទៅផ្ទះមួយ (ដាក់លើចិញ្ចើមផ្លូវ) និងគរជាគំនរត្រូវបានអនុវត្តជាទូទៅនៅក្នុងតំបន់ទីប្រជុំក្រុង គេក៏សង្កេតឃើញមាននូវការប្រើធុងកុងទីន័រ គរជាគំនរបោះចោលដោយគ្មានសណ្តាប់ធ្នាប់ នៅតែបន្តមានជាធម្មតានៅក្នុងតំបន់ជាយរាជធានីភ្នំពេញ។

- រដ្ឋបាលខណ្ឌ និងសង្កាត់នឹងជួយសម្របសម្រួលការចាត់ចែងកំណត់ទីតាំងប្រមូលផ្តុំសំរាម ដោយបានស្វែងរកកិច្ចសហការ និងការយល់ព្រមពីអ្នករស់នៅក្បែរនោះ (អ្នកបង្កើតសំណល់) ព្រមទាំងបានជំនួយពីក្រុមហ៊ុនប្រមូលសំរាម និងរដ្ឋបាលរាជធានីភ្នំពេញ។
- ទីតាំងប្រមូលសំរាម គួរត្រូវបានរៀបចំឱ្យត្រូវទៅតាមកម្មវិធីប្រមូល
- ទីតាំងទាំងនេះអាចជាទីសាធារណៈ និងមានទីតាំងនៅក្បែរលំនៅឋានប្រជាពលរដ្ឋ (ដែលរស់នៅក្នុងរង្វង់ ១០០ ទៅ១៥០ ម៉ែត្រ) អាចយកសំណល់មកចាក់បាន មុនពេលឡានមកប្រមូល។
- បន្ថែមទៅលើទីតាំងបណ្តោះអាសន្ន រដ្ឋបាលរាជធានីនឹងធ្វើការជាមួយរដ្ឋបាលខណ្ឌ/ សង្កាត់ ស្វែងរកទីតាំងដាក់លាក់សម្រាប់ធុងស្តុកធំៗ ដែលប្រជាពលរដ្ឋ ឬអ្នកលក់ដូរចល័តអាចយកសំណល់មកចាក់ក្រៅពីពេលវេលាប្រមូលធម្មតា ទៅតាមលទ្ធភាពជាក់ស្តែង។
- នៅជាយរាជធានី ប្រជាពលរដ្ឋអាចប្រើធុង/កេសសំរាម ដើម្បីចំណេញពេលវេលាប្រមូល និងមានភាពងាយស្រួល។ ប្រជាពលរដ្ឋម្នាក់ៗអាចយកសំរាមមកបញ្ចេញដាក់ទៅក្នុងធុងស្តុក ឬក៏មានរទេះដឹកសំរាមតូចៗប្រមូលពីផ្ទះមួយទៅផ្ទះមួយទៀត បន្ទាប់មកគេផ្ទេរវាដាក់ធុងកុងទឺន័រ។ សាលារាជធានីនឹងធ្វើការជាមួយរដ្ឋបាលខណ្ឌ/សង្កាត់ ដើម្បីធានាទីតាំងប្រមូលសំរាម និងការរៀបចំឱ្យបានសមរម្យ ដើម្បីឱ្យប្រជាពលរដ្ឋ និងរទេះដឹកសំរាមមានភាពងាយស្រួលក្នុងការចូលមកដឹកសំណល់
- រដ្ឋបាលរាជធានីភ្នំពេញ ត្រូវធ្វើការយ៉ាងស្អិតរមួតជាមួយរដ្ឋបាលខណ្ឌ/ សង្កាត់ និងក្រុមហ៊ុននឹងបានកែសម្រួលកម្មវិធីប្រមូលសំរាមសម្រាប់ទីតាំងទាំងអស់ក្នុងរាជធានីភ្នំពេញ។ នាពេលបច្ចុប្បន្ន ការប្រមូលប្រចាំថ្ងៃត្រូវគេប្រមូលនៅក្នុងទីប្រជុំជន ឯតំបន់ជាយរាជធានីភ្នំពេញគេប្រមូលប្រហែល ៣ដងនៅក្នុងមួយសប្តាហ៍។ កម្មវិធីប្រមូលសំរាមត្រូវធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយតាមរយៈរដ្ឋបាលខណ្ឌ សង្កាត់ និងប្រឹក្សាជាមួយនឹងក្រុមហ៊ុនប្រមូលសំរាម និងរដ្ឋបាលរាជធានីភ្នំពេញ ដើម្បីសម្រេចបាននូវភាពស៊ីសង្វាក់ និងល្អប្រសើរនៅទូទាំងរាជធានីភ្នំពេញ
- រដ្ឋបាលរាជធានីភ្នំពេញ ក៏នឹងបង្កើតកាលវិភាគប្រមូលសំណល់កែច្នៃពីតាមលំនៅឋាន សំណល់សំពីងសំពោង និងសំណល់គ្រោះថ្នាក់ ដែលត្រូវការនូវវេចខ្ចប់ និងពេលវេលាបញ្ចេញ។[៤២]

### ២.៣.១.៣. ពង្រឹងវិធានការប្រឆាំងការបោះចោលសំរាមគ្មានសណ្តាប់ធ្នាប់

ការចោលសំរាមពាសវាលពាសកាល ផ្តល់ផលប៉ះពាល់ច្រើនណាស់ ទាំងសម្រាប់គ្រួសារនិងសង្គមជាតិ។ សម្រាប់គ្រួសារ វាជាការបង្ហាញពីរបៀប ឬទម្លាប់មិនល្អនៃការរស់នៅទាក់ទងនឹងបរិស្ថាន និងអនាម័យ។

[៤២] គេហទំព័រសាលារាជធានីភ្នំពេញ https://phnompenh.gov.kh/ ដកស្រង់ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៤

លើសពីនេះ វាក៏អាចបង្កផលប៉ះពាល់ដល់សុខភាព ធ្វើឱ្យកើតជំងឺផ្សេងៗដូចជា កម រមាស់ និងបញ្ហាផ្លូវដង្ហើម ជាដើម។ ដោយឡែកសម្រាប់សង្គមជាតិវិញ មិនត្រឹមតែធ្វើឱ្យបាត់បង់នូវសោភ័ណភាពទីសាធារណៈ និង រមណីយដ្ឋានប៉ុណ្ណោះនោះទេ ក៏ប៉ុន្តែវាបានបង្ហាញពីកម្សោយរបស់អាជ្ញាធរ ក្នុងការគ្រប់គ្រងសំរាមផងដែរ។ ប្រជាពលរដ្ឋត្រូវបង្កើតទម្លាប់ស្រឡាញ់អនាម័យ តាមរយៈការបោះចោលសំរាមនៅក្នុងធុងឱ្យបានត្រឹមត្រូវ។ គ្រួសារ និងស្ថាប័នអប់រំ ក៏ត្រូវរួមចំណែកបង្កើតទម្លាប់នេះដែរ។ ដោយឡែក អាជ្ញាធរមូលដ្ឋានជាពិសេស ត្រូវតែ បន្តការអប់រំដល់ប្រជាពលរដ្ឋ និងបង្កើនបរិមាណធុងសំរាមឱ្យបានគ្រប់គ្រាន់ តាមតម្រូវការរបស់ប្រជាពលរដ្ឋ។

- ចែកចាយធុងដាក់សំរាម និងផ្ទាំងសញ្ញា ឬផ្ទាំងបដាដាក់នៅទីសាធារណៈ ស្តីពីការចោលសំរាមគ្មាន សណ្តាប់ធ្នាប់ ឬមិនត្រឹមត្រូវតាមរយៈកិច្ចសហការស្មិតរមួតជាមួយវិស័យឯកជន។ ស្លាកសញ្ញាគួរធ្វើឱ្យ គេមើលឃើញ និងធំល្មម ដើម្បីភាពទាក់ទាញចំណាប់អារម្មណ៍របស់ប្រជាពលរដ្ឋទូទៅ
- ធានានូវការអនុវត្ត និងការពង្រឹងច្បាប់ក៏ដូចជាការកែតម្រូវនៅពេលដែលចាំបាច់លើបទបញ្ញត្តិដែល មានស្រាប់ និងសេចក្តីណែនាំស្តីពីការបោះចោលសំរាម និងការផាកពិន័យជាប្រាក់ផ្សេងៗ ដូចជា៖
    - សេចក្តីជូនដំណឹង ស្តីពីការទុកដាក់ ការសម្អាត ការបញ្ចេញសំរាម និងការពិន័យទៅលើការ ចោលសំរាមដែលគ្មានសណ្តាប់ធ្នាប់នៅក្នុងរាជធានីភ្នំពេញ លេខ ១៣ សជណ.គកស (ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៣)
    - ផែនការណែនាំ ស្តីពីការអនុវត្តការផាកពិន័យ ដើម្បីផ្សព្វផ្សាយបញ្ហាអនាម័យបរិស្ថានដែល មាននៅក្នុងរាជធានីភ្នំពេញ លេខ ០៩ ផកណន.ស (ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០១០)
    - សេចក្តីណែនាំ ស្តីពីការផាកពិន័យលើការបោះចោលសំណល់ក្នុងទីធ្លាសាធារណៈដែលមាន លេខ ១៦ សជណ.ស (ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១០)
    - ប្រាក់ពិន័យដែលបានប្រមូល ត្រូវប្រើសម្រាប់ប្រយោជន៍គាំទ្រការអនុវត្តការងារគ្រប់គ្រងសំរាម សំណល់រឹង និងការសិក្សាស្រាវជ្រាវ។ ដើម្បីធានានូវអនុលោមភាព ត្រូវការទាមទារឱ្យមាននូវ កិច្ចសហការក្នុងចំណោមភាគីពាក់ព័ន្ធ ដូចជានគរបាល ប្រធានភូមិ សង្កាត់ និងខណ្ឌជាដើម
    - ប្រសិនបើអាចធ្វើបាន រដ្ឋបាលរាជធានីភ្នំពេញអាចដំឡើងកាមេរ៉ានៅតាមទីសាធារណៈដើម្បី អាចត្រួតពិនិត្យការបោះចោលសំរាម ឬសកម្មភាពចាក់សំរាមដោយគ្មានសណ្តាប់ធ្នាប់។[៤៣]

[៤៣] គេហទំព័រសាលារាជធានីភ្នំពេញ https://phnompenh.gov.kh/ ដកស្រង់ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៤

### ២.៣.២. ការធ្វើឱ្យប្រសើរនូវសេវាប្រមូលសំណល់ សម្អាតផ្លូវ និងទីសាធារណៈ

តាមប្រកាសអន្តរក្រសួងលេខ ៨០រវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាននៅក្នុងឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសំរាម និងកាកសំណល់រឹងនៅថ្នាក់ខេត្ត ក្រុង មានវិសាលភាពគ្រប់គ្រងសំណល់រឹងទាំងឡាយដោយរាប់បញ្ចូលទាំងការប្រមូល ការសម្អាត ការស្តុកទុកបណ្តោះអាសន្ន ការដឹកជញ្ជូន ការកែច្នៃ និងការបោះចោលសំរាមសំណល់រឹងគ្រប់ប្រភេទ ដែលមានគោលបំណងលើកកម្ពស់ការទទួលខុសត្រូវរបស់ខាងអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចដែលពាក់ព័ន្ធនានា ក្នុងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងនៅថ្នាក់ រាជធានីខេត្ត ក្រុងប្រកបដោយប្រសិទ្ធភាពទូទាំងប្រទេស។[៤៤]

#### ២.៣.២.១. ការកែលម្អផែនការប្រតិបត្តិការ និងការប្រមូលសំណល់ឱ្យល្អប្រសើរ

នៅក្នុងរាជធានីភ្នំពេញចំពោះសេវាការប្រមូលសំណល់បច្ចុប្បន្ន និងសេវាសម្អាតតាមផ្លូវ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុនសំរាមធំៗចំនួន ០៣។ ចំណែកឯទីតាំងសាធារណៈ និងសួនស្ថិតនៅក្រោមមន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ ហើយអ្នកម៉ៅការឯកជនមួយចំនួនទៀត ត្រូវបានប្រគល់ភារកិច្ចក្នុងការផ្តល់សេវាប្រមូលសំរាម ដែលមានទ្រង់ទ្រាយតូចៗពីទីតាំងជាក់លាក់ណាមួយ (**ឧទាហរណ៍** ក្នុងផ្សាររបស់រដ្ឋ ឬឯកជន) រីឯការដឹកជញ្ជូន និងការចាក់ចោលសំរាមចុងក្រោយទៅកាន់ទីលានចាក់សំរាមដែលកំណត់ដោយរដ្ឋបាលរាជធានីភ្នំពេញ។

ការអនុវត្តបច្ចុប្បន្ន សំរាមគ្រប់ប្រភេទត្រូវបានដាក់ជាមួយគ្នា វេចខ្ចប់ និងបញ្ចេញទៅឱ្យក្រុមហ៊ុនប្រមូល តែទោះយ៉ាងណាក៏នៅមានបញ្ហាប្រឈមមួយចំនួន ដែលកើតមានពីសេវាកម្មប្រមូលសំរាមនាពេលបច្ចុប្បន្ន៖

- ក្រុមហ៊ុនស៊ីនទ្រីមានឡានដឹកសំរាមច្រើនប៉ុន្តែភាគច្រើនចាស់ៗ និងមានបញ្ហាច្រើន។ ឡានខូចញឹកញាប់ដែលរាំងស្ទះដល់ការប្រមូលឱ្យបានទៀងទាត់។
- សំណល់ដែលបោះចោលក្នុងរាជធានីភាគច្រើនសើមមានជាតិទឹកលើសពី ៦០%។ ដោយមានអាងស្តុកទឹកសំអុយតូចមួយនៅពីក្រោមផ្នែកខាងក្រោយនៃរថយន្តទឹកសំអុយទាំងនេះស្រក់តាមផ្លូវពេលដឹកនាំឱ្យមានមតិរិះគន់ពីសាធារណជនអំពីបញ្ហាអនាម័យ។

---

[៤៤] ប្រកាសអន្តរក្រសួងលេខ៨០ រវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាននៅក្នុងឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសំរាម និងកាកសំណល់រឹងនៅថ្នាក់ខេត្ត ក្រុង

- ក្រុមហ៊ុនប្រមូលសំរាមបានផ្តល់កាលវិភាគប្រមូលសំរាមនៅទូទាំងរាជធានី ប៉ុន្តែប្រឈមជាមួយបញ្ហាមួយចំនួនដូចជា ការស្ទះចរាចរណ៍ ផ្លូវតូចចង្អៀត ពិបាកចូលប្រមូលខ្វះកម្លាំងពលកម្ម និងឆ្ងាយពីទីលានជាដើម។
- ក្រុមហ៊ុនប្រមូលសំរាម ប្រើកម្លាំងកម្មករច្រើនក្នុងប្រតិបត្តិការប្រមូលសំណល់ ដោយសារតែការវេចខ្ចប់ និងការទុកដាក់សំណល់ក្នុងរាជធានីមិនបានត្រឹមត្រូវ។ កម្មករជាច្រើនត្រូវចូកសម្អាតសំណល់នៅលើថ្នល់ទៅក្នុងឡានដឹក ឬដើររើសសំណល់ដែលដាក់រាយប៉ាយដោយដៃទទេ។
- កម្មកររបស់ក្រុមហ៊ុនប្រមូលសំរាមដែលត្រូវទទួលខុសត្រូវក្នុងការប្រមូលសំណល់ដាក់ក្នុងឡានដឹកជាទូទៅឈរពីក្រោយឡានរើសសំណល់ដែលអាចកែច្នៃបាន។ សកម្មភាពនេះធ្វើឱ្យប្រតិបត្តិការប្រមូលមិនសូវមានប្រសិទ្ធភាព និងមិនសូវល្អចំពោះសេវាកម្មប្រមូលសំរាមក្នុងរាជធានីភ្នំពេញ។
- អ្នកលក់ដូរចល័តជាពិសេសនៅតាមសួនច្បារសាធារណៈតែងទុកដាក់សំណល់ពួកគេចោលពាសវាលគ្មានសណ្តាប់ធ្នាប់តម្រូវឱ្យមានកម្លាំងបន្ថែមមកជួយសម្អាត។

ណែនាំក្នុងការកែលម្អឱ្យផែនការប្រតិបត្តិការ និងប្រមូលដែលមានស្រាប់កាន់តែប្រសើរឡើងសម្រាប់ខណ្ឌនីមួយៗរួមមានការរៀបចំកាលវិភាគប្រមូលសំណល់កំណត់ទីតាំងប្រមូលរួមគ្នា( ទីតាំងសមរម្យអាចធ្វើទៅបាន ) និងប្រព័ន្ធផ្លូវប្រមូលសំរាមដោយមានការសហការគ្នារវាងក្រុមហ៊ុនប្រមូលសំរាម និងរដ្ឋបាលខណ្ឌ

- រៀបចំកាលវិភាគប្រមូលសំរាម រដ្ឋបាលរាជធានីភ្នំពេញបានសហការជាមួយរដ្ឋបាលខណ្ឌ/សង្កាត់ និងក្រុមហ៊ុននឹងបង្កើតផែនការប្រមូលសំរាមដោយមានកាលវិភាគច្បាស់លាស់ និងគោលការណ៍ណែនាំស្តីអំពីការវេចខ្ចប់ និងការទុកដាក់សំរាម សំណល់រឹង។ **ឧទាហរណ៍** រដ្ឋបាលរាជធានីភ្នំពេញនឹងឱ្យខាងរដ្ឋបាលខណ្ឌ សង្កាត់ធ្វើការជាមួយក្រុមហ៊ុនប្រមូលសំរាមក្នុងការបង្កើតនូវផែនការប្រមូលសំរាម សំណល់រឹង ដោយយកចិត្តទុកដាក់ទៅលើចំណុចដូចតទៅ មានមធ្យោបាយឧបករណ៍ប្រមូលផ្សេងៗ ការរៀបចំផ្លូវដឹកជញ្ជូន ប្រតិបត្តិការនូវការអនុវត្តប្រមូលសំណល់អាស្រ័យលើប្រភពបញ្ចេញសំណល់ ការសម្អាតនៅទីតាំងទុកដាក់សំណល់ឱ្យបានស្អាត ការទុកដាក់ឧបករណ៍ប្រមូល ការបណ្តុះបណ្តាល ឬគ្រប់គ្រងកម្មករឱ្យបានត្រឹមត្រូវ ឧបករណ៍ការពារសុវត្ថិភាពអនាម័យសម្រាប់កម្មករ និងមានបទដ្ឋានសុវត្ថិភាពការពារ។
- សម្រាប់តំបន់ដែលយូរៗត្រូវប្រមូលម្តង ( គម្លាតរវាងរយៈពេលចាក់សំរាម និងរយៈពេលទៅប្រមូល ) ក្រុមហ៊ុនប្រមូលសំរាម និងរដ្ឋបាលខណ្ឌគួរណែនាំពីវិធានការសន្សំសំចៃដើម្បីទុកដាក់សំណល់ដែលមិនប៉ះពាល់ដល់សោភ័ណភាពសាធារណៈ។ ជូនដំណឹងដល់សាធារណជនឱ្យបានដឹងនូវកាលវិភាគ

ប្រមូលតាមរយៈការបិទផ្សាយតាមគេហទំព័ររបស់រដ្ឋបាលរាជធានីភ្នំពេញ និងក្រុមហ៊ុនផ្ទាល់ហើយផ្សាយតាមកម្មវិធីទូរស័ព្ទដៃ និងផ្សព្វផ្សាយតាមបណ្តាញសង្គម និងខិត្តប័ណ្ណផ្សេងៗទៀត។

- រៀបចំផែនការ/កាលវិភាគបោសសម្អាតតាមដងផ្លូវ និងតាមទីសាធារណៈ រដ្ឋបាលរាជធានីភ្នំពេញនឹងកំណត់ឱ្យបានច្បាស់លាស់នូវតួនាទី និងការទទួលខុសត្រូវរបស់ក្រុមហ៊ុន និងមន្ទីរពាក់ព័ន្ធ (មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ។ រដ្ឋបាលរាជធានីភ្នំពេញធ្វើការជិតស្និទ្ធជាមួយរដ្ឋបាលខណ្ឌ/សង្កាត់ និងអង្គភាពពាក់ព័ន្ធខាងលើរៀបចំផែនការ និងការសម្អាតតាមដងផ្លូវ និងសួនសាធារណៈឱ្យបានប្រសើរឡើង។ កាលវិភាគ និងផែនការខាងលើត្រូវដើរស្របនឹងកាលវិភាគប្រមូលសំរាម និងសៀវភៅគោលការណ៍ណែនាំពីការវេចខ្ចប់ និងទុកដាក់សំរាម សំណល់រឹង។
- ករណីសម្អាតថ្នល់ រដ្ឋបាលរាជធានីភ្នំពេញនឹងធានាថា ក្រុមហ៊ុនមានសមត្ថភាព និងអាចចាត់ចែងធនធានគ្រប់គ្រាន់ដើម្បីអនុវត្តន៍ការងារ។ ក្នុងលក្ខខណ្ឌនេះ រដ្ឋបាលរាជធានីភ្នំពេញត្រូវសិក្សាលម្អិត និងវាយតម្លៃសំណើគម្រោងសម្អាតថ្នល់ឡើងវិញតាមរយៈការយកចិត្តទុកដាក់លើ សេវាគ្របដណ្តប់ មានមធ្យោបាយ/ឧបករណ៍ប្រមូលផ្សេងៗ ការបណ្តុះបណ្តាល ឬគ្រប់គ្រងកម្មករឱ្យបានត្រឹមត្រូវ ឧបករណ៍ការពារសុវត្ថិភាពកម្មករ និងអនាម័យ និងបទដ្ឋានសុវត្ថិភាព/ការពារ។
- សម្រាប់ផ្លូវដែលត្រូវសម្អាត គឺអាស្រ័យលើសារៈសំខាន់នៃផ្លូវចំពោះសាធារណៈ ឬមានសោភ័ណភាពនៃទីក្រុង។ រដ្ឋបាលរាជធានីភ្នំពេញនឹងរៀបចំផែនទីបង្ហាញផ្លូវមួយដែលចង្អុលបង្ហាញពីថ្នល់ដែលត្រូវសម្អាតដើម្បីឱ្យក្រុមហ៊ុនដឹងថាត្រូវសម្អាតថ្នល់មួយណា។
- ការគាំទ្រពីអាជ្ញាធរមូលដ្ឋានរាជធានីត្រូវធានាឱ្យបានដើម្បីកំណត់ទីតាំងសម្រាប់រទេះសំរាម និងដឹកជញ្ជូនទៅផ្ទេរដាក់ឡាន។
- រដ្ឋបាលខណ្ឌ/សង្កាត់ ត្រូវកំណត់ទីតាំង និងថែទាំទីតាំងស្តុកសំរាមបណ្តោះអាសន្ន។
- ត្រួតពិនិត្យតម្លាភាពសេវាកម្មរបស់ក្រុមហ៊ុនប្រមូលសំរាមមានន័យថា រដ្ឋបាលរាជធានីភ្នំពេញគួរត្រួតពិនិត្យ ថាតើក្រុមហ៊ុនផ្តល់សេវាកម្មត្រឹមត្រូវដល់ម្ចាស់លំនៅឋានទាំងអស់ដែរឬទេ ហើយថាអាចមានភាពអសកម្មណាខ្លះដែលអាចការពារបាន និងហាមឃាត់ ឬធានាឱ្យមានការផ្តល់សេវាបានស្មើៗគ្នានៅក្នុងទូទាំងរាជធានីភ្នំពេញ។ **ឧទាហរណ៍** ធានាថាបុគ្គលិកប្រមូលលុយរបស់ក្រុមហ៊ុនប្រមូលសំរាមគ្មានស៊ីសំណូកពីម្ចាស់លំនៅឋាន ដោយមិនផ្តល់សេវាកម្មល្អតែនៅទីតាំងដែលឱ្យលុយថែមក្រៅ។[៩៥]

[៩៥] គេហទំព័រសាលារាជធានីភ្នំពេញ https://phnompenh.gov.kh/ ដកស្រង់ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៤

### ២.៣.២.២. ការពិនិត្យនូវថ្លៃសេវាកម្មដើម្បីឱ្យការប្រមូលមានប្រសិទ្ធភាពខ្ពស់

ធ្វើឱ្យសេវាប្រមូលសំរាមមានភាពប្រសើរឡើងដោយធានាឱ្យបានថា សំរាម សំណល់រឹងទាំងអស់ត្រូវបានប្រមូលយកទាំងស្រុង។ សេវាប្រមូលគួរគ្របដណ្តប់ ១០០% នៃទីតាំងលំនៅឋានស្ថិតនៅក្នុងដែនរដ្ឋបាលរាជធានីភ្នំពេញ។ លើសពីនេះទៀត ផ្លូវនិងទីសាធារណៈគួរតែត្រូវបានសម្អាតឱ្យបានទៀងទាត់ និងអាចទទួលយកបានជាសាធារណៈ និងត្រូវពិនិត្យមើលដូចជា៖

- ការពិនិត្យឡើងវិញនូវថ្លៃសេវាកម្មដើម្បីឱ្យការប្រមូលសំរាមមានប្រសិទ្ធភាពខ្ពស់ការវិភាគសេដ្ឋកិច្ចទៅលើប្រព័ន្ធថ្លៃសេវាកម្មអាចធ្វើបានដើម្បីកំណត់ថ្លៃឈ្នួលសេវាកម្មដែលមានភាពជាក់លាក់មួយក្នុងការធានាឱ្យបាននូវនិរន្តរភាព និងភាពពេញលេញនៃការប្រមូលសំរាមដែលផ្តល់ឱ្យអតិថិជន។ សម្រាប់ក្រុមហ៊ុនប្រមូលសំរាមអាចចូលរួមបានតាមរយៈការបង្ហាញរបាយការណ៍ប្រតិបត្តិការរបស់ខ្លួនដើម្បីតម្លាភាពនឹងជួយដល់ការដាក់ថ្លៃសេវាឱ្យបានប្រសើរ។ វិធីសាស្ត្រពីរយ៉ាងដែលត្រូវបានគេអនុវត្តន៍បានជោគជ័យលើប្រព័ន្ធកំណត់តម្លៃសេវាប្រមូល គឺការកំណត់តម្លៃដែលផ្តោតទៅលើបរិមាណ និងការកំណត់តម្លៃដែលគិតលើទម្ងន់។
- សម្រាប់ការកំណត់តម្លៃដោយគិតលើបរិមាណ គឺជាថ្លៃប្រមូលសំរាមគ្រួសារនីមួយៗដែលអាស្រ័យលើចំនួនស្បោងសំរាមដែលបានបញ្ចេញចោល និងទំហំរបស់ថង់នីមួយៗ។ ថង់សំរាមកាន់តែតូចហើយសំរាមកាន់តែតិចនោះអ្នកប្រើប្រាស់នឹងបង់ថ្លៃប្រមូលសំរាមកាន់តែតិច។ សម្រាប់ការកំណត់តម្លៃដោយគិតទៅតាមទម្ងន់ គឺជាការគិតថ្លៃប្រមូលសំរាមតាមរយៈទម្ងន់សំរាមដែលបានបញ្ចេញចោល។ ចំពោះកម្រិតនៃការប្រើប្រាស់ប្រជាពលរដ្ឋត្រូវបានលើកទឹកចិត្តក្នុងការបញ្ចេញសំរាមចោលកាន់តែតិចបំផុតតាមដែលអាចធ្វើទៅបាន តាមរយៈការកែច្នៃប្រើប្រាស់សំណល់ឡើងវិញ។
- ការប្រែប្រួលតម្លៃសេវាកម្ម ការវាយតម្លៃអាស្រ័យលើប្រភេទអាជីវកម្ម និងទំហំអាជីវកម្មដើម្បីកំណត់ថ្លៃសេវាដែលត្រូវបង់ជំនួសឱ្យការដាក់តម្លៃមួយសម្រាប់គ្រប់អាជីវកម្ម។
- នៅពេលច្បាប់នៃការញែកសំរាមត្រូវបានគេដាក់ឱ្យអនុវត្តន៍អត្រាតម្លៃអាចត្រូវកំណត់ខុសៗគ្នាចំពោះអ្នកបង្កើតសំរាមណាដែលញែកសំរាម (អត្រាទាប) និងអ្នកដែលមិនបានញែក (អត្រាខ្ពស់) ដែលនឹងជំរុញឱ្យបង្កើនការញែកសំណល់កាន់តែល្អប្រសើរនៅតាមផ្ទះ។
- សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវលើការងារគ្រប់គ្រងសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងបរិស្ថានល្អ។

- ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រដ្ឋបាលរាជធានី ក្រុង ស្រុកអាចៈ
  - រៀបចំ និងប្រតិបត្តិការដោយរដ្ឋបាលរបស់ខ្លួនផ្ទាល់នូវមុខងារមួយផ្នែក ឬទាំងស្រុងនៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
  - ធ្វើកិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀតដែលមានព្រំប្រទល់រដ្ឋបាលជាប់គ្នានៅក្នុងការផ្តល់សេវារួមជាមួយគ្នា។
  - ផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូន ឬ/និងសេវាទីលានទុកដាក់សំរាមចំពោះសំណល់រឹងទីប្រជុំជនទៅឱ្យផ្នែកឯកជន ជាអ្នកទទួលបន្ទុកអនុវត្តន៍។
  - ផ្ទេរមុខងារមួយផ្នែក ឬក៏ទាំងស្រុងនៅក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យខាងរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ឬផ្តល់សិទ្ធិទៅឱ្យសហគមន៍អនុវត្តន៍នូវមុខងាររងណាមួយ ឬមួយចំនួនមុខងារគ្រប់គ្រងសម្រាប់សំរាមសំណល់រឹងទីប្រជុំជន។
- ការផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូនសំរាម សំណល់រឹងក្នុងទីប្រជុំជនដែលត្រូវមានរយៈពេលមិនលើសពី១០ឆ្នាំក្នុងកិច្ចសន្យាមួយលើក និងត្រូវអនុវត្តន៍ទៅតាមវិធីសាស្ត្រ និងមាននីតិវិធីលទ្ធកម្មជាធរមាន។
- រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយផ្អែកលើតម្លៃសេវាអតិបរមា ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់តម្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនសម្រាប់អនុវត្តន៍នៅក្នុងតំបន់មូលដ្ឋានរបស់ខ្លួន ដោយគោរពតាមគោលការណ៍ដូចខាងក្រោមៈ
  - ត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
  - ធានាប្រសិទ្ធភាព និងគុណភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
  - កំណត់តម្លៃលើសេវាផ្អែកតាមប្រភេទអាជីវកម្ម ទីតាំង កម្រិតប្រាក់ចំណូល បរិមាណនៃសំរាម សំណល់រឹងទីប្រជុំជន ដែលនឹងត្រូវបញ្ចេញ ត្រូវមានការពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សារបស់ខ្លួន។[៩៦]

[៩៦] គេហទំព័រសាលារាជធានីភ្នំពេញ https://phnompenh.gov.kh/ ដកស្រង់ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤

#### ២.៣.២.៣. ការកំណត់លើភាពជាដៃគូរជាមួយក្រុមហ៊ុនប្រមូលសំរាម

ដំណើរការនេះអាចទទួលបានជោគជ័យតាមរយៈការបង្កើតគុណតម្លៃសំណល់ ការបែងចែកទីផ្សារទៅតាមតំបន់ឱ្យក្រុមហ៊ុនប្រមូលសំរាមនានា ឬបង្កើតឱ្យមានការដាក់ដេញថ្លៃជំរុញការប្រកួតប្រជែង។

- ការដាក់ដេញថ្លៃ រដ្ឋបាលរាជធានីភ្នំពេញ និងវាយតម្លៃនូវលទ្ធភាពនៃការដាក់ឱ្យមានការដេញថ្លៃប្រកបដោយការប្រកួតប្រជែងទៅលើក្រុមហ៊ុនសេវាប្រមូលសំរាម។ ទោះជាយ៉ាងណាក៏ដោយ ចំពោះកិច្ចសន្យាជាមួយក្រុមហ៊ុនស៊ីនទ្រីនឹងមិនត្រូវបញ្ចប់ឆាប់ៗនេះឡើយដូចនេះយុទ្ធសាស្ត្រនេះអាចមានប្រសិទ្ធភាពនៅក្នុងរយៈពេលវែងមួយ។ យុទ្ធសាស្ត្រនេះរដ្ឋបាលរាជធានីភ្នំពេញអាចបែងចែកទីតាំងក្នុងរាជធានីភ្នំពេញជាច្រើនតំបន់ (ខណ្ឌ/សង្កាត់) ហើយប្រកាសឱ្យក្រុមហ៊ុននានាដាក់ពាក្យដេញថ្លៃសម្រាប់តំបន់នីមួយៗ។ ដំណើការនេះ និងធ្វើឱ្យរដ្ឋបាលរាជធានីភ្នំពេញត្រូវពិនិត្យមើលគ្រប់ក្រុមហ៊ុនទាំងអស់ និងជ្រើសរើសយកក្រុមហ៊ុនដែលល្អជាងគេ។ បន្ថែមពីនេះការអនុញ្ញាតឱ្យក្រុមហ៊ុនតែមួយទទួលខុសត្រូវសម្រាប់តំបន់ណាមួយជាក់លាក់នោះ និងជំរុញឱ្យក្រុមហ៊ុនទាំងអស់អនុវត្តន៍សេវាកម្មប្រមូលសំរាមមានប្រសិទ្ធភាពល្អ។ ការជំរុញវិនិយោគក្នុងវិស័យនេះ ក៏អាចកសាង និងបង្កើនគុណតម្លៃសំណល់ក្នុងទីផ្សារបានផងដែរ។
- ស្វែងរកលទ្ធភាពផ្តួចផ្តើមកិច្ចសន្យាជាមួយក្រុមហ៊ុនប្រមូលសំរាមថ្មីមួយ សម្រាប់ប្រភេទសំណល់ដែលមិនត្រូវបានប្រមូលដោយក្រុមហ៊ុនប្រមូលសំរាមបច្ចុប្បន្ន ដូចជាប្រភេទនៃសំណល់ដែលមានភាពសំពីងសំពោង។[៤៧]

## ២.៤. បញ្ហាប្រឈម និងដំណោះស្រាយ

រាជធានីភ្នំពេញ ដែលជារាជធានីនៃប្រទេសកម្ពុជា ប្រឈមមុខនឹងបញ្ហាប្រឈមជាច្រើនក្នុងការគ្រប់គ្រងសំណល់រឹង-រាវ ដោយសារនគរូបនីយកម្ម កំណើនប្រជាជន និងការអភិវឌ្ឍសេដ្ឋកិច្ច។ ការកើនឡើងនៃបរិមាណសំណល់ដែលបានបង្កើតបានលើសពីសមត្ថភាពនៃប្រព័ន្ធគ្រប់គ្រងកាកសំណល់ដែលមានស្រាប់ដែលនាំឱ្យមានការបំពុលបរិស្ថាន និងការព្រួយបារម្ភអំពីសុខភាពសាធារណៈ។

### ២.៤.១. បញ្ហាប្រឈម

រាជធានីភ្នំពេញប្រឈមមុខនឹងបញ្ហាប្រឈមសំខាន់ៗក្នុងការគ្រប់គ្រងសំណល់រឹង-រាវ ដោយសារមានកត្តាផ្សេងៗដូចជា កំណើនប្រជាជន ការកើនឡើងកម្រិតប្រាក់ចំណូល នគរូបនីយកម្ម និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងសំណល់មិនគ្រប់គ្រាន់។ បញ្ហាប្រឈមរួមមាន៖

---

[៤៧] គេហទំព័រសាលារាជធានីភ្នំពេញ https://phnompenh.gov.kh/ ដកស្រង់ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២៤

- **កង្វះហេដ្ឋារចនាសម្ព័ន្ធត្រឹមត្រូវ** នគរូបនីយកម្ម និងកំណើនប្រជាជនមានការកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងទីក្រុងភ្នំពេញបានរាំងរាដាច់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងសំណល់គ្រប់គ្រាន់។ ទាំងនេះអាចបណ្ដាលឱ្យមានសម្ភារបរិក្ខារមិនគ្រប់គ្រាន់សម្រាប់ការប្រមូល ការដឹកជញ្ជូន ការកែច្នៃនិងការចោលកាកសំណល់រឹង-រាវឱ្យបានត្រឹមត្រូវ។
- **សេវាប្រមូល និងដឹកជញ្ជូនមិនគ្រប់គ្រាន់** ទោះបីជាមានការខិតខំប្រឹងប្រែងដើម្បីកែលម្អសេវាប្រមូលសំរាមក៏ដោយ ក៏នៅតែមានតំបន់នៅក្នុងរាជធានីភ្នំពេញ ជាពិសេសតំបន់ជុំវិញទីក្រុង ដែលខ្វះសេវាប្រមូល និងដឹកជញ្ជូនទៀងទាត់ និងមានប្រសិទ្ធភាពសម្រាប់ទាំងសំណល់រឹង-រាវ។ នេះនាំឱ្យមានការកកកុញនៃកាកសំណល់នៅក្នុងតំបន់ទាំងនេះដែលបង្កហានិភ័យទៅដល់ផ្នែកបរិស្ថាន និងសុខភាព។
- **គ្រឿងបរិក្ខារមានកំណត់** កន្លែងបំលែងសំណល់រាវដែលមានស្រាប់ក្នុងរាជធានីភ្នំពេញប្រហែលជាមិនគ្រប់គ្រាន់សម្រាប់គ្រប់គ្រងបរិមាណទឹកសំណល់ដែលកើនឡើងដែលបង្កើតឡើងដោយចំនួនប្រជាជន និងឧស្សាហកម្មដែលកំពុងកើនឡើងនោះទេ។ ការបំលែងមិនទាន់បានគ្រប់គ្រាន់អាចបណ្ដាលឱ្យមានការបំពុលទឹក និងគ្រោះថ្នាក់ដល់សុខភាព។
- **ការបំពុលនៃទឹក** ការចោលកាកសំណល់រាវមិនត្រឹមត្រូវ រួមទាំងទឹកសំណល់ដែលមិនត្រូវបានបម្លែងឱ្យបានស្រួលបួល អាចនាំឱ្យមានការចម្លងរោគទៅដល់ ទន្លេ និងបឹង។ ការបំពុលនេះមិនត្រឹមតែប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ីក្នុងទឹកប៉ុណ្ណោះទេ ថែមទាំងបង្កឱ្យមាននូវហានិភ័យចំពោះសុខភាពសាធារណៈតាមរយៈជម្ងឺដែលឆ្លងតាមទឹក។
- **កង្វះការយល់ដឹងជាសាធារណៈ** ចាំបាច់ត្រូវបង្កើនការយល់ដឹងជាសាធារណៈអំពីសារៈសំខាន់នៃការអនុវត្តការគ្រប់គ្រងសំណល់រឹង-រាវឱ្យបានត្រឹមត្រូវ។ អ្នកស្រុកជាច្រើនប្រហែលជាមិនត្រូវបានជូនដំណឹងពេញលេញអំពីផលប៉ះពាល់បរិស្ថាន និងសុខភាពដែលអាចកើតមាននៃការចោលកាកសំណល់មិនត្រឹមត្រូវនោះទេ។[៤៨]

### ២.៤.២. ដំណោះស្រាយ

ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងការគ្រប់គ្រងសំណល់រឹង-រាវក្នុងរាជធានីភ្នំពេញ ដំណោះស្រាយមួយចំនួនអាចត្រូវបានអនុវត្តន៍៖

[៤៨] គេហទំព័រសាលារាជធានីភ្នំពេញ https://phnompenh.gov.kh/ ដកស្រង់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤

### ២.៤.២.១. ការដោះស្រាយចំពោះសំណល់រឹង

សំណល់រឹង គឺជាបញ្ហាជាអាទិភាពមួយដែលត្រូវដោះស្រាយជាបន្ទាន់ព្រោះអាចបង្កគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់សុខភាពសាធារណៈ បរិស្ថាន សេដ្ឋកិច្ច និងមុខមាត់ប្រទេសជាតិប្រសិនបើយើងមិនដោះស្រាយឱ្យទាន់ពេល។ ការស្តុក ប្រមូល និងទុកដាក់សំរាមជាបញ្ហាចម្បង។ ការប្រមូល ការដឹកជញ្ជូន ការកាត់បន្ថយការប្រើប្រាស់ ការកែច្នៃឡើងវិញ និងការចាក់សំរាមចោល គឺជាការទទួលខុសត្រូវរបស់ខាងអាជ្ញាធររាជធានី ខេត្ត នឹងជាបន្តបន្ទាប់ត្រូវប្រតិភូកម្ម ទៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ-សង្កាត់ ដើម្បីងាយស្រួលនៅក្នុងការអនុវត្តឱ្យទាន់ពេល តាមតម្រូវការ និងឆ្លើយតប។

**ក. ការបែងចែកសំណល់រឹង**

សំណង់រឹងមួយចំនួនឆាប់រលាយដូចជាសំណល់ចេញពីផ្ទះបាយ និងសំណល់រឹងមួយចំនួនទៀត មិនងាយរលាយ ដូចជា ថង់ប្លាស្ទិក ដប កែវ ជ័រ និងសំណល់បង្កគ្រោះថ្នាក់ដទៃទៀតដូចជា សំណល់ត្រូវចេញពីរោងចក្រ និងមន្ទីរពេទ្យ ជាដើម។ សំណល់រឹងត្រូវបានបែងចែកជា ០៣ប្រភេទ ដូចជា៖

- **សំណល់សើម** ជាប្រភេទសំរាមដែលផ្ទាប់ទឹក មានជាតិទឹក ឬមានសំណើមមួយចំនួនដូចជាកាកសំណល់នៅក្នុងផ្ទះបាយ កាកសំណល់ផ្លែឈើ បន្លែ រុក្ខជាតិ ដែលរលួយកាកសំណល់ចេញពីទីផ្សារជាដើម។
- **សំណល់ស្ងួត** សំរាមស្ងួតអាចបែងចែកជា ០២ប្រភេទផ្សេងទៀត គឺប្រភេទស្រាល និងប្រភេទធ្ងន់ឬរឹង។ សំរាមស្ងួតប្រភេទស្រាលមានដូចជា ក្រដាសការសែត សៀវភៅ ទស្សនាវដ្តី ថង់ប្លាស្ទិក ជ័រកៅស៊ូ សម្បកកំប៉ុង និងរបស់របរជាច្រើនប្រភេទទៀត។ សំរាមប្រភេទធ្ងន់ ឬរឹងមានដូចជា សម្បកកង់ឡាន សម្បកដប អំបែងកែវ ដែក និងប្រភេទលោហៈធាតុដូចជា ឆ្នាំងបែកបាក់ជាដើម។
- **សំណល់គ្រោះថ្នាក់** សំណល់គ្រោះថ្នាក់ក៏ជាសំណល់រឹងដែរ ប៉ុន្តែវាមានលក្ខណៈពិសេសត្រង់ថាវាមានជាតិពុលច្រើន និងបង្កគ្រោះថ្នាក់។ សំណល់នេះត្រូវញែកវាឱ្យដាក់ពីសំណល់ធម្មតាហើយទុកដាក់វាឱ្យត្រឹមត្រូវ ដែលមានដូចជា អាគុយ ថ្មពិល ដបថ្នាំពុល អំពូលអគ្គិសនីជាដើម។

**ខ. ការស្តុកបណ្តោះអាសន្នការស្តុកបណ្តោះអាសន្ន**

ការស្តុកបណ្តោះអាសន្ន គឺសំដៅទៅលើការស្តុកទុករយៈពេលខ្លីមួយមុនពេលយកទៅចាក់ចោលនៅក្នុងទីតាំងចាក់សំរាម។ ក្រោយពីយើងទុកដាក់ និងវិចខ្ចប់ បែកចែកសំរាមរួចហើយត្រូវយកទៅដាក់ទីតាំងផ្សេងគ្នា ឬដាក់ពណ៌ខុសគ្នា ពិសេសសំណល់ដែលប្រកបដោយគ្រោះថ្នាក់ ដើម្បីងាយស្រួលចំណាំ។ យើងត្រូវយកសំរាមស្តុកក្នុងធុងសំរាមរួចរាល់ នៅពេលដែលដល់ម៉ោងកំណត់នៃការប្រមូលសំរាមទើបត្រូវយកទៅទុកមុខផ្ទះ

ករណីនៅលំនៅឋាន។ ភាគច្រើននៅមានតាមអគារពាណិជ្ជកម្ម មន្ទីរពេទ្យ រោងចក្រ និងសិប្បកម្មគេមានធុងដាក់សំរាមធំៗ ហើយគេទុកទីតាំងមួយកន្លែងជាក់លាក់ រួចគេនឹងប្រមូលតាមពេលវេលាកំណត់មួយ។ ចំពោះផ្សារតូចៗក៏ដូចជាតាមទីធ្លាសាធារណៈដែរ គេត្រូវរក្សាទុកសំរាមក្នុងធុងសំរាមឱ្យបានត្រឹមត្រូវជៀសវាងការគរជាគំនរចោលនៅលើដី ពីព្រោះការគរចោលបែបនេះនឹងត្រូវវាយប៉ាយ ដោយសារតែសត្វពាហនៈទៅកកូកកាយរកចំណី និងមនុស្សមួយចំនួនទៅកកាយដើម្បីរកវត្ថុដែលអាចយកទៅកែច្នៃបាន។

### គ. ការប្រមូល និងការដឹកជញ្ជូនសំរាម

ការប្រមូល និងការដឹកជញ្ជូនសំណល់រឹងមានភាពស្មុគស្មាញ និងសាំញ៉ាំដោយសារការបញ្ចេញសំណល់មាននៅគ្រប់ទីកន្លែងទាំងអស់រួមទាំងលំនៅឋាន ទីផ្សារ រោងចក្រ សហគ្រាស ផ្លូវ និងតំបន់ទីកន្លែងសាធារណៈផ្សេងៗ។ កាប្រមូល និងការដឹកជញ្ជូនសំរាម គឺត្រូវបានបែងចែកដូចជា ប្រមូលនៅតាមលំនៅឋាន ការប្រមូលតាមសហគមន៍ រោងចក្រ សហគ្រាស មន្ទីរពេទ្យ និងការប្រមូលតាមចិញ្ចើមថ្នល់។

- ការប្រមូលតាមលំនៅឋាន សេវាកម្មនៃការប្រមូលសំណល់ គឺចូលទៅប្រមូលនៅតាមផ្ទះនីមួយៗរបស់ប្រជាពលរដ្ឋ ករណីផ្លូវតូចចង្អៀតដែលមិនអាចចូលទៅប្រមូលសំរាមបាន ប្រជាពលរដ្ឋត្រូវប្រមូលទៅដាក់ទីកន្លែងដែលគេអាចមកប្រមូលបាន។ ការប្រមូលនេះត្រូវបានកំណត់ពេលវេលាជាក់លាក់នូវការប្រមូលជៀសវាងការទុកសំរាមរយៈពេលយូរនៅខាងមុខផ្ទះ ឬទីសាធារណៈ ដែលបង្កឱ្យទៅជាក្លិនមិនល្អ និងស្ទះលូ ជាដើម។
- ការប្រមូលតាមសហគមន៍ រោងចក្រ សហគ្រាស មន្ទីរពេទ្យ សេវាកម្មនៃការប្រមូលសំណល់ចូលទៅប្រមូលនៅតាមទីតាំងស្តុករួម នៅតាមសហគមន៍ រោងចក្រ សហគ្រាស មន្ទីរពេទ្យ។ ទីតាំងស្តុកសំរាមរួម ត្រូវកំណត់ទីតាំងជាក់លាក់ ទំហំ ពេលវេលាដែលត្រូវប្រមូល ដើម្បីរក្សាបរិស្ថានឱ្យស្អាតល្អ។
- ការប្រមូលតាមទីធ្លាសាធារណៈ ការសម្អាតតាមដងផ្លូវត្រូវធ្វើឡើងជាប្រចាំ នៅតាមសួនច្បារចិញ្ចើមផ្លូវមាត់ទន្លេ និងនៅកន្លែងផ្សេង រួចត្រូវប្រមូលសំណល់ទៅដាក់នៅទីតាំងស្តុកក្នុងធុងសំរាមសាធារណៈ ដោយចែងចែកវាទៅប្រភេទនីមួយៗ។ ការស្តុក ការប្រមូល និងដឹកជញ្ជូន សំរាមដែលមានគ្រោះថ្នាក់ត្រូវដាក់ដាច់ដោយឡែកពីសំរាមធម្មតា។

### ឃ. ការកាត់បន្ថយការប្រើប្រាស់

ក្នុងការកាត់បន្ថយបរិមាណសំណង់រឹង គឺចាប់ផ្តើមចេញពីសកម្មភាពរបស់យើងម្នាក់ៗ។ ជាដំបូងយើងអាចធ្វើការផ្លាស់ប្តូររបៀបរស់នៅរបស់យើង ដោយមិនប្រើប្រាស់ថង់ប្លាស់ស្ទិក ឬសម្ភារផ្សេងៗទៀតដែលមិន

ចាំបាច់ ការដាក់បញ្ចូលគ្នានៅក្នុងថង់តែមួយ ឬយកថង់បរិស្ថានពីផ្ទះទៅច្រក ប្រជាពលរដ្ឋគ្រប់រូបត្រូវមានកាតព្វកិច្ចចូលរួម ចំណែកក្នុងការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិកតាមតែអាចធ្វើទៅបាននោះ ស្តែងតាមរយៈការនាំយកថង់ប្លាស្ទិកមកប្រើប្រាស់ឡើងវិញ ឬប្រើប្រាស់វត្ថុជំនួសថង់ប្លាស្ទិក។

**ង. ការកែច្នៃ និងការកំទេចចោល**

លើកទឹកចិត្តដល់ការកែច្នៃ និងការផលិតក្នុងប្រទេសនូវសម្ភារនានាអំពីថង់ប្លាស្ទិកក្នុងស្រុកតាមរយៈការសរសើរ ការជូនរង្វាន់ និងការដាក់អាករពិសេសជាបន្ទុករបស់រដ្ឋ។ ដូចនេះយើងត្រូវតែធ្វើការបែកចែកសំណល់រឹងធ្វើអាចកែច្នៃបាន ប្រើប្រាស់ឡើងវិញ និងកម្ទេចចោល។

❖ **ការកែច្នៃ**

ការកែច្នៃសំរាម គឺជាការចាំបាច់ និងមានសារៈសំខាន់ខ្លាំងណាស់ទៅលើសេដ្ឋកិច្ច និងបរិស្ថាន។ ចំពោះការកែច្នៃសំណល់រឹងត្រូវបានបែងចែកជា ០៣ប្រភេទៈ

- **ជីកំប៉ុស** ជាជីធម្មជាតិដែលផ្សំឡើងដោយ លាមកសត្វ រុក្ខជាតិ និងសំណល់សើម អាចបំបែកទៅជាសរីរាង្គបាន។ សារៈសំខាន់នៃការប្រើប្រាស់ជីកំប៉ុសមានដូចជា ធ្វើឱ្យដីល្អ មិនខូចដីនៅពេលប្រើបើប្រើជីគីមីនាំឱ្យដី ក្តាំងហិរ ពេលប្រើយូរៗទៅ (ដំណាំលូតលាស់ល្អតាមធម្មជាតិទិន្នផលខ្ពស់ និងផលដំណាំគ្មានជាតិគីមីមិនប៉ះពាល់ដល់សុខភាពអ្នកបរិភោគជាដើម)។
- **ប្រើប្រាស់ឡើងវិញ** ការនាំចេញសំរាមពីព្រះរាជាណាចក្រកម្ពុជាទៅប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបានលុះតែណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់របស់ក្រសួងពាណិជ្ជកម្មព្រមទាំងលិខិតអនុញ្ញាតឱ្យនាំចូលរបស់របស់សាម៉ីប្រទេស ជាមុនសិន។ សំណល់សើមភាគច្រើនយកទៅធ្វើជាជីកំប៉ុសដោយបំបែកជាសរីរាង្គ តែសំណល់រឹងមួយចំនួនអាចប្រើប្រាស់ឡើងវិញបានដូចជា ដែក សំបកកំប៉ុង ជ័រ អាលុយមីញ៉ូមជាដើម រួចយកមកបំលែងជារបស់ប្រើប្រាស់ឡើងវិញ។
- **ប្រែក្លាយសំណល់ទៅជាថាមពល ឧទាហរណ៍** នៅប្រទេសកម្ពុជាតាមរយៈការផ្តល់មូលនិធិដោយសហភាពអឺរ៉ុប, SWITCH-Asia, អង្គការSNVកម្ពុជា បានអនុវត្តន៍គម្រោងប្រែក្លាយសំណល់ទៅជាថាមពលសម្រាប់ប្រើប្រាស់ក្នុងរោងកិនស្រូវ បច្ចេកវិទ្យាដើម្បីបម្លែងជាថាមពលអគ្គិសនីចេញពីអង្កាម (ពីឆ្នាំ២០១២ ដល់ឆ្នាំ ២០១៥)។

❖ **ការកំទេចចោល**

ក្រោយពីការកែច្នៃឱ្យអស់លទ្ធភាពហើយសំណល់ដែលនៅសេសសល់មិនយកទៅប្រើការបានទៀតទេ។ ការដុតកម្ទេចចោល ឬក៏យកកិនចោលជាជម្រើសចុងក្រោយហើយត្រូវធ្វើឡើងដោយមិនប៉ះពាល់ទៅដល់ផ្នែកបរិស្ថានឡើយ។ អប់រំ និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីប្រភព និងគុណវិបត្តិដែលត្រូវបានបង្កឡើងពីសំណល់រឹងនៅថ្នាក់មូលដ្ឋានរបស់ខ្លួនក្នុងករណីដែលមានការចាំបាច់ត្រូវតែបង្កើតច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដទៃទៀត ដើម្បីទប់ស្កាត់តាមរយៈការដាក់ពិន័យ ឬ/និងដាក់ទណ្ឌកម្ម។

**ច. វិធានការទប់ស្កាត់**

អប់រំ និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីប្រភព និងគុណវិបត្តិដែលបង្កឡើងពីសំណល់រឹងនៅតំបន់ថ្នាក់មូលដ្ឋានរបស់ខ្លួនក្នុងករណីដែលមានការចាំបាច់ត្រូវបង្កើតច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដទៃទៀត ដើម្បីធ្វើការទប់ស្កាត់តាមរយៈការដាក់ពិន័យ ឬ/និងដាក់ទណ្ឌកម្ម។

**ឆ. វិធានការប្រជុំ អប់រំ និងផ្សព្វផ្សាយ**

ត្រូវមានប្រតិបត្តិបរិស្ថានស្អាតជារៀងរាល់ថ្ងៃ និងនៅគ្រប់ទីកន្លែងដើម្បីកម្ពុជាដែលជាផ្ទះរបស់យើងស្អាតគេមិនអាចមិនគិតគូរដល់អនាម័យបរិស្ថានស្អាតនោះទេព្រោះថាសំរាម និងកាកសំណល់កខ្វក់ គឺជាសត្រូវរបស់ផ្នែកវិស័យទេសចរណ៍។

**ជ. ការប្រជុំ និងការអប់រំ**

- **ការប្រជុំ**

យើងត្រូវតែប្រជុំផ្សព្វផ្សាយផងដែរចំពោះមន្ត្រីនៅមន្ទីរអង្គភាពទាំងអស់ដើម្បីធ្វើជាគំរូដល់ប្រជាពលរដ្ឋជាពិសេសសាមីអង្គភាពអនុវត្តន៍ដោះស្រាយលើសំណល់រឹងនេះកិច្ចប្រជុំទាំងអស់ត្រូវតែសង្កាត់ធ្ងន់ទៅលើប្រភពដែលធ្វើឱ្យកើតមានសំណល់រឹង គុណវិបត្តិដែលបង្កមកពីកាកសំណល់រឹង និងដំណោះស្រាយដូចដែលបានលើកឡើងខាងលើស្រាប់។ អង្គភាពស្ថាប័ននីមួយៗត្រូវតែស្វែងយល់ឱ្យបានច្បាស់ជាមុនសិនទើបអាចធ្វើការអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យមានប្រសិទ្ធភាព។

- **ការអប់រំ**

ការអប់រំបរិស្ថាន គឺត្រូវបណ្តុះគំនិតពីក្មេងៗហើយផ្តើមចេញពីយើងគ្រប់គ្នាដែលជាមាតាបិតា លោកគ្រូអ្នកគ្រូដោយរៀបចំវិធីសាស្ត្រងាយៗសប្បាយៗដើម្បីបង្រៀនដល់កូនៗ ឬសិស្សានុសិស្សលេងល្បែងកម្សាន្តដែលបង្កប់ន័យអប់រំពាក់ព័ន្ធនឹងការងារថែរក្សាបរិស្ថាន ក៏ដូចជាបណ្តុះកុមារឱ្យចេះគិតគូរដោះស្រាយបញ្ហានិង

ចេះស្រឡាញ់ថែរក្សាបរិស្ថានដោយខ្លួនឯងតាំងពីតូចទៅដោយមិនចាំបាច់រង់ចាំទាល់តែពេញវ័យបានធ្វើការអប់រំផ្នែកបរិស្ថាននោះទេ។ ការលើកទឹកចិត្តកូនៗឱ្យសម្អាតអនាម័យបរិស្ថាននៅផ្ទះ និងសិស្សានុសិស្សឱ្យចូលរួមសម្អាតបរិស្ថានក្នុងសាលា ឱ្យពួកគេចេះទុកដាក់សំរាមបានត្រឹមត្រូវ និងចូលរួមសម្អាតអនាម័យក្នុងសហគមន៍ជាកិច្ចការសាមញ្ញៗប៉ុន្តែបានបង្កប់នូវគំនិតអប់រំ ផ្លាស់ប្តូរឥរិយាបថរបស់ពួកគាត់ បណ្តុះគំនិត ការបញ្ជ្រាបចំណេះដឹង និងសារៈសំខាន់នៃបរិស្ថាននឹងជំរុញឱ្យកុមារចូលរួមយ៉ាងសកម្មប្រកបដោយការទទួលខុសត្រូវចំពោះបរិស្ថាន។ កុមារងាយស្រួលអប់រំ ព្រោះបន្ទាប់ពីរៀនសូត្រ ឬដឹងឮហើយ ពួកគេនឹងបានអនុវត្តន៍ភ្លាមៗកាលណាពួកគេដឹងគេស្រឡាញ់គេចូលចិត្តគេនឹងថែរក្សាដោយយកចិត្តទុកដាក់ហើយកុមារទាំងនេះនឹងក្លាយជាគំរូល្អក្នុងការថែរក្សាបរិស្ថាន និងជួយអប់រំដល់កុមារដទៃទៀតផងនៅក្នុងតំបន់ក៏ដូចជាប្រទេសកម្ពុជានេះទាំងមូល។ ជាការពិតកុមារពិតជាមានតួនាទីសំខាន់រួមចំណែកយ៉ាងសកម្មក្នុងការចូលរួមថែរក្សាបរិស្ថានទាំងនៅសាលារៀន និងលំនៅឋានរបស់ពួកគេផ្ទាល់។

### ឈ. ការផ្សព្វផ្សាយ

ការប្រជុំ និងអប់រំពលរដ្ឋ និងមន្ត្រីនៅមូលដ្ឋានគ្រប់គ្រាន់នៅឡើយទេចំពោះដំណោះស្រាយការគ្រប់គ្រងសំណល់រឹង។ ការផ្សព្វផ្សាយទៅតាមទូរទស្សន៍ ការសែត ទស្សនាវដ្តី ខិតប័ណ្ណផ្សព្វផ្សាយ ដើម្បីផ្សាយទៅដល់ប្រជាជនទូទាំងប្រទេសចូលរួមដោះស្រាយទាំងអស់គ្នា។ នៅក្នុងសម័យបច្ចុប្បន្ននេះការផ្សព្វផ្សាយលើប្រព័ន្ធទំនាក់ទំនងសង្គមដូចជា ហ្វេសប៊ុក តិកតុក ជាដើម វាឆាប់រហ័សក្នុងការផ្សាយទៅដល់អ្នកដែលបានប្រើប្រាស់ជាពិសេសយុវជនក្នុងការចូលរួមដោះស្រាយបញ្ហាសំណល់នេះ។ ការផ្សព្វផ្សាយត្រូវបង្ហាញនូវការទាក់ទាញដល់អ្នកទស្សនាដោយផ្តោតទៅប្រភព គុណវិបត្តិ និងដោះស្រាយដែលចាំបាច់សម្រាប់ប្រជាពលរដ្ឋគ្រប់ត្រូវដឹងនិងចូលរួមដោះស្រាយ។

### ញ. វិធានការតាមផ្លូវច្បាប់

ហាមឃាត់ជាដាច់ខាតការនាំចូលនូវសំណល់ប្រកបដោយគ្រោះថ្នាក់ពីប្រទេសក្រៅចូលមកក្នុងប្រទេសកម្ពុជា។ មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណាដែលមានការធ្វេសប្រហែសខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពតាមបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសម្រួលការប្រព្រឹត្តបទល្មើសនេះត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ។ រាល់ការនាំចូល និងការផលិតផលថង់ប្លាស្ទិកក្នុងស្រុកត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន លើកលែងតែការនាំចូលគ្មានលក្ខណៈពាណិជ្ជកម្មក្នុងទណ្ឌកម្មរួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ

- ការដកហូតសម្ភារដែលល្មើស
- ការផ្អាកសកម្មភាពអាជីវកម្ម ឬសកម្មភាពផលិតជាបណ្តោះអាសន្ន
- ការផ្អាក ឬដកហូតការអនុញ្ញាតក្នុងការនាំចូល ឬការផលិតក្នុងស្រុក
- ការពិន័យអន្តរការណ៍។

ការអនុវត្តទណ្ឌកម្មខាងលើនេះជាសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិលើកលែងតែមានការផ្អាក ឬដកហូតអនុញ្ញាតក្នុងការនាំចូល ឬការផលិតក្នុងស្រុកដែលជាសមត្ថកិច្ចផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។ បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចនានារបស់រដ្ឋបាលរាជធានី ខេត្តក្នុងការអនុវត្តមានសិទ្ធិប្តឹងតវ៉ាទៅកាន់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថានខាងលើមានសិទ្ធិប្តឹងតវ៉ាទៅតុលាការតាមនីតិវិធីជាធរមាន។ បុគ្គលដែលមិនបានបង់ប្រាក់ពិន័យអន្តរការណ៍នេះក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ គិតពីថ្ងៃតវ៉ាទៅរដ្ឋមន្ត្រីក្រសួងបរិស្ថាន។ ថ្លៃចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាបីដងបើលើសពី៩០(កៅសិប)ថ្ងៃ។ រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវដែលបានទទួលបង្គាន់ដៃបង់ប្រាក់ពិន័យចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាពីរដងបើលើសពី៦០(ហុកសិប) ថ្ងៃរៀបចំសំណុំឯកសារប្តឹងទៅសាលាដំបូងរាជធានីខេត្ត។ ថ្មីៗនេះរាជរដ្ឋាភិបាលកម្ពុជាបានដកហូតសិទ្ធិពីក្រុមហ៊ុនស៊ិនទ្រីដែលប្រមូលសំរាមមិនបានទៀងទាត់ និងគ្រប់ជ្រុងជ្រោយ ដោយផ្តល់សិទ្ធិឱ្យក្រុមហ៊ុនយ៉ាងតិច៤ ដាក់ឱ្យដេញថ្លៃដើម្បីធ្វើការប្រមូលសំរាមនៅក្នុងរាជធានីភ្នំពេញវិញ ក្នុងដំណាក់កាលនេះប្រមូលយកធនធានសម្ភារ និងធនធានមនុស្សមកគ្រប់គ្រងជាបណ្តោះអាសន្នទម្រាំរកបានក្រុមហ៊ុនថ្មី។ ផលប្រយោជន៍នៃការសិក្សាសំណល់រឹងគោលបំណងសំខាន់ក្នុងការគ្រប់គ្រងសំណល់រឹង គឺរៀបចំ ការបោះបង់ចោលសំណល់ឱ្យបានត្រឹមត្រូវដើម្បីសុខមាលភាពរបស់មនុស្ស សត្វ និងផ្នែកនៃបរិស្ថានទាំងមូល។ នៅពេលដែលវិស័យឧស្សាហកម្មមិនទាន់មានការរីកចម្រើនខ្លាំងក្លាទេនោះ សំណល់រឹងត្រូវបានគេយកទៅចោលនៅតាមទីវាលដែលទំនេរ។ ប៉ុន្តែចាប់ពីវិស័យឧស្សាហកម្មបានរីកចម្រើនមកសមាសធាតុបង្កសំណល់ក៏មានភាពស្មុគស្មាញផងដែរដែលទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ និងមានបច្ចេកវិទ្យាត្រឹមត្រូវដើម្បីធ្វើការបោះបង់ចោលសំណល់ឱ្យបានត្រឹមត្រូវ។[៥៩]

[៥៩] អនុក្រឹត្យ ស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក, លេខ ១៦៨ អនក្រ.បក, ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧, មាត្រា២៣

#### ២.៤.២.២. ដំណោះស្រាយចំពោះភាគសំណល់រាវ

ដោយពិនិត្យឃើញពីស្ថានភាពដ៏មានគ្រោះថ្នាក់ដែលបណ្ដាលមកពីសកម្មភាពល្មើសផ្សេងៗ ខាងក្រសួងបរិស្ថានបានដាក់ចេញនូវវិធានការចំពោះមុខមួយចំនួនដូចខាងក្រោម៖

- ចំពោះរោងចក្រ សហគ្រាស និងសិប្បកម្មដែលពុំទាន់មានអាងប្រព្រឹត្តិកម្មសម្អាតសំណល់រាវត្រូវតែរួសរាន់រៀបចំអាងប្រព្រឹត្តិកម្មសម្អាតសំណល់រាវឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសមុន និងបង្ហូរចូលទៅក្នុងប្រព័ន្ធលូសាធារណៈ ឬប្រភពទឹកសាធារណៈដ៏ទៃទៀត។
- ចំពោះរោងចក្រ សហគ្រាស និងសិប្បកម្មដែលមានអាងប្រព្រឹត្តិកម្មសម្អាតសំណល់រាវប៉ុន្តែសម្រាប់អាងប្រព្រឹត្តិកម្មសម្អាតនោះមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ឬពុំអាចមានលទ្ធភាពធ្វើការសម្អាតសំណល់រាវឱ្យឆ្លើយតបតាមកម្រិតកំណត់ស្តង់ដារត្រូវតែធ្វើការកែតម្រូវអាងប្រព្រឹត្តកម្មសម្អាតនៃសំណល់រាវជាបន្ទាន់ដោយធ្វើយ៉ាងណាដើម្បីធានាឱ្យការបញ្ចេញសំណល់រាវរបស់ខ្លួនមិនបានបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាន និងសុខភាពប្រជាពលរដ្ឋ។
- ចំពោះរោងចក្រ សហគ្រាស និងសិប្បកម្មដែលមានអាងប្រព្រឹត្តិកម្មសម្អាតត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសរួចត្រូវតែដាក់ឱ្យដំណើរការជាប់ជាប្រចាំហើយសំណល់រាវដែលបានធ្វើប្រព្រឹត្តិកម្មសម្អាតរួចត្រូវតែឆ្លើយតបតាមកម្រិតកំណត់ស្តង់ដារនៃការបញ្ចេញ។
- សំណល់រាវដែលបានធ្វើប្រព្រឹត្តកម្មសម្អាតរួចត្រូវបង្ហូរតាមបណ្តាញលូដាច់ដោយឡែក និងនៅត្រង់ចំណុចបញ្ចេញនៅខាងក្រៅបរិវេណរោងចក្រមុនតភ្ជាប់ទៅប្រព័ន្ធលូសាធារណៈ ឬបញ្ចេញទៅក្នុងប្រភពទឹកប្រភពនៅត្រង់ចំណុចបញ្ចេញនេះត្រូវរៀបចំអណ្តូងលូសាធារណៈដែលមានគម្របអាចបិទបើកបានងាយស្រួលដើម្បីឱ្យភ្នាក់ងារមានសមត្ថកិច្ចចុះធ្វើការត្រួតពិនិត្យ និងងាយយកសំណាកទឹកសម្រាប់ធ្វើការវិភាគ។
- ការបញ្ចេញសំណល់រាវក្រោយប្រព្រឹត្តិកម្មសម្អាតរួចចូលទៅក្នុងប្រព័ន្ធលូ ឬប្រភពទឹកសាធារណៈត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថានជាមុន។
- ម្ចាស់ ឬអ្នកទទួលខុសត្រូវប្រភពបំពុលទាំងឡាយណាដែលខកខានមិនបានអនុវត្តន៍តាមបណ្តាវិធានការដូចមានចែងក្នុងសេចក្តីជូនដំណឹងនេះ ឬ/និងលិខិតបញ្ជាកែប្រែជាលាយលក្ខណ៍អក្សររបស់ក្រសួងបរិស្ថាន ម្ចាស់ ឬអ្នកដែលទទួលខុសត្រូវប្រភពបំពុលទាំងនោះនឹងត្រូវទទួលការ

ពិន័យអន្តរការណ៍ជាប្រាក់ ឬ/និងត្រូវប្រឈមចំពោះមុខច្បាប់ជាធរមានដោយអនុលោមតាមទំហំនៃបទល្មើសដែលខ្លួនបានប្រព្រឹត្តជាក់ស្តែង។[៥០]

[៥០] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី៤២

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាទៅការគ្រប់គ្រងសំណល់រឹង-រាវនៅរាជធានីភ្នំពេញរួចមក យើងឃើញថា ក្នុងការគ្រប់គ្រងសំណល់រឹង-រាវ គឺចាំបាច់ត្រូវតែមានការចូលរួមគ្រប់អាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ដូចជា រដ្ឋ វិស័យឯកជន និងពីសំណាក់ប្រជាពលរដ្ឋផ្ទាល់ដើម្បីធ្វើយ៉ាងណាឱ្យមានការថយចុះនូវកំណើនកាកសំណល់ នៅក្នុងរាជធានីភ្នំពេញ។ យ៉ាងណាមិញភាគីរដ្ឋ គឺត្រូវដើរតួនាទីយ៉ាងសំខាន់ក្នុងចូលរួមសម្របសម្រួល និង តាមដាននៃការអនុវត្តរបស់អ្នកផ្តល់សេវាប្រមូលសំរាមទៅកាន់ប្រជាពលរដ្ឋ ក្នុងកាលៈទេសៈមានបញ្ហា ប្រឈមក្នុងមូលដ្ឋានត្រូវមានការសម្របសម្រួល ពីអ្នកដែលមានសមត្ថកិច្ចក្នុងការដោះស្រាយកុំឱ្យមាននូវការ កកស្ទះ និងឈានទៅដល់ការកើតមានផលប៉ះពាល់នៃបរិស្ថានកាន់តែខ្លាំងឡើង។ ឆ្លងកាត់បទពិសោធន៍ក្នុង ការគ្រប់គ្រងសំណល់រឹង-រាវ របស់សាលារាជធានីភ្នំពេញ យើងឃើញថាសាលារាជធានីភ្នំពេញបានសម្រេច បាននូវសមិទ្ធផលជាច្រើនក្នុងការរៀបចំផែនការ និងគោលការណ៍ណែនាំអនុវត្តន៍មួយចំនួនសំដៅឱ្យមានការ គ្រប់គ្រងប្រាកដដោយប្រសិទ្ធភាព និងនិរន្តរភាពបរិស្ថានដូចជា ការរៀបចំផែនការណែនាំនឹងអនុវត្តន៍ក្នុងការ ញែកសំរាម ការអប់រំប្រជាពលរដ្ឋ ការរៀបចំក្បួនយុទ្ធនាការអប់រំផ្សព្វផ្សាយ ការរៀបចំស្លាតអប់រំ ការរៀបចំសិក្ខា សាលា ការដាក់ចេញនូវគោលការណ៍ណែនាំឱ្យបានត្រឹមត្រូវអំពីការប្រើប្រាស់ថង់ប្លាស្ទិក និងមានជាច្រើន ទៀតក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាលក្រសួង ផ្សេងៗទៀតដែលមានដូចជា ក្រសួងទេសចរណ៍ ក្រសួងបរិស្ថាន-ល-។

ក្នុងទិសដៅសកម្មភាពនាពេលបច្ចុប្បន្នការគ្រប់គ្រងកាកសំណល់ គឺធ្វើយ៉ាងណាកាត់បន្ថយសំរាមឱ្យ បានច្រើន និងរក្សាសោភ័ណភាព អនាម័យ និងឈានទៅធ្វើការញែកសំរាម កែច្នៃសំណល់ សម្រាប់ការផ្ទុក សំរាមនៅទីលានចាក់សំរាមដែលកំពុងកើតមានបញ្ហាផលប៉ះពាល់បរិស្ថាន គំរាមកំហែងប្រជាពលរដ្ឋ ហើយ ធ្វើយ៉ាងណាត្រូវមានការចូលរួមធ្វើកិច្ចអន្តរាគមន៍ពីអាជ្ញាធរមូលដ្ឋានទៅក្នុងដំណើរការសេវាកម្មដែលកត្តាមួយ នេះមិនអាចខ្វះបានឡើយ។ មិនត្រឹមតែប៉ុណ្ណោះ ត្រូវមានការយកចិត្តទុកដាក់ទៅលើចំនុចសំខាន់មួយទៀត ដូចជា ការបញ្ចេញសំណល់គ្រោះថ្នាក់ចេញពីបរិវេណរោងចក្រដោយពុំបានធ្វើប្រព្រឹត្តកម្មតាមស្តង់ដារបានបង្ក ឱ្យមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋ ដូច្នេះចាំបាច់ត្រូវមានយន្តការត្រួតពិនិត្យតាមដានជាប្រចាំរកឱ្យឃើញ នូវប៉ះពាល់បរិស្ថានដើម្បីចាត់វិធានការធ្វើការដោះស្រាយឱ្យបានទាន់ពេលវេលា។ អាស្រ័យដែលអាចធ្វើឱ្យការ គ្រប់គ្រងសំណល់រឹង-រាវក្នុងរាជធានីភ្នំពេញកាន់តែមានការប្រសើរឡើងជាងមុនបន្ទាប់ពីមានការចូលរួមពីខាង សាលារាជធានីភ្នំពេញ និងវិស័យឯកជនដោយតែចំណុចចាំបាច់មួយទៀតនោះ គឺការចូលរួមពីប្រជាពលរដ្ឋ ខ្លួនឯងផ្ទាល់ដែលជាអ្នកទទួលសេវា។ ប្រជាពលរដ្ឋ គឺដើរតួនាទីសំខាន់ក្នុងការគ្រប់គ្រងកាកសំណល់ សំរាម នៅក្នុងលំនៅឋានរបស់គាត់ដោយតាមរយៈការចេះញែកសំរាមឱ្យដាច់ដោយឡែកពីគ្នាកុំឱ្យមានច្រលូកច្រលំ

គ្មានវាង សំរាមសើម និងសំរាមរឹង។ មិនត្រឹមតែប៉ុណ្ណោះប្រជាពលរដ្ឋ គឺត្រូវតែមាននូវសីលធម៌មួយចំពោះទំនួលខុសត្រូវក្នុងការធ្វើជាគំរូទាក់ទងទៅនឹងការទុកដាក់កាកសំណល់ សំរាមឱ្យមានអនាម័យ និងមានសណ្ដាប់ធ្នាប់ខ្ពស់។

សរុបជារួមមក ការគ្រប់គ្រងកាកសំណល់រឹង-រាវនៅរាជធានីភ្នំពេញពិតជាមានសារៈសំខាន់ណាស់ចំពោះប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍ វាបានជួយឱ្យប្រទេសជាតិមានសោភ័ណភាពស្រស់ស្អាតគ្មាននូវការបំពុល និងទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិផងដែរ។ ទាំងអស់នេះហើយ គឺសុទ្ធសឹងតែកើតចេញពីការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាល អាជ្ញាធរដែលពាក់ព័ន្ធ និងការចូលរួមយ៉ាងសកម្មរបស់ប្រជាពលរដ្ឋផ្ទាល់តែម្ដង។

# អនុសាសន៍

# អនុសាសន៍

ដោយផ្អែកទៅលើស្ថានភាពជាក់ស្តែង ការគ្រប់គ្រងសំណល់រឹង-រាវនៅរាជធានីភ្នំពេញមានលក្ខណៈល្អប្រសើរ ដោយសារតែការយកចិត្តទុកដាក់ពីសំណាក់អាជ្ញាធរដែលពាក់ព័ន្ធ គួបផ្សំជាមួយនឹងការចូលរួមផ្សព្វផ្សាយបន្ថែមទៀតផងដែរ។ ប៉ុន្តែ យើងនៅតែឃើញមានបញ្ហាប្រឈមដែលទាក់ទងនឹងបញ្ហាសំរាម ដោយសារតែការទុកដាក់សំរាមមិនទាន់មានភាពត្រឹមត្រូវនៅឡើយ និងបញ្ហាផ្សេងៗមួយចំនួនទៀតផង។ ជាមួយគ្នានេះផងដែរ នាងខ្ញុំ និងខ្ញុំបាទក៏មានជាមតិសំណូមពរមួយចំនួនលើបញ្ហាខាងលើនេះ ដែលមានដូចតទៅ៖

- ស្នើសុំសាលារាជធានីភ្នំពេញគួរតែមានវិធានការសំខាន់ផ្សេងៗទៅលើកង្វះខាតរបស់ក្រុមហ៊ុនឯកជននៃផែនការសកម្មភាព ដើម្បីឱ្យក្រុមហ៊ុនឯកជនធ្វើការងារ និងធ្វើសកម្មភាពដោយប្រុងប្រយ័ត្ន និងទំនួលខុសត្រូវខ្ពស់។ **ឧទាហរណ៍** ដូចក្នុងករណីភាពយឺតយ៉ាវនៃការប្រមូលសំរាម នៅតាមតំបន់ដែលខ្លួនប្រតិបត្តិ។
- ស្នើសុំឱ្យមានការពង្រីកទីលានចាក់សំរាមឱ្យបានធំទូលាយ បន្ថែមពីលើទីតាំងប្រើប្រាស់ក្នុងពេលបច្ចុប្បន្ន
- ស្នើសុំនៅតាមទីសាធារណៈគួរតែមានផាកពិន័យ នៅពេលមានការបោះសំរាមពាសវាលពាសកាល ដើម្បីការអនុវត្តវិធានការច្បាប់ឱ្យមានប្រសិទ្ធភាពជាពិសេសអ្នកដែលចោលកន្ទុយបារីជាដើម
- ស្នើសុំឱ្យពង្រឹងចលនានៃការគ្រប់គ្រង និងកាត់បន្ថយក្នុងការប្រើប្រាស់ថង់ប្លាស្ទីកគួរតែមានការចុះអប់រំ ប្រជាពលរដ្ឋអំពីការវែកញែក និងទុកដាក់សំរាម ជាប្រចាំ និងដាក់ការតាមដានទៅលើអ្វីដែលធ្លាប់ទទួលបានអំពីការរៀន និងការអនុវត្តផ្ទាល់របស់ប្រជាពលរដ្ឋ។
- ស្នើសុំអនុវត្តយ៉ាងតឹងរឹងចំពោះអ្នកប្រព្រឹត្តអំពើល្មើស ឬធ្វើនូវសកម្មភាពដែលផ្ទុយពីគោលការណ៍របស់រាជរដ្ឋាភិបាល។
- ស្នើសុំឱ្យមានការលើកទឹកចិត្តទៅដល់យុវជនស្ម័គ្រចិត្តដែលបានចុះទៅប្រមូលសំរាមតាមបណ្តាលូនានា
- ស្នើសុំឱ្យមានការរៀបចំផែនការចុះត្រួតពិនិត្យនៅតាមបណ្តាទីសាធារណៈដូចជាផ្សារ ឬក៏ទីកន្លែងសាធារណៈផ្សេងៗទៀតអំពីការទុកដាក់សំរាមឱ្យបានត្រឹមត្រូវ។
- ត្រូវយកសំរាមទៅដាក់ចោលឱ្យទាន់ពេលវេលាដែលក្រុមហ៊ុនប្រមូលសំរាមបានមកប្រមូល។

- ដើម្បីធ្វើជាពលរដ្ឋល្អ គឺយើងត្រូវចូលរួមថែរក្សាបរិស្ថានឱ្យបានល្អ និងគ្រប់គ្រងសំណល់បានត្រឹមត្រូវ ដូច្នេះដើម្បីធ្វើឱ្យទីក្រុងស្អាត និងគ្មានសំរាម គឺផ្ដើមចេញពីយើងទាំងអស់គ្នា។
- ស្នើសុំសាលារាជធានីគួរមានការរៀបចំកម្មវិធីថ្មី និងប្លែកប្រចាំខែដោយដាក់ឱ្យថ្នាក់មូលដ្ឋានអនុវត្តន៍ ដោយតាមភូមិនីមួយៗអាចថាមានការដឹកនាំដោយ មេភូមិ និងរៀបចំការរើសសំរាមប្រចាំសប្ដាហ៍ ឬប្រចាំខែ ហើយការចំណាយរយៈពេលត្រឹមតែ ១ម៉ោងក្នុងការរើសសំរាមហើយជាងនេះទៅទៀតអ្នកចូលរួមនោះ គឺប្រជាពលរដ្ឋទាំងអស់ដែលរស់នៅក្នុងភូមិនោះផ្ទាល់តែម្ដង។ គោលបំណងនោះ គឺបង្កើតឱ្យទម្លាប់ឱ្យចេះស្រលាញ់បរិស្ថាន គឺថាធ្វើឱ្យគាត់កាត់បន្ថយការចោលសំរាមរបស់គាត់បើមានប្រជាពលរដ្ឋចោលសំរាមច្រើននោះ ខ្លួនគាត់ផ្ទាល់នឹងត្រូវរើសខ្លួនឯងដដែល ដូច្នេះចង់មិនចង់គាត់នឹងបានកាត់បន្ថយសំរាមបានដោយខ្លួនគាត់ និងប្រជាពលរដ្ឋនៅក្នុងភូមិត្រូវមានទំនាក់ទំនងគ្នាល្អ ដោយការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក អំឡុងពេលធ្វើយុទ្ធនាការណ៍រើសសំរាម ប្រចាំសប្ដាហ៍ ឬប្រចាំខែ របស់ពួកគាត់។

ស្របតាមគំនិតដ៏សួចស្ដើងខាងលើនេះខ្ញុំទាំងពីរនាក់សង្ឃឹមថា និងបានជាជ្រុងមួយនៃគំនិតក្នុងការរួមចំណែកការគ្រប់គ្រងសំណល់នៅក្នុងរាជធានីភ្នំពេញក៏ដូចជា ការការពារសោភ័ណភាពរបស់ទីក្រុងយើងឱ្យបានស្អាតផងដែរ និងអាចជាគំនិតក្នុងការដាស់តឿនស្មារតីអ្នកជំនាន់ក្រោយឱ្យយល់ដឹងកាន់តែច្បាស់អំពីបញ្ហាសំរាម និងចូលរួមទាំងអស់គ្នាក្នុងការការពារបរិស្ថានរបស់រាជធានីភ្នំពេញយើងឱ្យមានភាពកាន់តែស្រស់ស្អាតបន្តទៀត។

# ឯកសារយោង

# ឯកសារយោង

## ១. ឯកសារយោងជាលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ, ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦
- អនុក្រឹត្យ ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព្រឹកម្មទឹកកខ្វក់, លេខ ២៣៥ អនក្រ.បក, ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៧
- អនុក្រឹត្យស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក, លេខ ១៦៨ អនក្រ.បក, ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧
- អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន, លេខ ១៣៥ អនក្រ.បក, ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ ២០១៦
- អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ ១១៣ អនក្រ.បក, ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥
- អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង, លេខ ៣៦ អនក្រ.បក, ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៩៩
- អនុក្រឹត្យ ស្តីពីការបំពុលទឹក, លេខ ២៧ អនក្រ.បក, ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩
- ប្រកាសអន្តរក្រសួងលេខ ៨០ រវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាននៅក្នុងឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសំរាម និងកាកសំណល់រឹងនៅថ្នាក់ខេត្ត ក្រុង
- គោលការណ៍ណែនាំបរិស្ថាន ស្តីពីការគ្រប់គ្រងសំណល់រឹងនៅព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០៦

## ២. ឯកសារយោងជាសៀវភៅតែខនិពន្ធ

- វចនានុក្រម សម្តេចព្រះមហាសង្ឃរាជ ជួន ណាត
- សៀវភៅ នីតិនគរូបនីយវិទ្យា, សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣
- សៀវភៅ ស្តីពីការគ្រប់គ្រងសំណល់ ក្រសួងបរិស្ថាន
- សៀវភៅ វិធីសាស្ត្រស្រាវជ្រាវ, សាស្ត្រាចារ្យបណ្ឌិត ហាប់ ផល្វី, បោះពុម្ពឆ្នាំ២០២១

## ៣. ឯកសារយោងជាគេហទំព័រទេបសាយ

- គេហទំព័រ https://www.khsearch.com/qna/8874
- គេហទំព័រ សោភ័ណភាពទីក្រុង – Site Title ( wordpress.com )
- គេហទំព័រ ការបំពុលសំរាមៈមូលហេតុ, ផលវិបាកនិងឧទាហរណ៍ ( warbletoncouncil.org )
- គេហទំព័រ សោភ័ណភាពទីក្រុង – Site Title ( wordpress.com )

- គេហទំព័រ https://phnompenh.gov.kh/
- គេហទំព័រ https://thmeythmey.com/?page=detail&id=58963
- គេហទំព័រ https://seylanote.wordpress.com/?s= សំណល់រារ
- គេហទំព័រ https://km.warbletoncouncil.org/contaminacion-por-basura-១៦៥២៤#menu-៦
- គេហទំព័រ https://thmeythmey.com/?page=detail&id=៥៨៩៦៣
- គេហទំព័រ https://opendevelopmentcambodia.net/km/topics/pollution-and-waste/
- គេហទំព័រ https://teangtnaut.org/wp-content/uploads/២០១៩/០៨/STT-Waste-Management-Community-Booklet-Kh-Final_.pdf

# ឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធ

**១. ឧបសម្ព័ន្ធគតិយុត្ត**

**ឧបសម្ព័ន្ធទី១៖** ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ, ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦

**ឧបសម្ព័ន្ធទី២៖** អនុក្រឹត្យ ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព្រឹកម្មទឹកកខ្វក់, លេខ ២៣៥ អនក្រ.បក, ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧

**ឧបសម្ព័ន្ធទី៣៖** អនុក្រឹត្យ ស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក, លេខ ១៦៨ អនក្រ.បក, ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧

**ឧបសម្ព័ន្ធទី៤៖** អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន, លេខ ១៣៥ អនក្រ.បក, ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦

**ឧបសម្ព័ន្ធទី៥៖** អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ ១១៣ អនក្រ.បក, ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥

**ឧបសម្ព័ន្ធទី៦៖** អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង, លេខ ៣៦ អនក្រ.បក, ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៩៩

**២. ឧបសម្ព័ន្ធរូបភាព**

**ឧបសម្ព័ន្ធទី១៖** សំណល់រឹង-រាវ

**ឧបសម្ព័ន្ធទី២៖** ការគ្រប់គ្រងសំណល់

**ឧបសម្ព័ន្ធទី៣៖** ការទុកដាក់សំណល់

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១១៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## សម្រេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាពសាធារណៈ និងបរិស្ថាន។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- ពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី ក្រុងនិងស្រុក និងធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ
- កំណត់វិធានការចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើការញែក ការទុកដាក់ ការសម្អាត ការប្រមូល ការដឹកជញ្ជូន ការកែច្នៃ និងការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះពុំមានវិសាលភាពអនុវត្តលើការងារគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម និងសំណល់គ្រោះថ្នាក់ឡើយ។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

## ជំពូកទី២

## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥ .-**

ក្រសួងបរិស្ថាន មានតួនាទីដឹកនាំ និងជំរុញកិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ
- ផ្តល់ការណែនាំបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ដឹកនាំសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន ឬសាធារណៈ ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារ គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការអប់រំក្នុងនិងក្រៅប្រព័ន្ធ និងការផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ (3R: Reduce, Reuse, Recycle) និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៦.-**

ក្រសួងមហាផ្ទៃ មានតួនាទីជំរុញដល់កិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- គាំទ្រនិងសហការជាមួយក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍសមត្ថភាព និងការចែករំលែកបទពិសោធន៍អំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល និងកៀរគរការគាំទ្រនានាទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ផ្តល់អន្តរាគមន៍ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៧.-**

រដ្ឋបាលខេត្តត្រូវផ្តល់ការគាំទ្រ និងការសម្របសម្រួល ព្រមទាំងជំរុញកិច្ចប្រតិបត្តិការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលអនុវត្តដោយរដ្ឋបាលក្រុង ស្រុក និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានចាំបាច់នានាសម្រាប់ណែនាំនិងជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ណែនាំដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកា

ប្រចាំឆ្នាំសម្រាប់គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ជំរុញ និងគាំទ្រការបង្កើតសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន
- កៀរគរធនធាន មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលក្រុង ស្រុកលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងជំរុញការអប់រំ និងការផ្សព្វផ្សាយតាមគ្រប់រូបភាពដល់សាធារណជនអំពីសារប្រយោជន៍នៃការញែកសំរាម សំណល់រឹងទីប្រជុំជន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន
- សម្របសម្រួលដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំនិងប្រើប្រាស់រួមគ្នានូវសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តរបស់រដ្ឋបាលក្រុង ស្រុកក្នុងការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៨.-**

មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្តលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីអនាម័យបរិស្ថានតាមរយៈការអប់រំ និងធ្វើការផ្សព្វផ្សាយអំពីការទុកដាក់ ការសម្អាត ការញែក ការកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការចូលរួមប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួមរៀបចំផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ចូលរួមផ្តល់យោបល់បច្ចេកទេសលើសំណើ ឬគម្រោងសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងដំណើរការសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងសកម្មភាពកែច្នៃសំរាម សំណល់រឹងប្រជុំជន
- ជំរុញការអនុវត្តវិធានការច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងចូលរួមការអនុវត្តវិធានការពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន និង
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីស្ថានភាព និងដំណើរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកមានតួនាទីក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- រៀបចំ និងអនុវត្តនូវវិធានការសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមរយៈការដាក់ចេញជាដីកា ឬលិខិតបទដ្ឋាននានា
- បង្កើត គ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធ្វើការណែនាំដល់ប្រជាពលរដ្ឋអំពីការសម្អាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលបានរៀបចំនៅក្នុងមូលដ្ឋាន និង
- អប់រំនិងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកនីមួយៗអាចស្នើសុំបង្កើតអង្គភាព ឬការិយាល័យដាក់លាក់ចំណុះរដ្ឋបាលរបស់ខ្លួនសម្រាប់ទទួលខុសត្រូវលើកិច្ចការនេះ ស្របតាមគោលការណ៍ និងនីតិវិធីជាធរមាន ដើម្បីធានាដល់ប្រសិទ្ធភាព និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១១.-**

រដ្ឋបាលរាជធានីត្រូវផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឬ/និងរដ្ឋបាលសង្កាត់។

រដ្ឋបាលក្រុង ស្រុកអាចធ្វើប្រតិភូកម្មមុខងារមួយផ្នែកក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១២.-**

រដ្ឋបាលខណ្ឌត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួល និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងរាជធានី និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តមុខងារដែលបានទទួលក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួម និងសហការអនុវត្តនូវកម្មវិធីនានានៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូលនិងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១៣.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួលប្រតិភូកម្ម និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមការធ្វើប្រតិភូកម្ម
- ចូលរួមអប់រំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការប្រើប្រាស់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ច
- ចូលរួមផ្តល់យោបល់លើការរៀបចំកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការងារសេវាសម្អាតប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង
- ចូលរួមសហការពង្រឹងការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១៤.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចដាក់ចេញលិខិតបទដ្ឋានសម្រាប់ណែនាំដល់ការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

## ជំពូកទី៣
## ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា១៥.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវអនុវត្តការញែក និងការវេចខ្ចប់សំរាម សំណល់រឹងដែលអាចប្រើប្រាស់ឡើងវិញ ឬកែច្នៃបានដាច់ដោយឡែកពីសំរាម សំណល់រឹងដែលត្រូវបោះចោលទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៦.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការវេចខ្ចប់ដោយថង់ ឬការដាក់នៅក្នុងធុងសំរាមផ្ទាល់ខ្លួននូវសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងលក្ខណៈហ្មត់ចត់ មិនឱ្យលេចធ្លាយ មិនឱ្យលេចជ្រាបទឹកស្អុយ ឬមិនឱ្យមានភាយក្លិនស្អុយក្នុងរយៈពេលនៃការទុកដាក់រង់ចាំការបញ្ចេញទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៧.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការរក្សាទុកនូវកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងរបស់ខ្លួននៅក្នុងរបង ឬបរិវេណនៃលំនៅឋាន អគារ ឬទីតាំងរបស់ខ្លួន និងត្រូវបញ្ចេញទៅតាមពេលម៉ោងដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការត្រួតពិនិត្យឱ្យបានម៉ឺងម៉ាត់លើការអនុវត្តការបញ្ចេញកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជនទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈរង់ចាំការប្រមូល និងដឹកជញ្ជូនទៅតាមពេលម៉ោងដែលបានកំណត់។

**មាត្រា១៨.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនដែលប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំដីកា ឬលិខិតបទដ្ឋាននានា ដើម្បីណែនាំអនុវត្តការសម្អាត ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានលក្ខណៈឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃទីប្រជុំជននីមួយៗ និងត្រូវធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងលើកកម្ពស់សោភ័ណភាព អនាម័យ និងបរិស្ថាននៅតាមទីប្រជុំជន ។

ដីកា ឬលិខិតបទដ្ឋានខាងលើនេះ ត្រូវរៀបចំឡើងដោយអនុលោមតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសជាធរមាន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវផ្សព្វផ្សាយដីកា ឬលិខិតបទដ្ឋាននានា ដូចមានចែងក្នុងកថាខ័ណ្ឌខាងលើឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាឱ្យមានការចូលរួមអនុវត្តប្រកបដោយការទទួលខុសត្រូវ។

## ជំពូកទី៤
## វិធានការទូទៅលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា២០.-**

ត្រូវបានហាមឃាត់ដាច់ខាតនូវការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល តាមប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការទប់ស្កាត់ការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល ប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

**មាត្រា២១.-**

រូបវន្តបុគ្គល និងនីតិបុគ្គលដែលប្រើប្រាស់ទីសាធារណៈសម្រាប់ការប្រារព្ធ ឬដំណើរការកម្មវិធីរបស់ខ្លួន ត្រូវទទួលខុសត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងពិធីទៅឱ្យអ្នកផ្តល់សេវាប្រមូលក្នុងមូលដ្ឋាន ទៅតាមតម្លៃដែលបានកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា២២.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់ចែងឱ្យមានធុងសំរាមសាធារណៈ និងត្រូវរៀបចំឱ្យមានសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតពីការលក់ដូរនៅតាមដងផ្លូវ និងទីសាធារណៈ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ម្ចាស់ ឬអ្នកគ្រប់គ្រងផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាសសិប្បកម្ម មណ្ឌលកំសាន្តត្រូវរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណ សម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន។

**មាត្រា២៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកម៉ៅការការដ្ឋានវាយកម្ទេច ជួសជុល ឬសាងសង់លំនៅឋាន ឬអគារត្រូវទទួលខុសត្រូវលើសំរាម សំណល់រឹងដែលចេញពីការដ្ឋានរបស់ខ្លួន ដូចខាងក្រោម៖

- ទុកដាក់ឱ្យបានត្រឹមត្រូវ មិនបង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាន និង
- សម្អាត ប្រមូល និងដឹកជញ្ជូនដោយខ្លួនឯងទៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ឬប្រើប្រាស់សេវា សម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានក្នុងមូលដ្ឋាន និងត្រូវបង់ថ្លៃតាមការកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា២៤.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវកំណត់កន្លែងសមស្របសម្រាប់ស្តុកសំរាម សំណល់រឹងទីប្រជុំជនបណ្តោះអាសន្នតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពក្នុងការប្រមូល និងដឹកជញ្ជូន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវកំណត់ពេលវេលាដែលអាចអនុញ្ញាតឱ្យបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនយកទៅដាក់នៅកន្លែងស្តុកសំរាមបណ្តោះអាសន្ន និងត្រូវចាត់វិធានការរារាំងការយកសំរាម សំណល់រឹងទៅបញ្ចេញនៅកន្លែងស្តុកសំរាមបណ្តោះអាសន្នខុសពេលវេលាដែលបានកំណត់។

**មាត្រា២៥.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងនានា និងបុរីលំនៅឋាន ត្រូវរៀបចំកន្លែងសមស្របសម្រាប់ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងបរិវេណគ្រប់គ្រងរបស់ខ្លួនរង់ចាំការដឹកចេញដែលមិនបង្កផលប៉ះពាល់ដល់សោភ័ណភាព សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងសុខភាពសាធារណៈ។

**មាត្រា២៦.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការបន្ទាន់ចំពោះករណីមានការកកស្ទះសំរាម សំណល់រឹងទីប្រជុំជនដែលបណ្តាលមកពីភាពអសកម្មនៃអ្នកផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនដោយប្រើប្រាស់គ្រប់មធ្យោបាយតាមដែលអាចធ្វើបានក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដើម្បីដោះស្រាយភាពកកស្ទះ។

ចំពោះការចំណាយក្នុងប្រតិបត្តិការខាងលើ គឺជាបន្ទុកផ្ទាល់របស់អ្នកផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងនៅក្នុងទីប្រជុំជននោះ។

**ប្រការ២៧.-**

ការធ្វើអាជីវកម្មបូម ដឹកជញ្ជូន និងការបោះចោលសំណល់ភក់ពីអាងស៊ិបទិក ត្រូវមានការអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌបន្ទាប់ពីបានទទួលយោបល់បច្ចេកទេសពីមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា២៨.-**

ក្រសួងបរិស្ថានត្រូវផ្តល់ការណែនាំអំពីបច្ចេកទេសគ្រប់គ្រងដោយឡែក សម្រាប់ប្រភេទសំណល់គ្រោះថ្នាក់ដែលបង្កើតនៅតាមលំនៅឋាន ស្ថាប័ន ឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

បញ្ជីសំណល់គ្រោះថ្នាក់ដែលបង្កើតតាមលំនៅឋាន ស្ថាប័នឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍មានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា២៩.-**

សំណល់រឹងឧស្សាហកម្មនិងសំណល់គ្រោះថ្នាក់ដែលបង្កើតចេញពីសកម្មភាពផលិតកម្មនៃរោងចក្រ អាជីវកម្មរ៉ែ និងពីប្រភពដទៃទៀតក្រៅពីទីតាំង ឬប្រភពដែលមានចែងក្នុងមាត្រា២៨នៃអនុក្រឹត្យនេះ ត្រូវគ្រប់គ្រងដោយក្រសួងបរិស្ថាន ដែលកំណត់ដោយបទបញ្ញត្តិដោយឡែក។

## ជំពូកទី៥
## សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៣០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវលើការងារគ្រប់គ្រងសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងមានសុវត្ថិភាពបរិស្ថាន។

**មាត្រា៣១.-**

ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រដ្ឋបាលរាជធានី ក្រុង ស្រុកអាចៈ

ក. រៀបចំ និងប្រតិបត្តិការដោយរដ្ឋបាលរបស់ខ្លួនផ្ទាល់នូវមុខងារមួយផ្នែក ឬទាំងស្រុងនៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ខ. ធ្វើកិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ដែលមានព្រំប្រទល់រដ្ឋបាលជាប់គ្នាក្នុងការផ្តល់សេវារួមជាមួយគ្នា។

គ. ផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូន ឬ/និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនទៅឱ្យផ្នែកឯកជន ជាអ្នកទទួលបន្ទុកអនុវត្ត។

ឃ. ផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ឬផ្តល់សិទ្ធិទៅឱ្យសហគមន៍អនុវត្តនូវមុខងារណាមួយ ឬមួយចំនួននៃមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន។

**មាត្រា៣២.-**

ការផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនត្រូវមានរយៈពេលមិនលើសពី១០ឆ្នាំក្នុងកិច្ចសន្យាមួយលើក និងត្រូវអនុវត្តទៅតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មជាធរមាន។

**មាត្រា៣៣.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយផ្អែកលើកម្រៃសេវាអតិបរមា ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់កម្រៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនសម្រាប់អនុវត្តនៅក្នុងមូលដ្ឋានរបស់ខ្លួន ដោយគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធានាប្រសិទ្ធភាព និងគុណភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- កំណត់កម្រៃសេវាផ្អែកតាមប្រភេទអាជីវកម្ម ទីតាំង កម្រិតប្រាក់ចំណូល បរិមាណសំរាម សំណល់រឹងទីប្រជុំជន ដែលត្រូវបញ្ចេញ និង
- ត្រូវមានការពិនិត្យ និងអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា៣៤.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកត្រូវកំណត់អំពីវិធានការ និងនីតិវិធីសមស្រប មានតម្លាភាព និងមានប្រសិទ្ធភាពសម្រាប់ការប្រមូល ការគ្រប់គ្រង និងការទូទាត់កម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ស្ថាប័ន និងអ្នកពាក់ព័ន្ធ។

ចំណូលដែលប្រមូលបានពីសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជាចំណូលផ្ទាល់របស់

រដ្ឋបាលរាជធានី ក្រុង ស្រុកសាមី។

រដ្ឋបាលរាជធានី ក្រុង ស្រុកអាចប្រើប្រាស់ថវិកាបស់ខ្លួន ឬថវិកាពីប្រភពផ្សេងទៀត សម្រាប់គាំទ្របន្ថែមលើការចំណាយសម្រាប់ការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៣៥.-**

ក្នុងករណីមានសំណើពីសហគមន៍ អង្គការ ឬប្រជាពលរដ្ឋសុំការអនុញ្ញាតប្រមូលយកសំរាម សំណល់រឹងទីប្រជុំជនមកប្រើប្រាស់ក្នុងប្រយោជន៍ណាមួយ រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយមានការពិគ្រោះយោបល់ជាមួយមន្ទីរបរិស្ថានរាជធានី ខេត្តអាច ៖

ក. ពិនិត្យផ្តល់ការអនុញ្ញាតឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនសម្រាប់យកទៅធ្វើការកែច្នៃធ្វើជីកំប៉ុស្ត៍ ផលិតឧស្ម័ន ប្រសិនបើសកម្មភាពប្រមូលយកសំរាមសំណល់រឹងនោះ មិនធ្វើឱ្យប៉ះពាល់ដល់ផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមិនមានផលប៉ះពាល់ជាអវិជ្ជមានដល់ការរស់នៅនៃមជ្ឈដ្ឋានជុំវិញ និងបរិស្ថាន។

ខ. ផ្តល់ការអនុញ្ញាតឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់កម្ទេចកម្ទីថ្ម និងដីចេញពីសកម្មភាពការដ្ឋានផ្លូវថ្នល់ សំណង់អគារ ឬលំនៅឋាន ដែលមិនមានលាយឡំសំរាម សំណល់រឹងទីប្រជុំជន និងមិនមានផ្ទុកឬលាយឡំជាមួយសំណល់គ្រោះថ្នាក់ ដើម្បីយកទៅចាក់បំពេញរណ្តៅដីកម្មសិទ្ធិសហគមន៍ អង្គការ ឬជីឯកជន។

## ជំពូកទី៦
## វិធានការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៣៦.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកត្រូវធ្វើការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនឱ្យស្របតាមទីតាំងស្ថានភាពភូមិសាស្ត្រជាក់ស្តែងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ចំពោះរដ្ឋបាលក្រុង ស្រុក ការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាមសំណល់រឹងទីប្រជុំជន ត្រូវមានការឯកភាពពីរដ្ឋបាលខេត្ត។

រាល់គម្រោងស្នើសុំបង្កើតទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនត្រូវស្នើសុំការពិនិត្យ សម្រេចពីក្រសួងបរិស្ថានលើបច្ចេកទេសរៀបចំទីលាន វិធានការការពារបរិស្ថានក្នុងពេលដំណើរការ និងពេលបិទបញ្ចប់ការប្រើប្រាស់ទីលាន និងរយៈពេលនៃការប្រើប្រាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣៧.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ត្រូវដំណើរការទីលានរបស់ខ្លួនតាមលក្ខខណ្ឌបច្ចេកទេស និងវិធានការការពារបរិស្ថាន តាមការកំណត់របស់ក្រសួងបរិស្ថាន។

ក្នុងករណីកើតមានហេតុការណ៍បំពុលបរិស្ថានបង្កដោយដំណើរការនៃទីលាន ម្ចាស់ ឬអ្នកគ្រប់

គ្រងទីលានត្រូវចាត់វិធានទប់ស្កាត់ជាបន្ទាន់ និងត្រូវផ្តល់ព័ត៌មានជាបន្ទាន់ទៅរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ និងមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា៣៨.-**

ក្រសួងបរិស្ថាន និងរដ្ឋបាលរាជធានី ខេត្តត្រូវចុះធ្វើការតាមដានត្រួតពិនិត្យជាប្រចាំលើការអនុវត្តរបស់ម្ចាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន នូវវិធានការទប់ស្កាត់និងកាត់បន្ថយផលប៉ះពាល់បរិស្ថានពីដំណើរការគ្រប់គ្រងទីលាន។

## ជំពូកទី៧
## ទោសបញ្ញត្តិ

**មាត្រា៣៩.-**

ការមិនអនុវត្តតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌក្នុងការញែក និងការវេចខ្ចប់ដោយឡែកនូវសំរាម សំណល់រឹងទីប្រជុំជនដែលអាចប្រើប្រាស់ឡើងវិញឬកែច្នៃបាន ដូចមានចែងក្នុងមាត្រា១៥នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ១០.០០០ (មួយម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១០០.០០០ (មួយសែន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ២០០.០០០ (ពីរសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤០.-**

បុគ្គលដែលនាំយកកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជន ទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈខុសពេលម៉ោងអនុញ្ញាតឱ្យធ្វើការបញ្ចេញ ដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៧នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤១.-**

បុគ្គលដែលបានប្រើប្រាស់សេវាគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន ហើយមិនព្រមបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន ឬសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលរៀបចំ ឬកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៨ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃតម្លៃសេវាសំរាម សំណល់រឹងដែលត្រូវបង់ក្នុងមួយខែ។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤២.-**

បុគ្គលដែលបោះចោលសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌហាមឃាត់ការបោះចោលសំរាម សំណល់រឹងទីប្រជុំជន ដូចមានចែងក្នុងមាត្រា២០ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូល សំអាតយកទៅដាក់ធុងសំរាមសាធារណៈ
- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមផ្ទះ ភោជនីយដ្ឋាន ទីកំសាន្ត និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៣.-**

បុគ្គលដែលដុតសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានីឬខណ្ឌ ក្រុង ស្រុកហាមឃាត់ ដូចមានចែងក្នុងមាត្រា២០នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូលសំអាត
- ចំនួន ១០០.០០០ (មួយសែន) រៀល ចំពោះម្ចាស់លំនៅឋាន អ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលសំអាត

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ ភោជនីយដ្ឋាន ទីកំសាន្ត អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៤.-**

បុគ្គលដែលគេចវេសមិនទទួលខុសត្រូវលើសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតនៅក្នុងពិធីនានារបស់ខ្លួនដែលប្រារព្ធនៅលើដងផ្លូវ ឬនៅលើទីសាធារណៈ ដូចមានចែងក្នុងមាត្រា២១នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់បន្ថែមទៅលើតម្លៃសេវាសំអាត ប្រមូលនិងដឹកជញ្ជូនដូចខាងក្រោម៖

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះពិធីមង្គលការ សម្ពោធហាង និងបុណ្យ លើកលែងពិធីបុណ្យសព
- ចំនួន ៦០០.០០០ (ប្រាំមួយសែន) រៀល ចំពោះពិធីប្រជុំ មិទ្ទិញ
- ចំនួន ២.០០០.០០០ (ពីរលាន) រៀល ចំពោះការប្រគុំតន្ត្រីសាធារណៈ

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៥.-**

បុគ្គលម្ចាស់ ឬអ្នកគ្រប់គ្រងទីផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម មណ្ឌលកំសាន្ត ដែលមិនបានរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណសម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន ដូចមានចែងក្នុងវាក្យខណ្ឌ២ មាត្រា២២នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួន៤០០.០០០(បួនសែន) រៀល។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៦.-**

បុគ្គលម្ចាស់ការដ្ឋានសំណង់អគារដែលធ្វើការទុកដាក់សំរាម សំណល់រឹងទីប្រជុំជនពីការងារសំណង់ ឬសម្ភារៈសំណង់មិនបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬការទុកដាក់បង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព ឬបរិស្ថាន ដូចមានចែងក្នុងមាត្រា២៣នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះការដ្ឋានសំណង់លំនៅឋាន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន

- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល ចំពោះការដ្ឋានសំណង់អគារធំៗ បុរីលំនៅឋាន និង ត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៧.-**

បុគ្គលដែលធ្វើអាជីវកម្មបូមសំណល់កក់ពីប្រព័ន្ធលូ ឬពីអាងស៊ិបទិក ដោយមិនមានលិខិតអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬដឹកយកទៅបញ្ចេញចោលខុសទីកន្លែងដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ ដូចមានចែងក្នុងមាត្រា២៧នៃអនុក្រឹត្យនេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះអាជីវកម្មជាលក្ខណៈគ្រួសារ
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះអាជីវកម្មជាលក្ខណៈក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៨.-**

បុគ្គលដែលធ្វើការទុកដាក់ វេចខ្ចប់ ឬប្រមូលនិងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន លាយឡំជាមួយសំណល់រឹងឧស្សាហកម្ម សំណល់វេជ្ជសាស្ត្រ ឬសំណល់គ្រោះថ្នាក់ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ៥០០.០០០ (ប្រាំសែន) រៀល សម្រាប់អាជីវកម្ម សិប្បកម្ម មន្ទីរពេទ្យ សម្ភព
- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល សម្រាប់ក្រុមហ៊ុនសេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៩.-**

បុគ្គលដែលមិនបានបង់ប្រាក់ពិន័យអន្តរការណ៍នេះក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃដែលបានទទួលបង្កាន់ដៃបង់ប្រាក់ពិន័យ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាពីរដង បើលើសពី៦០(ហុកសិប)ថ្ងៃ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាបីដង។ បើផុតរយៈពេល៩០(កៅសិប)ថ្ងៃ រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំសំណុំឯកសារប្ដឹងទៅសាលាដំបូងរាជធានី ខេត្ត។

**មាត្រា៥០.-**

បុគ្គលដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចផាកពិន័យអន្តរការណ៍របស់មន្ត្រីមានសមត្ថកិច្ចរបស់រាជធានី ក្រុង ស្រុក ខណ្ឌ មានសិទ្ធិប្ដឹងតវ៉ាទៅអភិបាលរាជធានី ក្រុង ស្រុក ខណ្ឌសាមី។

អភិបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវសម្រេចលើបណ្ដឹងតវ៉ាក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ យ៉ាងយូរគិតពីថ្ងៃទទួលពាក្យបណ្ដឹង។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់រាជធានី ក្រុង ស្រុក ខណ្ឌមានសិទ្ធិប្ដឹងទៅតុលាការតាមនីតិវិធីជាធរមាន។

**មាត្រា៥១.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវក្នុងការរៀបចំយន្តការសម្រាប់អនុវត្តវិធានការពិន័យអន្តរការណ៍ឱ្យមានប្រសិទ្ធភាព។

នីតិវិធីនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ចំណូលពីការពិន័យអន្តរការណ៍នេះនឹងត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ។

## ជំពូកទី៨
## អន្តរបញ្ញត្តិ

**មាត្រា៥២.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវពិនិត្យការអនុវត្តកិច្ចសន្យាកន្លងមក និងធ្វើការពិភាក្សាពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្ដល់សេវា ព្រមទាំងអ្នកពាក់ព័ន្ធនានាដើម្បីពិនិត្យ និងកែសម្រួលនូវកិច្ចសន្យាផ្ដល់សេវាសំរាម សំណល់រឹងដែលកំពុងអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងរយៈពេល១២(ដប់ពីរ)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

**មាត្រា ៥៣.-**

ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបង្កើតក្រុមការងារអន្តរក្រសួងមួយ ដើម្បីពិភាក្សា និងសម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ទេរការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងប្រតិភូកម្មការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ។

## ជំពូកទី៩
## អវសានបញ្ញត្តិ

**មាត្រា៥៤.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្តេចក្រឡាហោម ស ខេង**

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សាយ សំអាល់**

**កន្លែងទទួល** ÷

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥៥*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

## ឧបសម្ព័ន្ធទី១
## សន្ទានុក្រម

១- **សំរាម** សំដៅដល់របស់របរប្រើប្រាស់ សម្ភារ ផលិតផលដែលបានបន្សល់ ឬបង្កើតពីសកម្មភាព និងជីវភាពផ្ទាល់របស់មនុស្សប្រចាំថ្ងៃ ដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់។

២- **សំណល់រឹងទីប្រជុំជន** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬបង្កើតពីសកម្មភាព អាជីវកម្ម ឬសេវាកម្មដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់។

៣- **សំណល់រឹងឧស្សាហកម្ម** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬបង្កើតពីសកម្មភាព ផលិតកម្មនៃរោងចក្រ ឬសហគ្រាសដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់។

៤- **សំណល់គ្រោះថ្នាក់** សំដៅដល់វត្ថុធាតុរឹង រាវ ឧស្ម័ន សារធាតុវិទ្យុសកម្ម សារធាតុផ្ទុះ សារធាតុឆេះ សារធាតុចំលងជំងឺ ឬធ្វើឱ្យលោក ធ្វើឱ្យច្រេះ ធ្វើអុកស៊ីតកម្ម បង្កការពុល បង្កឱ្យមានជំងឺមហារីក ឬសារធាតុគីមីពុលដទៃទៀត ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន។ ប្រភពសំណល់គ្រោះថ្នាក់អាចមានប្រភពមកពីលំនៅដ្ឋាន ទីផ្សារ ផ្សារទំនើប ទីកន្លែងកំសាន្ត អគារសាធារណៈ គ្រឹះស្ថានសិក្សា សកម្មភាពអាជីវកម្ម សេវាកម្ម សិប្បកម្ម រោងចក្រ សកម្មភាពកសិកម្ម និងអាជីវកម្មរ៉ែ។

៥- **ការទាញយកធនធាន** សំដៅដល់សកម្មភាពជម្រើស ឬប្រើប្រាស់សំរាម សំណល់រឹងធ្វើជាជីកំប៉ុស្ដិ៍ កែច្នៃ ទាញយកថាមពល ឬសារប្រយោជន៍នានា។

៦- **ការកែច្នៃ** សំដៅដល់សកម្មភាព ឬដំណើរការបំបែក ឬបំលែងសំរាម សំណល់រឹងទៅជាវត្ថុធាតុដើមសម្រាប់បម្រើការផលិតឡើងវិញ។

៧- **ការប្រើប្រាស់ឡើងវិញ** សំដៅដល់ការជម្រើសសំរាម សំណល់រឹងដែលអាចប្រើប្រាស់សារជាថ្មីឡើងវិញដោយគ្រាន់តែឆ្លងកាត់ការលាងសម្អាត ឬការជួសជុលដោយនៅរក្សាទ្រង់ទ្រាយដើម។

៨- **ការញែក** សំដៅដល់ការបែងចែកទៅតាមប្រភេទនៃសំរាម សំណល់រឹងនៅនឹងប្រភពបង្កើតសម្រាប់គោលបំណងការទាញយកធនធាន ឬដើម្បីសុវត្ថិភាពក្នុងការយកទៅចាក់នៅទីលាន។

៩- **ទីលាន** សំដៅដល់ទីកន្លែងដែលអាជ្ញាធរបានកំណត់ ឬរៀបចំតាមវិធានសុវត្ថិភាពបរិស្ថានសម្រាប់ការចាក់សំរាម សំណល់រឹងទីប្រជុំជន។

១០-**ការធ្វើប្រព្រឹត្តកម្ម** សំដៅដល់សកម្មភាព ឬវិធានការនៅក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលរួមមាន៖

ក). ការបន្ថយទំហំ ឬបរិមាណសំរាម សំណល់រឹងមុនការយកទៅចាក់នៅទីលាន ដូចជា ការដោះបំបែក ការកិនកម្ទេច ការរំលាយ ឬការដុតនៅក្នុងឡ។

ខ). ការដកយក ឬកម្ទេចចោលជាតិពុល សារធាតុគ្រោះថ្នាក់ ឬភ្នាក់ងារចម្លងជម្ងឺ ដែលមាននៅក្នុងសំរាម សំណល់រឹងមុនការយកទៅចាក់នៅទីលាន។

១១- **ទីប្រជុំជន** សំដៅដល់ទីរួមក្រុង ទីរួមស្រុក ទីប្រជុំជនផ្សារ និងលំនៅដ្ឋាន រួមទាំងរមណីយដ្ឋាន មណ្ឌលកំសាន្ត តំបន់ទេសចរណ៍។

១២- **ទីតាំង** សំដៅដល់កន្លែងផលិតកម្ម អាជីវកម្ម សេវាកម្ម អគាររដ្ឋបាលសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម។

១៣- **អាងស៊ិបទិក** សំដៅដល់អាងស្តុកសំណល់បង្គន់អនាម័យបឋម។

១៤- **ពិន័យអន្តរការណ៍** សំដៅដល់ការតម្រូវជនប្រព្រឹត្តល្មើលទៅនឹងប្បញ្ញត្តិ ដែលមានចែងក្នុងអនុក្រឹត្យនេះ បង់ប្រាក់ពិន័យតាមកម្រិតទណ្ឌកម្មដែលបានប្រព្រឹត្តល្មើស។

១៥- **សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន** សំដៅដល់សេវាប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

## ឧបសម្ព័ន្ធទី២

## សំណល់គ្រោះថ្នាក់ ដែលបង្កើតនៅតាមលំនៅឋាន ស្ថាប័ន ឬអាគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍

សំណល់គ្រោះថ្នាក់ដែលបង្កើតឡើងនៅតាមលំនៅឋាន ស្ថាប័ន ឬអាគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍រួមមាន៖

១- សំណល់អាគុយ និងថ្មពិល ឬថ្មសាកគ្រប់ប្រភេទ។

២- សំណល់គ្រឿងបរិក្ខារអគ្គិសនី និងអេឡិចត្រូនិក។

៣- សំណល់សំបកដប ឬកំប៉ុងដែលមានប្រឡាក់សារធាតុគីមី ឬថ្នាំពុលកសិកម្ម។

៤- សំណល់សំបកកង់យានយន្តគ្រប់ប្រភេទ។

៥- សំណល់ប្រេងម៉ាស៊ីន។

៦- សំណល់ថ្នាំលាបថ្នាំជ្រលក់ពណ៌ និងសម្ភារវេចខ្ចប់។

៧- សំណល់ទឹកខ្មៅបោះពុម្ព។

៨- សំណល់ដែលជាសមាសធាតុអាបេស្តូស។

## រូបភាពឧបសម្ព័ន្ធទី១ សំណល់រឹង-រាវ











## ឧបសម្ព័ន្ធ រូបភាពអនុវត្តន៍ការគ្រប់គ្រងសំណល់



ការគ្រប់គ្រងទឹកសំអុយនៅទីលានដង្កោ



គំនរសំរាមនៅទីលានដង្កោ



គ្រឿងចក្រប្រើប្រាស់នៅទីលានដង្កោ



រថយន្តប្រើប្រាស់នៅទីលានដង្កោ



អ្នករើសសំណល់អេតចាយនៅទីលានដង្កោ



សំណល់អេតចាយប្រមូលបាន ត្រូវបានថ្លឹងលក់



ភ្លើងឆេះ និងភ្នាក់ងារពន្លត់អគ្គីភ័យនៅទីលានដង្កោ



ភ្លើងឆេះ និងផ្សែងហុយនៅទីលានដង្កោ



ទីលានដង្កោបន្ទាប់ពីភ្លើងឆេះ



គំនរសំរាមគ្មានសណ្តាប់ធ្នាប់នៅទីដីទំនេរ




គំនរសំណល់អេឡិចត្រូនិកនៅតាមផ្លូវ



គំនរសំណល់សំណង់នៅលើចិញ្ចើមផ្លូវ



សំណល់គ្រោះថ្នាក់ និងសំរាមសំពីងសំពោង



សំរាមជំនឿសាសនានៅតាមដងផ្លូវ



សំណល់ឧស្សាហកម្មពីរោងចក្រកាត់ដេរទី១



សំណល់ឧស្សាហកម្មពីរោងចក្រកាត់ដេរទី២

## ឧបសម្ព័ន្ធ ផែនទីតំបន់នៃទីលានចាក់សំរាមដង្កោ



## រូបភាពឧបសម្ព័ន្ធទី៣ ការទុកដាក់សំណលរឹង-រាវ










